លេខ៨
ឆ្នាំ២០២០

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា តែងតែយកចិត្តទុកដាក់ និងកំណត់ការងារកែទម្រង់ គឺជាឧបករណ៍គោលនយោបាយគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា និងបង្កើតកាលានុវត្តភាពថ្មីៗ ឆ្ពោះទៅរកការអភិវឌ្ឍ និងវិបុលភាព។ ការងារកែទម្រង់ដ៏មានសារៈសំខាន់បី ដែលកំពុងបន្តតួនាទីជាសសរស្តម្ភសម្រាប់ធានាជោគជ័យនៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦នេះគឺ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ចាប់តាំងពីការចាប់ផ្តើមដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ២០០៤ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវវឌ្ឍនភាពជាសារវន្តជាច្រើនដែលបានជំរុញនាវាកម្ពុជាឆ្ពោះទៅឆាកអន្តរជាតិប្រកបដោយមោទនភាព។ សម្រាប់ឆ្នាំនេះ គឺជាពេលវេលាថ្មីមួយទៀតដែលកម្មវិធីកែទម្រង់ ត្រូវបានអនុវត្តនិងវាយតម្លៃលើសមិទ្ធកម្មការងារតាមរយៈកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំដែលមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍដែលជាតួអង្គដ៏សំខាន់ក្នុងការជំរុញកិច្ចដំណើរការនៃកម្មវិធីកែទម្រង់ប្រកដបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងការត្រៀមខ្លួនបោះជំហានទៅដំណាក់កាលថ្មីមួយទៀត ក្នុងឆ្នាំបន្តបន្ទាប់។

ជាក់ស្តែង រហូតមកដល់ដើមឆ្នាំ២០១៩នេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទទួលបានលទ្ធផលល្អប្រសើរ ទាំងក្នុងក្របខ័ណ្ឌសកម្មភាពកែទម្រង់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសកម្មភាពកែទម្រង់របស់ក្រសួង-ស្ថាប័ន។ ការអនុវត្តដោយជោគជ័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ដែលធ្វើឱ្យចំណូលកើនឡើងជាលំដាប់, ការគ្រប់គ្រងនិងការវិភាជថវិកាកាន់តែប្រសើរឡើងនិងចំគោលដៅនៃវិស័យអាទិភាព, ការបង្កើតបានជាមូលដ្ឋានសម្រាប់ការកត់ត្រាគណនេយ្យគ្រប់ជ្រុងជ្រោយ និងអាចផលិតរបាយការណ៍បានទាន់ពេលវេលាតាមរយៈការដាក់ឱ្យអនុវត្តជា បណ្តើរៗនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង-ស្ថាប័ន និងតាមបណ្តារដ្ឋបាលរាជធានី-ខេត្តមួយចំនួន សុទ្ធសឹងជាសមិទ្ធកម្មជាក់លាក់ និងជាសមាសធាតុគន្លឹះសម្រាប់វាស់វែងនៅក្នុងរយៈពេលចុងក្រោយនេះ ។

ដោយឡែកនៅត្រីមាសទី១នេះ ក្របខ័ណ្ឌយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនត្រូវបានដាក់អនុម័តឱ្យប្រើប្រាស់ ដែលក្នុងនោះមាន «យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣», «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥», «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥» និង «ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥» ។ ម្យ៉ាងវិញទៀត, ការដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការបង្កើនការផ្សព្វផ្សាយឯកសារថវិកាជាសាធារណៈ ការពង្រឹងតួនាទីស្ថាប័នសវនកម្ម និងអធិការកិច្ច, និងការពង្រឹងសមត្ថភាពមន្ត្រីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាប្រចាំ បានជួយឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាន់តែមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងតម្លាភាព។ លើសពីនេះទៅទៀត, ការចូលរួមរបស់ក្រសួង-ស្ថាប័ន ក្នុងសកម្មភាព កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈមានការរីកចម្រើនជាលំដាប់ ជាពិសេសយន្តការនៃការគ្រប់គ្រងចំណូល, ការរៀបចំថវិកាតាមប្រព័ន្ធថវិកាកម្មវិធី, ការអនុវត្តថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

ជារួមយើងអាចវាយតម្លៃប្រកបដោយការជឿជាក់ថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងស្ថិតនៅលើគន្លងដែលយើងម្ចាស់ការបានទាំងស្រុង ហើយរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានជ្រើសរើសអភិក្រមអនុវត្ត ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបាន ជាពិសេសផ្តល់នូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់នៅតាមដំណាក់កាលនីមួយៗ។ បន្ថែមពីនេះ, ប្រព័ន្ធថវិកាយើងកាន់តែមានភាពជឿទុកចិត្ត និងជាឧបករណ៍សំខាន់សម្រាប់ទ្រទ្រង់ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម, មានបុរេលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ, មានក្របខណ្ឌថវិការកម្មវិធីច្បាស់លាស់ **ជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។**

ជាចុងបញ្ចប់, ក្នុងនាមជាប្រធាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**), ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ និងផ្តល់មូលវិចារដ៏ថ្លៃថ្លាចំពោះសហការី នៃរាជរដ្ឋាភិបាលកម្ពុជា, ក្រសួង-ស្ថាប័ន, និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុដែលបានផ្តល់កិច្ចសហការ និងចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាឧត្តមសេនាធិការជូន **គ.ហ.ស.** ទាំងការងារដឹកនាំ, សម្របសម្រួល, ផ្សព្វផ្សាយ, គាំទ្រ និងត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ និងបន្តគាំទ្រក្នុងទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យប្រព្រឹត្តទៅដោយរលូន និងមានសន្ទុះល្អទៅមុខ, ក្រសួង-ស្ថាប័នដែលជាតួអង្គចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្ត, ព្រមទាំងសហសេវិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕

ថ្ងៃ ពុធ ០១រោច ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

គិតមកត្រឹមដើមឆ្នាំ ២០២០ នេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឆ្លងកាត់ការអនុវត្តកម្មវិធីកែទម្រង់អស់រយៈពេលប្រមាណ ១៦ ឆ្នាំ។ សមិទ្ធផលជាច្រើន បានរំលេចចេញជាបន្តបន្ទាប់ រួមមានជាអាទិ៍ដូចជា លិខិតបទដ្ឋានគតិយុត្តិ ការធ្វើទំនើបកម្មនៃការផ្តល់សេវាសាធារណៈតាមបែបប្រព័ន្ធព័ត៌មានវិទ្យា គណនេយ្យភាព និងតម្លាភាព ជាដើម ដែលបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចក្នុងអត្រា ៧ ភាគរយ ក៏ដូចជាការកាត់បន្ថយនូវភាពក្រីក្រជាបន្តបន្ទាប់ ។

ទោះជាយ៉ាងណា កម្មវិធីកែទម្រង់នេះ ត្រូវបានរំពឹងថានឹងបញ្ចប់នៅឆ្នាំ២០២៥ ដែលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា នឹងឆ្ពោះទៅរកប្រព័ន្ធថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម។ ហេតុដូចនេះ គ្រប់តួអង្គពាក់ព័ន្ធ នៅបន្តយកចិត្តទុកដាក់ពង្រឹងលើការងារកែទម្រង់កន្លងមក និងធ្វើអាទិភាវូបនីយកម្មលើសកម្មភាពកែទម្រង់ថ្មីៗទៀត ដើម្បីឆ្លើយតបនឹងចក្ខុវិស័យខាងលើ។ ទន្ទឹមនេះ ក្នុងតួនាទី និងភារកិច្ចជាអង្គភាពសម្របសម្រួលលើការរៀបចំ ការអនុវត្ត និងការតាមដាននិងវាយតម្លៃ ការងារកែទម្រង់ដែលដឹកនាំដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធាន, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បន្តជំរុញ គាំទ្រ និងសម្របសម្រួល ទាំងក្របខណ្ឌបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់គ្រប់អង្គភាព ក្រសួង-ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់នេះ ។ លើសពីនេះ ការបង្កើនការចូលរួមអនុវត្តការងារកែទម្រង់លើគ្រប់ទិដ្ឋភាពទាំងអស់ គឺជាកិច្ចការសំខាន់មួយ ដែល **អ.គ.ហ.** បន្តយកចិត្តទុកដាក់តាមរយៈការបង្កើនការផ្សព្វផ្សាយ ដែលកន្លងមក **អ.គ.ហ.** បានធ្លាប់ធ្វើរួចមកហើយ រួមមាន ការបង្កើនសមត្ថភាពមន្ត្រីរាជការ តាមរយៈវគ្គបណ្តុះបណ្តាល, សិក្ខាសាលា, និងកិច្ចប្រជុំនានា ការបញ្ជ្រាបការយល់ដឹងដល់សាធារណជនគ្រប់ស្រទាប់វណ្ណៈ តាមរយៈកម្រងខ្សែវីដេអូខ្លី, ការចែកឯកសារគតិយុត្តិនានា, ព្រឹត្តិបត្រកម្មវិធីកែទម្រង់, និងឧបករណ៍ផ្សព្វផ្សាយ ផ្សេងៗទៀត។

ជាក់ស្តែង, ចាប់តាំងពីដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, **អ.គ.ហ.** បានរៀបចំ និងបោះផ្សាយនូវព្រឹត្តិបត្រកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ បានចំនួន ៧ លេខ រួចមកហើយ ។ សម្រាប់ឆ្នាំ២០២០ នេះ, កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក៏បានចេញផ្សាយលេខ ៨ ដែលមាតិកានៃឯកសារនេះ ត្រូវបានរក្សានៅដដែល ប៉ុន្តែ ខ្លឹមសារ គឺស្របតាមបរិបទជាក់ស្តែង។ ការចូលរួមចំណែករបស់មន្ត្រីរាជការ និងដៃគូអភិវឌ្ឍ លើកិច្ចការនេះ បានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ និងការគាំទ្រពីសំណាក់ថ្នាក់ដឹកនាំ នៃអង្គភាពនីមួយៗ លើការងារកែទម្រង់ តាមរយៈការចូលរួមរៀបចំផ្តល់នូវអត្ថបទដែលមានខ្លឹមសារពាក់ព័ន្ធក្នុងក្របខណ្ឌនៃការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។

ក្នុងនាមខ្ញុំជាអគ្គលេខាធិការ នៃ **អ.គ.ហ.**, ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាអនេក និងសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំ ចូលរួម លើកកម្ពស់ លើការងារកែទម្រង់នេះ តាមរយៈការចូលរួមផ្តល់ជាចំណេះដឹង ស្មារតី ភាពសហការ និងការគាំទ្ររហូតមក របស់គ្រប់សហការី នៃ **អ.គ.ហ.** និង គ្រប់ភាគីពាក់ព័ន្ធទាំងអស់ និងស្នើឱ្យបន្តរក្សាអភិក្រមនៃការអនុវត្តការងារនេះ ឱ្យបានជានិច្ចនិរន្តរ៍។៚

ថ្ងៃ ព្រហស្បតិ៍ ៧កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០២០

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

*ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - លេខ៨ - ឆ្នាំ២០២០*

## ព្រឹត្តិការណ៍


**ទំព័រទី ០១**
កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស ស្តីពីការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩

**ទំព័រទី ០៤**
សិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលស្តីពី "ក្របខណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ"

**ទំព័រទី ០៧**
សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃរាជរដ្ឋាភិបាលកម្ពុជា"

**ទំព័រទី ១០**
កម្មវិធីទស្សនកិច្ចផ្លាស់ប្តូរចំណេះដឹងស្តីពីការកែទម្រង់វិស័យសាធារណៈ និងការគ្រប់គ្រងការផ្លាស់ប្តូរនៅប្រទេសអូស្ត្រាលី


## អត្ថបទ


**ទំព័រទី ១៧**
របាយការណ៍សង្ខេបវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រីមាសទី៣ ឆ្នាំ២០១៩

**ទំព័រទី ២៤**
សញ្ញាណទូទៅ នៃការគ្រប់គ្រងការផ្លាស់ប្តូរ

**ទំព័រទី ២៧**
យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម-ជាតិឆ្នាំ ២០១៩-២០២៥

**ទំព័រទី ២៩**
សញ្ញាណទូទៅ នៃចំណូលមិនមែនសារពើពន្ធនៅកម្ពុជា

**ទំព័រទី ៣២**
ការកែទម្រង់ នៃការបើកផ្តល់បៀវត្សតាមនីតិវិធីថ្មី

**ទំព័រទី ៣៤**
វឌ្ឍនភាព នៃការអនុវត្តប្រព័ន្ធ FMIS ឆ្នាំ២០១៩

**ទំព័រទី ៣៦**
ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ " **គណនេយ្យភាព-សមិទ្ធកម្ម** "

## ទំព័រទី ៣៩
ទស្សនាទាន នៃការរៀបចំសៀវភៅស្តីពី “ **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - បទពិសោធន៍កម្ពុជា** ”

## ទំព័រទី ៤១
ការរៀបចំក្របខណ្ឌលទ្ធផលគន្លឹះក្នុងឆ្នាំ របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន

## ទំព័រទី ៤៤
យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥

## ទំព័រទី ៤៧
ស្វែងយល់អំពីក្របខណ្ឌ នៃប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា÷ សវនកម្ម និងអធិការកិច្ច

# សន្ទរកថា

## ទំព័រទី ៥១
សន្ទរកថាបើករបស់ ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ទស្សនៈ និងមតិ

## ទំព័រទី ៥៥
ប្រសាសន៍របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងកិច្ចប្រជុំជាមួយនឹងគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា ស្តីពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០, នាថ្ងៃទី១៤

## ទំព័រទី ៥៥
ប្រសាសន៍របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS

## ទំព័រទី ៥៦
ប្រសាសន៍របស់ឯកឧត្តមកិត្តិបរិវក្សបណ្ឌិត **គាត ឈន់** ប្រធានកិត្តិយស ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ថ្លែងក្នុងសិក្ខាសាលាស្តីពីការបង្កើនភាពជាម្ចាស់លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។

## ទំព័រទី ៥៦
មតិរបស់ដៃគូអភិវឌ្ឍន៍នាកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងក្រុមបច្ចេកទេសដៃគូអភិវឌ្ឍន៍ ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩, នាថ្ងៃទី២២ ខែវិច្ឆិកា

# ផ្នែកទី១

# ព្រឹត្តិការណ៍





# កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារបច្ចេកទេស ស្តីពី ការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៩

*នាព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**), មានរៀបចំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស។*

កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស ដើម្បីត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩ មានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័ន, តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល។ កិច្ចប្រជុំនេះផ្តោតសំខាន់លើការត្រួតពិនិត្យតាមដានវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានអនុវត្តក្នុងដំណាក់កាលទី ៣ ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៩ ។

តាមរយៈរបាយការណ៍បូកសរុប, រហូតមកដល់ត្រីមាសទី ៣ នេះគ្រប់ផ្នែក នៃផែនការសកម្មភាពរួម នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅបន្តមានវឌ្ឍនភាពល្អ និងវិជ្ជមាន។ ក្នុងរយៈពេល ៩ ខែនេះ, រាជរដ្ឋាភិបាលកម្ពុជា បានប្រមូលចំណូលថវិការដ្ឋសរុបប្រមាណ ១៩ ១២៥ ប៊ីលានរៀល ស្មើនឹង ៩០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៩ ។ ការអនុវត្តផែនការប្រមូលចំណូលប្រចាំត្រីមាសទី ៣ បង្ហាញថា ទិន្នផលចំណូលបានពីការប្រមូលដោយពន្ធគយនិងរដ្ឋាករ មានប្រមាណ ៤៩%, ពន្ធដារ មានប្រមាណ



*កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩*



*កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩*

៣២%, ចំណូលមិនមែនសារពើពន្ធ មានប្រមាណ ១២% និងចំណូលផ្សេងៗ ប្រមាណ ៦%។ រីឯ ការអនុវត្តចំណាយស្ថិតក្នុងស្ថានភាពដែលអាច គ្រប់គ្រងបានតាមច្បាប់ជាធរមាន ។ សម្រាប់ការអនុវត្តសកម្មភាពនៃការងារកែទម្រង់ទាំងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាក្របខ័ណ្ឌក្រសួង-ស្ថាប័ន កំពុងបន្តមានវឌ្ឍនភាពល្អប្រសើរ ដែលត្រូវបានរំពឹងទុកថាអាចសម្រេចបានគោលដៅប្រចាំឆ្នាំ។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ក៏បានគូសបញ្ជាក់ថា ការប្រមូល



ចំណូល និងការអនុវត្ត ចំណាយ នៅបន្តមានសុខភាពល្អធៀបនឹងឆ្នាំមុនៗ និងនៅរក្សាបាននិន្នាការល្អប្រសើរទៅតាមការគ្រោងទុក ។ ស្របពេលជាមួយគ្នានេះ, កិច្ចការគន្លឹះៗមួយចំនួនទៀត ត្រូវបន្តពង្រឹងក្នុងការអនុវត្ត កសាង និងរៀបចំបញ្ចប់រួមមាន÷ ការរៀបចំបញ្ចប់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រគន្លឹះៗនានា ដូចជាយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, និងអនុក្រឹត្យស្តីពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈជាដើម។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ក៏បានផ្តល់អនុសាសន៍ណែនាំបន្ថែម លើការពង្រឹងសមត្ថភាពមន្ត្រីដោយត្រូវគិតគូររៀបចំឱ្យបានគ្រប់ជ្រុងជ្រោយ តាមរយៈការបន្តបណ្តុះបណ្តាលដែលជាក់លាក់ ប្រកបដោយគុណភាព ក៏ដូចជាបំពាក់ជំនាញច្បាស់លាស់ និងប្រើប្រាស់ធនធានដែលបានបណ្តុះបណ្តាល

*សម្រាប់ការអនុវត្តសកម្មភាព នៃការងារកែទម្រង់ ទាំងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាក្របខណ្ឌក្រសួង-ស្ថាប័ន កំពុងមានវឌ្ឍនភាពល្អប្រសើរ ដែលត្រូវបានរំពឹងទុកថាអាចសម្រេចបានគោលដៅប្រចាំឆ្នាំ ។*



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**

ឲ្យត្រូវតាមតួនាទី និងភារកិច្ច និងជំនាញនីមួយៗ ។

ជាមួយគ្នានេះ, តំណាងដៃគូអភិវឌ្ឍន៍បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលដែលសម្រេចបានក្នុងត្រីមាសទី ៣ និងការខិតខំប្រឹងប្រែងអនុវត្តការងារកែទម្រង់យ៉ាងសកម្មពីក្រសួង-ស្ថាប័ន ទាំងអស់ ។ ដៃគូអភិវឌ្ឍន៍ ក៏បានផ្តល់អនុសាសន៍បន្ថែមជាពិសេស ទៅលើប្រសិទ្ធភាពនៃការអនុវត្តចំណាយរបស់ក្រសួង-ស្ថាប័ន, ការប្រើប្រាស់ប្រព័ន្ធ (Financial Management Information System - FMIS) និងពង្រឹងការផ្សព្វផ្សាយលើការត្រួតពិនិត្យ ការអនុវត្តថវិកាកម្មវិធី។ បន្ថែមពីនេះ, ដៃគូអភិវឌ្ឍន៍នៅតែបន្តផ្តល់ការសហការល្អ និងកិច្ចគាំទ្រ ទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុទៅលើសកម្មភាពគន្លឹះសំខាន់ៗរបស់ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅកម្ពុជានេះ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ចំពោះអនុសាសន៍ដែលជាធាតុចូលបន្ថែមរបស់ដៃគូអភិវឌ្ឍន៍ និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ កោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងការ យកចិត្តទុកដាក់ខ្ពស់របស់ដៃគូអភិវឌ្ឍន៍ដែលបានចូលរួមសហការ និងធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើស្មារតីដែលកម្ពុជា ជាម្ចាស់លើការដ្ឋានការងារកែទម្រង់នេះ ដែលធាតុចូលបន្ថែមរបស់ដៃគូអភិវឌ្ឍន៍ ឆ្លើយតបទៅនឹងតម្រូវនិងសភាពការជាក់ស្តែងរបស់កម្ពុជា។ ជាមួយគ្នានេះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ក៏បានស្នើ និងលើកទឹកចិត្តឲ្យមន្ត្រីរាជការគ្រប់ក្រសួង-ស្ថាប័ន ទាំងអស់បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕■

*រៀបចំដោយ÷ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព នៃអ.គ.ហ.*



កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩

# សិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្ដុះបណ្ដាលស្ដីពី "ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ"

*កាលពីថ្ងៃទី១៩ ដល់ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩, នៅសណ្ឋាគារសុខាភ្នំពេញ,អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) សហការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund-IMF) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្ដុះបណ្ដាលស្ដីពី "ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability-PEFA) ។*

កម្មវិធីសិក្ខាសាលា ប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងជាអគ្គលេខាធិការនៃ **អ.គ.ហ.** តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ដោយមាន ការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន, តំណាង អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត, តំណាងអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធ និងតំ-ណាង IMF។ គោលបំណងនៃការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្ដុះបណ្ដាល ស្ដីពីក្របខ័ណ្ឌវាយតម្លៃ PEFA គឺដើម្បីបញ្ជ្រាបការយល់ដឹងអំពីឧត្តមានុវត្តន៍អន្តរជាតិលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាដើម្បីពង្រឹងសមត្ថភាពក្រុមការងារវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិដែលរដ្ឋបាលរាជធានីភ្នំពេញ ត្រូវបានជ្រើសរើសសម្រាប់ការវាយតម្លៃសាកល្បង។

### ❖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពីក្របខ័ណ្ឌវាយតម្លៃ PEFA

ក្នុងកម្មវិធីបើកសិក្ខាសាលាផ្សព្វផ្សាយ, ឯកឧត្តម **រស់ សីលវ៉ា** បានលើកឡើងថា ក្របខ័ណ្ឌ PEFA គឺជា ឧបករណ៍វាស់ស្ទង់សុខភាពប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាង ១៥០ ប្រទេស លើសកលលោក។ លទ្ធផលវាយតម្លៃ PEFA គឺជាមូលដ្ឋានដ៏មានសារៈសំខាន់សម្រាប់រៀបចំផែនការសកម្មភាពរួម និងកំណត់ទិសដៅអាទិភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្អែកលើលទ្ធផលវាយតម្លៃ



*ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃ **អ.គ.ហ.** ក្នុងកម្មវិធីសិក្ខាសលានិងវគ្គបណ្ដុះបណ្ដាលស្ដីពី ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ*



*សកម្មភាពបណ្តុះបណ្តាលស្តីពី ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ*

PEFA ចំនួន ២លើក ដែលលើកទី១ ក្នុងឆ្នាំ២០១០ និងលើកទី២ ក្នុងឆ្នាំ២០១៥ បានឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេលជាង ១៥ឆ្នាំ កន្លងទៅ ។ សម្រាប់ឆ្នាំ ២០១៩ និងឆ្នាំ២០២០ រាជរដ្ឋាភិបាលសហការជាមួយដៃគូអភិវឌ្ឍន៍ នឹងធ្វើការវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំផែនការសកម្មភាពរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ ២០២១-២០២៥។

ទន្ទឹមនេះ លោក JOSHI Suhas ទីប្រឹក្សាក្នុងតំបន់នៃ IMF បានលើកឡើងថាការវាយតម្លៃ PEFA គឺពិតជា មានសារៈសំខាន់ខ្លាំងណាស់ក្នុងការពិនិត្យភាពខ្លាំង និងភាពខ្សោយ នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចដែលរាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានវាយតម្លៃចំនួន ២ លើក រួចមកហើយ។ លោក JOSHI Suhas ក៏បានបញ្ជាក់បន្ថែមថា ការវាយម្លៃ PEFA ឆ្នាំ ២០១៥ដោយក្រុមការងាររបស់រាជរដ្ឋាភិបាលគឺប្រកាន់យកអភិក្រម “*ក្រុមការងារវាយតម្លៃរបស់រាជរដ្ឋាភិបាល ជាអ្នករៀបចំរបាយការណ៍ រីឯទីប្រឹក្សាអន្តរជាតិ ជាអ្នកត្រួតពិនិត្យគុណភាព និងផ្តល់យោបល់ដើម្បីកែសម្រួលរបាយការណ៍ឱ្យមានភាពគ្រប់ជ្រុងជ្រោយស្របតាមស្តង់ដារ PEFA*” ។ ការអនុវត្តអភិក្រមនេះ បានបង្ហាញអំពីភាពជាម្ចាស់, ភាពជាអ្នកដឹកនាំ និងឆន្ទៈលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ។

❖ **វគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌវាយតម្លៃ** PEFA

វគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌវាយម្លៃ PEFA ត្រូវបានរៀបចំឡើងនៅថ្ងៃទី ២០ ដល់ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០១៩ បន្ទាប់ពីសិក្ខាសាលាផ្សព្វផ្សាយ ក្នុងគោលបំណងពង្រឹងសមត្ថភាពក្រុមការងារវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ ដែលបានចាប់ផ្តើមវាយតម្លៃពីខែមិថុនា ដល់ខែធ្នូ ឆ្នាំ២០១៩ ។ ក្របខណ្ឌ PEFA ផ្តោតលើលទ្ធផលចុងក្រោយចំនួន ៣ (វិន័យថវិកា, យុទ្ធសាស្ត្រវិភាជន៍ថវិកា និងប្រសិទ្ធភាពផ្តល់សេវាសាធារណៈ) និងមានរចនាសម្ព័ន្ធ ជាអាទិ៍ សសរស្តម្ភចំនួន ០៧ , សូចនាករសមិទ្ធកម្មចំនួន ៣១ និងសមាសធាតុចំនួន ៩៤ សម្រាប់ក្របខ័ណ្ឌថ្នាក់ជាតិ។ រីឯ សម្រាប់ក្របខណ្ឌថ្នាក់ក្រោមជាតិ គឺដូច

**PEFA Framework**

| 7 | 31 | 94 |
|---|---|---|
| Pillars | Indicators | Dimensions |

*សម្រាប់ការអនុវត្តសកម្មភាព នៃការងារកែទម្រង់ទាំងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាក្របខណ្ឌក្រសួង-ស្ថាប័ន កំពុងមានវឌ្ឍនភាពល្អប្រសើរ ដែលត្រូវបានរំពឹងទុកថាអាចសម្រេចបាន គោលដៅប្រចាំឆ្នាំ ។*

នឹងសូចនាករថ្នាក់ជាតិដែរ ប៉ុន្តែបន្ថែមមួយសូចនាករ “ភាពប៉ាន់ប្រមាណ អំពីការផ្ទេរធនធានពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ” និងសមាសធាតុចំនួន ៣ រួមមាន (ទី១). គម្លាតថវិកាប្រចាំឆ្នាំរវាងការផ្ទេរថវិកាសរុបជាក់-ស្តែងពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ, (ទី២). គម្លាតប្រចាំឆ្នាំរវាងការផ្ទេរធនធានហិរញ្ញវត្ថុជាក់ស្តែង និងធនធានហិរញ្ញវត្ថុក្នុងច្បាប់ថវិកា, និង( ៣). ភាពទាន់ពេលវេលានៃ ការផ្ទេរថវិកាក្នុងឆ្នាំពីថ្នាក់ជាតិ។

ក្នុងវគ្គបណ្តុះបណ្តាលនេះអង្គសិក្ខាកាមបានផ្តោតការពិភាក្សាលើចំណុចគន្លឹះៗ រួមមាន÷ (ទី១). ទស្សនាទាន និងសារៈ-សំខាន់ នៃការប្រើប្រាស់ក្របខណ្ឌ PEFA ក្នុងការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ-សាធារណៈ, (ទី២). កិច្ចដំណើរការ និងវិធីសាស្ត្រវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, (ទី៣). ភាពខុសគ្នារវាងក្របខណ្ឌ PEFA ឆ្នាំ២០១១ និងក្របខណ្ឌ PEFA ឆ្នាំ២០១៦, ទី៤). កំណត់ភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា តាមរយៈរបាយការណ៍ PEFA ឆ្នាំ២០១៥ និង(ទី៥). ការប្រើប្រាស់ឧបករណ៍ PEFA ដើម្បីរៀបចំក្របខណ្ឌផែនការសកម្មភាពរួមសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជារួម ខណៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ហៀបនឹងបិទបញ្ចប់នៅឆ្នាំ២០២០ និងឈានទៅអនុវត្តនូវដំណាក់កាលទី ៤ នាពេលដ៏ខ្លីខាងមុខនេះ, ការរៀបចំនូវបុរេលក្ខណៈ មួយចំនួនគឺពិតជាមិនអាចខ្វះបាន ជាពិសេសការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ លទ្ធផលនៃការប្រើប្រាស់ក្របខណ្ឌ PEFA ក្នុងការពិនិត្យសុខភាពប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា នឹងផ្តល់ជាមូលដ្ឋានឬធាតុចូលដ៏មានសារៈសំខាន់បន្ថែមទៀតសម្រាប់ ជាទិសដៅកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា ៕■

*រៀបចំដោយ÷ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃអ. គ. ហ.*

## PEFA 2016 performance indicators

—BUDGET RELIABILITY—
PI-1. Aggregate expenditure outturn
PI-2. Expenditure composition outturn
PI-3. Revenue outturn

—TRANSPARENCY OF PUBLIC FINANCES—
PI-4. Budget classification
PI-5. Budget documentation
PI-6. Central government operations outside financial reports
PI-7. Transfers to subnational governments
PI-8. Performance information for service delivery
PI-9. Public access to fiscal information

—MANAGEMENT OF ASSETS AND LIABILITIES—
PI-10. Fiscal risk reporting
PI-11. Public investment management
PI-12. Public asset management
PI-13. Debt management

—POLICY-BASED FISCAL STRATEGY AND BUDGETING—
PI-14. Macroeconomic and fiscal forecasting
PI-15. Fiscal strategy
PI-16. Medium-term perspective in expenditure budgeting
PI-17. Budget preparation process
PI-18. Legislative scrutiny of budgets

—PREDICTABILITY AND CONTROL IN BUDGET EXECUTION—
PI-19. Revenue administration
PI-20. Accounting for revenue
PI-21. Predictability of in-year resource allocation
PI-22. Expenditure arrears
PI-23. Payroll controls
PI-24. Procurement
PI-25. Internal controls on nonsalary expenditure
PI-26. Internal audit

—ACCOUNTING AND REPORTING—
PI-27. Financial data integrity
PI-28. In-year budget reports
PI-29. Annual financial reports

—EXTERNAL SCRUTINY AND AUDIT—
PI-30. External audit
PI-31. Legislative scrutiny of audit reports

# សិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃរាជរដ្ឋាភិបាលកម្ពុជា"

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយប្រមុខរាជរដ្ឋាភិបាល កាលពីចុងឆ្នាំ ២០០៤ កន្លងទៅ មានគោលបំណងកែប្រែជាជំហានៗ នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ឧត្តមានុវត្តន៍អន្តរជាតិ ដោយប្រកាន់យកអភិក្រមជាខឿន និងបែងចែកជា ៤ ដំណាក់កាល ។*

ក្នុងទិសដៅនេះ ដើម្បីសម្រេចបានគោលដៅដែលមានរយៈពេលវែងប្រកបដោយមហិច្ឆិតានៅឆ្នាំ២០២៥, រាជរដ្ឋាភិបាលចាំបាច់ត្រូវដាក់ចេញ និងអនុវត្តយុទ្ធសាស្ត្រពាក់ព័ន្ធ ដោយម៉ឺងម៉ាត់ ទន់ភ្លន់ និងក្នុងជំហានប្រុងប្រយ័ត្នបំផុត។ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**អ.គ.ហ.**) ដែលជាសេនាធិការក្នុងភារកិច្ចសម្របសម្រួលការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, បានផ្ដួចផ្ដើមបង្កើត ឱ្យមានការផ្សព្វផ្សាយជាទម្រង់ផ្សេងៗ និងឧបករណ៍ផ្សព្វផ្សាយនានាក្នុងគោលដៅគាំទ្រទិសដៅ និងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ **អ.គ.ហ.** បានដាក់ចេញនូវផែនការផ្សព្វផ្សាយជាប្រចាំឆ្នាំ រួមទាំងការផ្សព្វផ្សាយជាទម្រង់សិក្ខាសាលា ការផ្សព្វផ្សាយតាមបណ្ដាញសង្គម និងការផលិតឧបករណ៍ផ្សព្វផ្សាយដូចជាវីដេអូ និងព្រឹត្តិបត្រជាដើម ។

ផ្អែកតាមស្មារតីនេះសម្រាប់ការផ្សព្វផ្សាយឆ្នាំ២០១៩ អត្ថបទនេះ នឹងរំលេចតែព្រឹត្តិការណ៍ នៃការផ្សព្វផ្សាយជាទម្រង់សិក្ខាសាលាចំនួន ៥ រួមមាន÷ សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃរាជរដ្ឋាភិបាលកម្ពុជា*" នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្ដាល, សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារសាខាខេត្តកំពង់ចាម, វិទ្យាស្ថានគរុកោសល្យបាត់ដំបង ខេត្តបាត់ដំបង, សាកលវិទ្យាល័យមានជ័យ ខេត្តបន្ទាយមានជ័យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង។ សិក្ខាសាលាផ្សព្វផ្សាយចំនួន ៥ គោលដៅខាងលើនេះ គឺក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង បង្កើនការចូលរួម និងបញ្ជ្រាបពុទ្ធិអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាជូនសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ គរុសិស្ស និងសិស្ស-និស្សិត ជាពិសេសក្នុងគោលដៅឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែង និងឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសជាតិ។


*សិក្ខាសាលាផ្សព្វផ្សាយស្ដីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្ដាល*

## ❖ សិក្ខាសាលាផ្សព្វផ្សាយនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្ដាល

សិក្ខាសាលាផ្សព្វផ្សាយនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្ដាល ត្រូវបានរៀបចំឡើងនាថ្ងៃ ទី០៨ ខែតុលា ឆ្នាំ ២០១៩ ក្រោមអធិបតីភាពឯកឧត្តម **យ៉េត វីណែល** អគ្គលេខាធិការរង នៃ **អ.គ.ហ.** តំណាងឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការ នៃ **អ.គ.ហ.** និងឯកឧត្តម **នូវប៉េង ច័ន្ទតារា** អភិបាលរង តំណាងអភិបាល នៃគណៈអភិបាលខេត្តកណ្ដាល ព្រមទាំងមានការចូលរួមពីលោកស្រីប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកណ្ដាល, តំណាងអគ្គនាយកដ្ឋានពន្ធដារ, នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្ដាល និងលោកគ្រូ អ្នកគ្រូ គរុសិស្សសរុបប្រមាណជា ៥៥០ នាក់ ។



សិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង

### ❖ សិក្ខាសាលាផ្សព្វផ្សាយនៅសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារសាខាខេត្តកំពង់ចាម

សិក្ខាសាលាផ្សព្វផ្សាយនៅសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារសាខាខេត្តកំពង់ចាម ត្រូវបានរៀបចំឡើងនាថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៩ ក្រោមអធិបតីភាពឯកឧត្តម **យ៉េត វីណែល** និងលោក **ត្រុយ ខន** នាយកទីចាត់ការហិរញ្ញវត្ថុ សាលាខេត្តកំពង់ចាម តំណាងឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម និងមានការចូលរួមពីលោកស្រី ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកំពង់ចាម, តំណាងអគ្គនាយកដ្ឋានពន្ធដារ, សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យ ជា ស៊ីមកំចាយមារសាខាខេត្តកំពង់ចាម ព្រមទាំងសាស្ត្រាចារ្យ សិស្ស-និស្សិត សរុបប្រមាណជា ២០០ នាក់ ។

### ❖ សិក្ខាសាលាផ្សព្វផ្សាយនៅសាកលវិទ្យាល័យមានជ័យខេត្តបន្ទាយមានជ័យ

សិក្ខាសាលាផ្សព្វផ្សាយនៅសាកលវិទ្យាល័យមានជ័យ ត្រូវបានរៀបចំឡើងនាថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តម **យ៉េត វីណែល** និង ឯកឧត្តម **ង៉ោ ម៉េងជ្រួន** អភិបាលរង តំណាងអភិបាលនៃគណៈអភិបាល ខេត្តបន្ទាយមានជ័យ, ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យមានជ័យ, លោកប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ, តំណាងអគ្គនាយកដ្ឋានពន្ធដារ, ព្រមទាំងសាស្ត្រាចារ្យ និស្សិត សរុបប្រមាណជា២៥០ នាក់។

### ❖ សិក្ខាសាលាផ្សព្វផ្សាយនៅ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង

សិក្ខាសាលាផ្សព្វផ្សាយនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ត្រូវបានរៀបចំឡើងនាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តម **យ៉េត វីណែល** និងឯកឧត្តម **ចាន់ វ៉ាន់** អភិបាលរង តំណាងអភិបាល នៃគណៈអភិបាលខេត្តព្រៃវែង និងមានការចូលរួមពីលោកប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រៃវែង, តំណាងអគ្គនាយកដ្ឋាន ពន្ធដារ, លោកនាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តព្រៃវែង ព្រមទាំងលោកគ្រូ អ្នកគ្រូ គរុសិស្ស សរុបប្រមាណជា ២០០ នាក់ ។

ថ្លែងក្នុងសុន្ទរកថាបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី “ ***កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃរាជរដ្ឋាភិបាលកម្ពុជា***” ទាំង ៥ គោលដៅ, ឯកឧត្តម **យ៉េត វីណែល** បានលើកឡើងអំពីសាវតារ



សិក្ខាសាលាផ្សព្វផ្សាយនៅសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ខេត្តកំពង់ចាម

*សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ គរុសិស្ស និងសិស្ស-និស្សិតចំនួនប្រមាណ ១៦០០ នាក់ បន្ថែមទៀត បានទទួលការយល់ដឹង និងជ្រួតជ្រាបអំពីភាពចាំបាច់ និងសារៈសំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ។*

សារៈសំខាន់ និងទិសដៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ ហិរញ្ញវត្ថុ នឹងត្រូវធ្វើវិមជ្ឈការទៅក្រសួង-ស្ថាប័ន ហើយពីក្រសួង-ស្ថាប័ន ទៅអង្គភាពផ្តល់សេវាសាធារណៈ ក្នុងគោល



សិក្ខាសាលាផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅសាកលវិទ្យាល័យមានជ័យ ខេត្តបន្ទាយមានជ័យ

ដៅជំរុញការផ្តល់សេវាសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងកាន់តែកៀតជិតប្រជាពលរដ្ឋនៅមូលដ្ឋាន។ បន្ថែមពីនេះ ឯកឧត្តមបានលើកទឹកចិត្តឱ្យសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ គរុសិស្ស និងសិស្ស-និស្សិត ចូលរួមឱ្យបានសកម្មក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយ ដោយយកចិត្តទុកដាក់ និងចោទជាសំណួរពាក់ព័ន្ធផ្សេងៗ ក្នុងន័យធ្វើឱ្យសិក្ខាសាលាផ្សព្វផ្សាយ ទទួលបានលទ្ធផល និងផ្លែផ្កា គួរជាទីមោទនៈ ។

ទន្ទឹមនេះ តំណាងអភិបាល នៃគណៈអភិបាលខេត្ត បានគូសបញ្ជាក់ស្រដៀងគ្នាថា លទ្ធផលដែលកម្ពុជា សម្រេចបានកំណើនជាមធ្យមរង្វង់ ៧% ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងត្រូវបានទទួលស្គាល់ជា “ខ្លាសេដ្ឋកិច្ចថ្មីមួយក្នុងតំបន់អាស៊ី” នៅឆ្នាំ២០១៦ គឺមិនអាចកាត់ផ្តាច់ចេញពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃ រាជរដ្ឋាភិបាលកម្ពុជា បាននោះទេ ដែលលទ្ធផលនៃការកែទម្រង់ បានបញ្ចប់ស្ថានភាពកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ និងធ្វើឱ្យចំណូល ថវិកាជាតិមានការកើនឡើងជាលំដាប់ ហើយជីវភាពរស់នៅរបស់មន្ត្រីរាជការ, កងកម្លាំងប្រដាប់អាវុធ, និវត្តជន, អ្នកបាត់បង់សម្បទាវិជ្ជាជីវៈ និងអតីតយុទ្ធជន មន្ត្រីជាប់កិច្ចសន្យា សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ មានភាពប្រសើរឡើងតាមរយៈការដំឡើងបៀវត្សជាបន្តបន្ទាប់។ ដោយឡែក ប្រធាន ឬនាយកគ្រឹះស្ថានអប់រំ មានការចាប់អារម្មណ៍ខ្លាំងទៅលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈមតិស្វាគមន៍ ក្នុងកម្មវិធីបើកសិក្ខាសាលាផ្សព្វផ្សាយ។

ជារួម សិក្ខាសាលាផ្សព្វផ្សាយស្តីពី “***កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃរាជរដ្ឋាភិបាលកម្ពុជា***” នៅគោលដៅចំនួន ៥ ខាងលើ បានបង្ហាញឱ្យឃើញអំពីកិច្ចខិតខំប្រឹងប្រែង និងឆន្ទៈមោះមុត របស់រាជរដ្ឋាភិបាល ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាការសន្និដ្ឋាន សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ គរុសិស្ស និងសិស្ស-និស្សិតចំនួនប្រមាណ ១៦០០ នាក់ បន្ថែមទៀត បានទទួលការយល់ដឹង និងជ្រួតជ្រាបអំពីភាពចាំបាច់ និងសារៈសំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ៕■

*រៀបចំដោយ÷ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃអ.គ.ហ.*

# កម្មវិធីទស្សនកិច្ចផ្លាស់ប្តូរចំណេះដឹងស្តីពីការកែទម្រង់វិស័យសាធារណៈ និងការគ្រប់គ្រងការផ្លាស់ប្តូរនៅប្រទេសអូស្ត្រាលី

*នៅថ្ងៃទី៨ ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩ កន្លងទៅ, ដោយទទួលបានការគាំទ្រសម្របសម្រួលរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងពាណិជ្ជកម្ម (Department of Foreign Affairs and Trade-DFAT) នៃរដ្ឋាភិបាលអូស្ត្រាលីប្រចាំនៅកម្ពុជា និងធនាគារពិភពលោក, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានដឹកនាំដំណើរទស្សនកិច្ចសិក្សាស្តីពីការកែទម្រង់វិស័យសាធារណៈ និងការគ្រប់គ្រងការផ្លាស់ប្តូរ នៅប្រទេសអូស្ត្រាលី ។*

កម្មវិធីនេះមានរយៈពេល ៤ ថ្ងៃ នៅរដ្ឋធានីកង់បេរ៉ា និងទីក្រុងស៊ីដនី នៃប្រទេសអូស្ត្រាលី ដែលដឹកនាំដោយឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការ នៃ **អ.គ.ហ.** អមដោយថ្នាក់ដឹកនាំ និងមន្ត្រីនៃ **អ.គ.ហ.** មួយចំនួនទៀតព្រមទាំងមានការអញ្ជើញចូលរួមពីតំណាងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មួយចំនួន រួមមានតំណាងអគ្គនាយកដ្ឋានថវិកា ចំនួន ០១ រូប, តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ចំនួន ០១ រូប, តំណាងក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យា FMIS ចំនួន ០១ រូប, និងគណៈប្រតិភូ នៃក្រសួងមុខងារសាធារណៈ ចំនួន ០៣ រូប និងមានការចូលរួម និងផ្តល់ការសម្រួលដោយ តំណាង DFAT និងតំណាងធនាគារពិភពលោកផងដែរ ដែលសរុបទាំងអស់ចំនួន ១៣ រូប។

ក្រោមកិច្ចស្វាគមន៍យ៉ាងកក់ក្តៅប្រកបដោយភាពសហប្រតិបត្តិការល្អរបស់តំណាងរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី, គណៈប្រតិភូនៃរាជរដ្ឋាភិបាលកម្ពុជា បានទទួលការអនុញ្ញាតឱ្យជួបជាមួយនឹងស្ថាប័នចំនួន ៦ ដើម្បីសិក្សាស្វែងយល់ និងចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងការផ្តល់សេវាសាធារណៈ ដែលរួមមាន ក្រសួងហិរញ្ញវត្ថុ (Department of Finance), ក្រសួងរតនាគារ (Department of Treasury), គណៈកម្មការសេវាសាធារណៈអូស្ត្រាលី, ក្រសួងអប់រំ (NSW Department of Education), ក្រសួងសុខាភិបាល (NSW Department of Health), និងមជ្ឈមណ្ឌល

*គោលនយោបាយហិរញ្ញវត្ថុពាក់កណ្តាលឆ្នាំ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺផ្តោតលើការពង្រឹងគុណភាពចំណាយវិនិយោគ, ប្រសិទ្ធភាពនៃការអនុវត្តចំណាយដើម្បីលើកកម្ពស់ការវិនិយោគឯកជន, បង្កើនការងារ និងកំណើនសេដ្ឋកិច្ច, បង្កើនការប្រមូលចំណូល និងពង្រឹងប្រសិទ្ធភាពទ្រព្យសកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ ។*



*រូបភាពនៅក្រសួងហិរញ្ញវត្ថុ នៃប្រទេស អូស្ត្រាលី (Department of Finance)*

សេវាវីនយ៉ាដញ្ញូសៅវេល (Wynyard Service New South wales Center)។

តាមរយៈដំណើរទស្សនកិច្ចសិក្សាដែលមានរយៈពេល ៤ ថ្ងៃនេះ, គណៈប្រតិភូបានទទួលនូវការចែករំលែកនូវបទពិសោធន៍ និងចំណេះដឹងថ្មីៗដែលមានសារៈប្រយោជន៍ជាធាតុចូលបន្ថែមសម្រាប់ការពង្រឹងលើប្រសិទ្ធភាពការងារជាពិសេសការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់មុខងារសាធារណៈពាក់ព័ន្ធលើចំណុចរួមមាន ការកែទម្រង់ និងការគ្រប់គ្រងថវិកា, ការគ្រប់គ្រងចំណូល និងម៉ាក្រូសេដ្ឋកិច្ច, អភិបាលកិច្ចសាធារណៈ, សមិទ្ធកម្មនិងគណនេយ្យភាព, ការគ្រប់គ្រងនិងការផ្ដល់សេវាសាធារណៈ, ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និងការគ្រប់គ្រងធនធានមនុស្ស ជាដើម។


*រូបភាពនៅក្រសួងហិរញ្ញវត្ថុ នៃប្រទេស អូស្ត្រាលី (Department of Finance) ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩*

ក្រោយទទួលបាននូវការចែករំលែក និងការបង្ហាញនូវការអនុវត្តជាក់ស្ដែង ប្រកបដោយភាពរីករាយ ជាមួយនឹងការស្វាគមន៍យ៉ាងកក់ក្ដៅ របស់ស្ថាប័នពាក់ព័ន្ធ របស់រដ្ឋាភិបាលអូស្ត្រាលី,ទស្សនកិច្ចសិក្សានេះបានផ្ដល់នូវផ្លែផ្កា និងធាតុចូលល្អៗ ជាច្រើនសម្រាប់ពិចារណាក្នុងការចូលរួមកែលម្អ និងអភិវឌ្ឍន៍ លើការងារកែទម្រង់ទាំងពីររបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ជាពិសេសការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម÷

### ១. បទពិសោធន៍ នៃការកែទម្រង់សេដ្ឋកិច្ច (Economic Reform)

រដ្ឋាភិបាលអូស្ត្រាលី បានរៀបចំធ្វើការកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចទៅតាមបីដំណាក់កាល ដែលដំណាក់កាលនីមួយៗ ត្រូវបានកំណត់គោលដៅ និងសម្រេចបានលទ្ធផលដូចខាងក្រោម÷

- ជំហានទី១ (First Wave Reform) ពីឆ្នាំ ១៩៧០-១៩៨០ “*ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច*”។ ក្នុងដំណាក់កាលនេះ, រដ្ឋាភិបាលអូស្ត្រាលី ផ្ដោតលើវិស័យហិរញ្ញវត្ថុ និងធនាគារ ដោយបានធ្វើការកែទម្រង់ជោគជ័យលើទីផ្សាររូបិយប័ណ្ណប្រាក់ដុល្លារអូស្ត្រាលីក្នុងការទប់ស្កាត់នូវបម្រែបម្រួលបានយ៉ាងប្រសើរ, ការដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រធនាគារបំរុង (Reserve Bank of Australia Strategy) និងសន្និសញ្ញាដើម្បីទប់ស្កាត់ នៃការឡើងប្រាក់បៀវត្ស និងជំរុញកំណើនសេដ្ឋកិច្ច។
- ជំហានទី២ (Second Wave Reform) ពីឆ្នាំ ១៩៨០-១៩៩០ “កែទម្រង់មីក្រូសេដ្ឋកិច្ចនិងផលិតភាព”។ ក្នុងដំណាក់កាលនេះ ផ្ដោតលើការកាត់បន្ថយអត្រាពន្ធដើម្បីបង្កើនទីផ្សារប្រកួតប្រជែង និងវិមជ្ឈការប្រព័ន្ធទំនាក់ទំនងឧស្សាហកម្ម (Decentralized industrial relations system) ដើម្បីរៀបចំកំណត់នូវអត្ថប្រយោជន៍ទាបបំផុតដែលកម្មករអាចទទួលបាន និងអនុញ្ញាតឱ្យសហជីពមានសិទ្ធិក្នុងការចចារលើការបង្កើនប្រាក់បៀវត្សសម្រាប់ជាអត្ថប្រយោជន៍របស់កម្មករផ្សារភ្ជាប់ជាមួយនឹងផលិតភាពការងារ។

*ការរៀបចំតាមដានសមិទ្ធកម្មការងាររបស់អង្គភាពនីមួយៗ ត្រូវបានធ្វើឡើងតាមរយៈ Performance Agreement ។*

- ជំហានទី៣ (Third Wave Reform) ពីឆ្នាំ ១៩៩០ រហូតមកដល់បច្ចុប្បន្ន “ការកែទម្រង់ថវិកា និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច”។ក្នុងដំណាក់កាលនេះផ្ដោតលើគោលនយោបាយរូបិយវត្ថុ, គោលនយោបាយហិរញ្ញវត្ថុ, វិធានការពង្រឹងចំណូលនិងចំណាយ, និងការដាក់ឱ្យអនុវត្តនូវច្បាប់ថវិកា (Charter of Budget Honesty Act)។ ច្បាប់ថវិការបស់អូស្ត្រាលីបានដាក់ទទួលការអនុម័តនៅឆ្នាំ ១៩៩៨ ដោយមានកម្មវត្ថុគន្លឹះ គឺក្របខណ្ឌរៀបចំគោលនយោបាយហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលផ្ដោតជាពិសេសលើ ការព្យាករណ៍, របាយការណ៍ពាក់កណ្ដាលឆ្នាំ, របាយការណ៍សម្រាប់ការត្រៀមការបោះឆ្នោត (Pre election update) និងយុទ្ធសាស្ត្រថវិការយៈពេលមធ្យម។

ជារួម, រដ្ឋាភិបាលអូស្ត្រាលី អនុវត្តកម្មវិធីកែទម្រង់តាមអភិក្រម Big Bang។ ការកែទម្រង់នេះ បានធ្វើឱ្យរដ្ឋាភិបាលអូស្ត្រាលី មានភាពរឹងមាំក្នុងការឆ្លងកាត់បាននូវព្យុះភ្លៀង នៃវិបត្តិហិរញ្ញវត្ថុអាស៊ី

ក្នុងកំឡុងឆ្នាំ ១៩៩៧ និងវិបត្តិសេដ្ឋកិច្ចសកល ក្នុងឆ្នាំ២០០៨ ដោយជោគជ័យ។ ឆន្ទៈមុតមាំ និងការមិនបោះបង់ចោលលើការកែទម្រង់ របស់អ្នកកែទម្រង់មិនថាជួបប្រទះនូវភាពឈឺចាប់ក្នុងដំណាក់កាលនីមួយៗគឺជាកត្តាកំណត់ជោគជ័យលើការកែទម្រង់របស់អូស្ត្រាលី, ដែលកិច្ចការនេះបានផ្តោតលើការផ្លាស់ប្តូរដោយមានការគាំទ្រពីវិស័យឯកជន និងសហជីពកម្មករក៏ដូចជាស្ថាប័នរដ្ឋ។



រូបភាពនៅក្រសួងហិរញ្ញវត្ថុ នៃប្រទេស អូស្ត្រាលី (Department of Finance) ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩

## ២. ការចែករំលែកបទពិសោធពីក្រសួងហិរញ្ញវត្ថុ

ក្នុងកិច្ចដំណើរការនៃវដ្តថវិកា, ក្រសួងហិរញ្ញវត្ថុអូស្ត្រាលី ជាអ្នករៀបចំនូវគោល-នយោបាយហិរញ្ញវត្ថុពាក់កណ្តាលឆ្នាំ និងពិនិត្យលើគ្រប់សំណើចំណាយ និងគម្រោងចំណូលមិនមែនពន្ធ, រីឯក្រសួងរតនាគារពិនិត្យតែលើគម្រោងចំណូលពន្ធតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ ក្នុងដំណើរការរៀបចំថវិកាមានគណៈកម្មការពិនិត្យការចំណាយ (Expenditure Review Committee-ERC) ដែលសមាសភាពរួមមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងប្រធានរតនាគារ សម្រាប់ពិនិត្យទៅលើសំណើចំណាយ ចំណូល។ ការយល់ព្រមរបស់ ERC ផ្អែកលើការផ្តល់យោបល់របស់នាយកដ្ឋានហិរញ្ញវត្ថុ (Department of Finance) តាមរយៈ Green Brief។ គោលនយោបាយហិរញ្ញវត្ថុពាក់កណ្តាលឆ្នាំ ដែលរៀបចំដោយក្រសួងហិរញ្ញវត្ថុ គឺផ្តោតលើការពង្រឹងគុណភាពចំណាយវិនិ-យោគ, ប្រសិទ្ធភាពនៃការអនុវត្តចំណាយដើម្បីលើកកម្ពស់ការវិនិយោគឯកជន , បង្កើនការងារ និងកំណើនសេដ្ឋកិច្ច, បង្កើនការប្រមូលចំណូល និងពង្រឹងប្រសិទ្ធភាពទ្រព្យសកម្មនៃរបាយការណ៍ហិរញ្ញវត្ថុ។

*ការគ្រប់គ្រងតាមបែបប្រព័ន្ធព័ត៌មាន-វិទ្យា÷* ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួងហិរញ្ញវត្ថុអូស្ត្រាលី បានរៀបចំប្រព័ន្ធគ្រប់គ្រងថវិកា (Central Budget Management System- CBMS) ដើម្បីបង្កើនប្រសិទ្ធភាព នៃការធ្វើការសម្រេចចិត្តតាមក្រោយ (Post decision) , របាយការណ៍ហិរញ្ញវត្ថុ, និងរបាយការណ៍ថវិកាប្រចាំឆ្នាំ។ ប្រព័ន្ធនេះផ្តល់ប្រយោជន៍ដូចជា សម្រួលដល់ការធ្វើការសម្រេចចិត្ត, ភាពអាចប៉ាន់ប្រមាណបានលើកញ្ចប់ថវិកាប្រចាំឆ្នាំ, ឯកសារថវិកា, គម្រោងថវិកា និងការអនុវត្តប្រចាំខែ និងប្រចាំឆ្នាំ, ការគ្រប់គ្រងសាច់ប្រាក់, និងរបាយការណ៍។ ទន្ទឹមនេះ, ក្រសួងស្ថាប័នដទៃបានអនុញ្ញាតឱ្យរៀបចំប្រព័ន្ធ FMIS ដោយឡែក សម្រាប់គ្រប់គ្រងចំណាយប្រចាំថ្ងៃរបស់ខ្លួនដូចជាការបើកប្រាក់បៀវត្ស និងទូទាត់វិក័យបត្រជាដើម។ ប៉ុន្តែប្រព័ន្ធFMIS នេះ ត្រូវធ្វើសន្ធានកម្មជាមួយនឹងប្រព័ន្ធ CBMS របស់ក្រសួងហិរញ្ញវត្ថុ។ ក្រសួងហិរញ្ញវត្ថុ ក៏កំពុងរៀបចំប្រព័ន្ធថ្មីមួយទៀត ដើម្បីធ្វើស្វ័យប្រវត្តិកម្ម Pre-decision ដែលហៅថា Shared Budget Workflow System (SBWS)។ ប្រព័ន្ធនេះអាចផ្តល់នូវព័ត៌មានបន្ថែមសម្រាប់ដំណាក់កាល នៃការរៀបចំ និងការចចារថវិកា។

## ៣. ការចែករំលែកបទពិសោធន៍ របស់ក្រសួងរតនាគារជាតិ

ក្រសួងរតនាគារអូស្ត្រាលី មានកម្មវិធីគោលនយោបាយ៤ គឺ ធានាប្រសិទ្ធភាពនៃការអនុវត្តចំណាយ និងការគ្រប់គ្រងចំណូលពន្ធ, ធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច, ធានាដំណើរការទីផ្សារ, និងធានាប្រសិទ្ធ-


រូបភាពនៅក្រសួងរតនាគារជាតិ (Department of Treasury) នៃប្រទេសអូស្ត្រាលី នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩



*រូបភាពនៅក្រសួងអប់រំ នៃប្រទេស អូស្ត្រាលី (NSW Department of Education) ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៩*

ភាព នៃការគ្រប់គ្រងប្រាក់ចូលនិវត្តន៍ ។ ក្រសួងរតនាគាររបស់អូស្ត្រាលី គ្រប់គ្រងលើការអនុវត្តថវិកា ដែលអនុលោមតាមច្បាប់ Government Sector Finance Act របស់រដ្ឋញូសៅវេល ។ ជាការកត់សម្គាល់, ពន្ធលើទំនិញនិងសេវា ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងកំឡុងទសវត្សរ៍ ៨០-៩០ ប៉ុន្តែបរាជ័យ។ នៅឆ្នាំ២០០០, រដ្ឋាភិបាលអូស្ត្រាលី បានពង្រឹងការងារកែទម្រង់ដោយពង្រឹងមូលដ្ឋានពន្ធ និងកាត់បន្ថយពន្ធលើប្រាក់ចំណេញ រួមទាំងដាក់ឱ្យអនុវត្តជាថ្មីនូវពន្ធលើទំនិញ និងសេវាកម្ម (Goods & Services Tax-"GST") ដោយកំណត់អត្រា ១០ ភាគរយ។

### ៤. បទពិសោធន៍ពីក្រសួងអប់រំ និងក្រសួងសុខាភិបាល

តាមរយៈការចែករំលែកបទពិសោធន៍របស់ក្រសួងអប់រំ និងក្រសួងសុខាភិបាល

*អូស្ត្រាលីបានរៀបចំយុទ្ធសាស្ត្រធនធានមនុស្ស ដោយមានប្រព័ន្ធទិន្នន័យការងារច្បាស់លាស់ និងប្រើវិធីសាស្ត្រ ៧០:២០:១០ ដើម្បីពង្រឹងសមត្ថភាពមន្ត្រី*

អូស្ត្រាលី, ការអនុវត្តថវិកា ត្រូវអនុលោមតាមច្បាប់ Government Sector Finance Act របស់រដ្ឋញូសៅវេលដែលគ្រប់គ្រងដោយក្រសួងរតនាគារ ។ ច្បាប់ Government Sector Finance Act ផ្តោតទៅលើនីតិវិធីនៃការទទួលបានថវិកា រដ្ឋ និងការអនុវត្តថវិកា។ ជាការកត់សម្គាល់, តាមរយៈប្រព័ន្ធថវិកាសមិទ្ធកម្ម (Outcome Budgeting System), ប្រសិនបើអង្គភាពក្រោមការគ្រប់គ្រងរបស់ក្រសួងណាមួយនៃរដ្ឋញូសៅវេលមិនអាចសម្រេចបាននូវសកម្មភាពទៅតាមការគ្រោងក្នុងឆ្នាំណាមួយ នោះកញ្ចប់ថវិកាមិនត្រូវបានកាត់នោះឡើយ ប៉ុន្តែតម្រូវឱ្យមានការចរចានិងពិភាក្សា និងស្វែងរកដំណោះស្រាយរួមគ្នា។ ការរៀបចំតាមដានសមិទ្ធកម្មការងាររបស់អង្គភាព


*រូបភាពនៅក្រសួងអប់រំ នៃប្រទេស អូស្ត្រាលី (NSW Department of Education) ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៩*



រូបភាពនៅក្រសួងអប់រំ នៃប្រទេស អូស្ត្រាលី (NSW Department of Education) ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៩

នីមួយៗ ត្រូវបានធ្វើឡើងតាមរយៈ Performance Agreement។

ជាការកត់សម្គាល់, រដ្ឋាភិបាលអូស្ត្រាលី បានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធសុខាភិបាលសាធារណៈ (Public Healthcare Scheme - ហៅថា Medicare) នៅឆ្នាំ១៩៨៣, និងប្រព័ន្ធគាំទ្រការអប់រំជាន់ខ្ពស់ (Higher Education Contribution Scheme - HECS) នៅឆ្នាំ១៩៨៩។ នៅឆ្នាំ១៩៩២, អូស្ត្រាលីបានដាក់ឱ្យអនុវត្តប្រព័ន្ធសន្សំកាតព្វកិច្ច (Compulsory Retirement Saving Scheme - ហៅថា Supperannuation) ដែលបានបន្ថែម ៩.៥% ប្រចាំឆ្នាំ លើប្រាក់បៀវត្ស។ នៅឆ្នាំបន្តបន្ទាប់, អូស្ត្រាលីក៏ចាប់ផ្តើមបង្កើតនូវប្រព័ន្ធធានារ៉ាប់រងសម្រាប់ជនពិការជាតិ (National Disability Insurance Scheme) និងប្រព័ន្ធសុខុមាលភាព (Welfare Scheme)

## ៥. ការគ្រប់គ្រងសមិទ្ធកម្ម

រដ្ឋាភិបាលអូស្ត្រាលី មានការគ្រប់គ្រងសមិទ្ធកម្ម ស្ថិតក្នុងក្របខណ្ឌច្បាប់ Public Governance, Performance and Accountability (PGPA Act)។ ច្បាប់នេះមានវិសាលភាពលើគ្រងរដ្ឋរបស់អូស្ត្រាលីទាំងមូលក្នុងការសម្រេចឱ្យបាននូវអភិបាលកិច្ចខ្ពស់, ផ្តល់នូវព័ត៌មានសម្រាប់សភានិងសាធារណៈជន, គ្រប់គ្រងនូវធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព, និងបង្កើនកិច្ចសហប្រតិបត្តិការរវាងគ្រប់អង្គភាព។ តាមរយៈច្បាប់នេះ, មានចំណុចមួយចំនួនបានបង្ហាញថា ក្រសួងហិរញ្ញវត្ថុអូស្ត្រាលី នៅមានសិទ្ធិក្នុងការគ្រប់គ្រងគណនីធនាគារ, ការខ្ចី, ការវិនិយោគ, ប្រសិទ្ធភាពហិរញ្ញវត្ថុ, សម្បទាន, ការអនុគ្រោះបំណុល។

## ៦. ការគ្រប់គ្រងមន្ត្រីសាធារណៈ

រដ្ឋាភិបាលអូស្ត្រាលីគ្រប់គ្រងមន្ត្រីតាមពីរប្រព័ន្ធផ្សេងគ្នារដ្ឋបាលកង់បេរា និងរដ្ឋបាលញូសៅវេល ប៉ុន្តែស្ថិតក្រោមច្បាប់តែមួយគឺ Public Service Act។ អូស្ត្រាលីបានរៀបចំយុទ្ធសាស្ត្រធនធានមនុស្ស ដោយមានប្រព័ន្ធទិន្នន័យការងារច្បាស់លាស់ និងប្រើវិធីសាស្ត្រ ៧០:២០:១០ ដើម្បីពង្រឹងសមត្ថភាពមន្ត្រី។ ក្នុងនោះ ៧០% សំដៅទៅលើការផ្តល់ឱកាសមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលដើម្បីអភិវឌ្ឍជំនាញ, ២០% ជាការបង្កើតបរិយាកាសឱ្យមន្ត្រីសិក្សាពីមិត្តរួមការងារ, និង ១០% ជាការសិក្សាដោយខ្លួនឯង ។ ទន្ទឹមនេះ អូស្ត្រាលី ក៏បានរៀបចំនូវប្រព័ន្ធគ្រប់គ្រងសមត្ថភាពធនធានមនុស្ស, ការគ្រប់គ្រងសមត្ថភាពតាមប្រព័ន្ធឌីជីថល, និងការតម្រង់ទិសតាមសមិទ្ធកម្មការងារជាដើម។ ជាការកត់សម្គាល់, រដ្ឋាភិបាលអូស្ត្រាលី បានរៀបចំនូវកម្មវិធី Branch Out ដែលជាកម្មវិធីផ្លាស់ប្តូរបទពិសោធន៍រវាងមន្ត្រីក្នុងស្ថាប័នរដ្ឋាភិបាល តាមរយៈការបញ្ជូនមន្ត្រីឱ្យទៅចូលរួមធ្វើការរយៈពេលខ្លីនៅ



រូបភាពនៅក្រសួងអប់រំ នៃប្រទេស អូស្ត្រាលី (NSW Department of Education) ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៩




*ប្រព័ន្ធគ្រប់គ្រងសេវាសាធារណៈ នៅមជ្ឈមណ្ឌលផ្ដល់សេវាសាធារណៈ (Wynyard Service New South Wales center)*

ស្ថាប័នផ្សេងទៀត ដើម្បីលើកកម្ពស់សមត្ថភាពរបស់មន្ត្រី ក៏ដូចជាបង្កើនផលិតភាព និងទំនាក់ទំនងរវាងស្ថាប័ននិងស្ថាប័ន ឆ្លងវិស័យ។

## ៧. ការគ្រប់គ្រងនិងការផ្ដល់សេវាសាធារណៈ

រដ្ឋញូសៅវែល មានប្រព័ន្ធគ្រប់គ្រងការផ្ដល់សេវាសាធារណៈរួម (one stop shop) សម្រាប់ប្រជាជនទៅលើសេវាសាធារណៈសរុបចំនួន ១០០០ ប្រភេទនៃប្រតិបត្តិការ ទូទាំង ៣៥ ស្ថាប័នរដ្ឋទាំងអស់។ ក្នុងនោះ មានមជ្ឈមណ្ឌលផ្ដល់សេវាសាធារណៈសរុបចំនួន១០៤ កន្លែង, ភ្នាក់ងារប្រឹក្សាចំនួន ៣២ (council agencies), សេវាចល័តចំនួន ២, និងបញ្ជរឱជីថលនិងស្វ័យប្រវត្តិ ចំនួន ១០ កន្លែង។ ការផ្ដល់ព័តមានសាធារណៈ ត្រូវបានធ្វើឡើងតាមរយៈមជ្ឈមណ្ឌលសេវាទូរស័ព្ទតែមួយ ( តំណាងឱ្យគ្រប់ស្ថាប័ន) និងតាមរយៈគេហទំព័រ និង Application ផងដែរ។ ទន្ទឹមនេះ, ការប្រមូលចំណូលសាធារណៈនៅរដ្ឋញូសៅវែល ត្រូវបានធ្វើឡើងតាមរយៈភ្នាក់ងារគ្រប់គ្រងចំណូលរបស់រដ្ឋ ហៅថា “Revenue NSW” ដែលមានភារកិច្ចក្នុងការប្រមូលចំណូល, ហិរញ្ញប្បទានឥតសំណង, និងបំណុល។ ស្ថាប័ននេះ ផ្ដល់នូវសេវាសម្រាប់ (១) សាធារណៈជនទូទៅ ដូចជា អ្នកបង់ពន្ធ អ្នករងការផាកពិន័យ,(២) ភ្នាក់ងារ ដូចជា គណនេយ្យករ, មេធាវី, (៣) អ្នកជំនួញ, (៤) អ្នកផ្គត់ផ្គង់, និង(៥) ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ជាដើម។

សរុបមក, បទពិសោធន៍ និងចំណេះដឹងដែលទទួលបានពី ការចែករំលែករបស់ស្ថាប័នមួយចំនួនរបស់អូស្ត្រាលី តាមរយៈដំណើរទស្សនកិច្ចនេះ, មានចំណុចល្អៗ និងជាគន្លឹះដែលអាចផ្ដល់ជាធាតុចូលមួយចំនួនក្នុង ការចូលរួមចំណែកពង្រឹងលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដូចខាងក្រោម÷

- ❑ **កត្តាកំណត់ជោគជ័យលើការងារកែទម្រង់,** ថ្វីបើកម្ពុជា ជ្រើសរើសនូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមអភិក្រមជាខឿន ដែលមានភាពផ្សេងគ្នាពីការអនុវត្តរបស់រដ្ឋាភិបាលអូស្ត្រាលីក៏ដោយ, ប៉ុន្តែចំណុចរួមមួយដែលជាបទពិសោធល្អសម្រាប់ជំរុញភាពជោគជ័យក្នុងការងារកែទម្រង់ គឺការចូលរួមពុះពារនូវបញ្ហាប្រឈមដែលកំពុង និងអាចកើតមាន ជាមួយនឹងឆន្ទៈមុតមាំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីកែទម្រង់ទាំងអស់ ព្រមទាំងពង្រឹងការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ។



*រូបភាពនៅមជ្ឈមណ្ឌលផ្ដល់សេវាសាធារណៈ (Wynyard Service New South Wal*

❑ **ការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបប្រព័ន្ធព័ត៌មានវិទ្យា ÷** ខណៈពេលដែលប្រព័ន្ធ FMIS កម្ពុជា កំពុងស្ថិតក្នុងដំណាក់កាល នៃការកសាងនិងដាក់ឱ្យអនុវត្តជាបណ្តើរៗលើម៉ូឌុលមួយចំនួន, ការធ្វើស្វ័យប្រវត្តិកម្ម Pre-decision ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងទស្សនាទានៃការកសាងប្រព័ន្ធ SBWS របស់អូស្ត្រាលី ក៏ជាចំណុចត្រៀមគិតគូរបន្ថែមក្នុងពេលវេលាសមស្របណាមួយ។

❑ **ការគ្រប់គ្រងធនធានមនុស្ស÷** ដើម្បីចូលរួមលើកកម្ពស់សមត្ថភាពមន្ត្រី ជាពិសេសមន្ត្រីក្នុងការងារកែទម្រង់, ការផ្លាស់ប្តូរជំនាញតាមរយៈផ្តល់ឱកាសផ្លាស់ប្តូរបទពិសោធរយៈពេលខ្លី គួរគិតគូរពិចារណៈក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈផងដែរ ក៏ដូចជា អភិក្រម ៧០:២០:១០ ផងដែរ៕■

*រៀបចំដោយ÷ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព នៃអ.គ.ហ.*



es center)

# ផ្នែកទី២

# អត្ថបទ




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រាជរដ្ឋាភិបាលកម្ពុជា
យុទ្ធសាស្ត្រ
ស្តីពី
កែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ
២០១៩ - ២០២៥

# របាយការណ៍សង្ខេបវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រីមាសទី៣ ឆ្នាំ២០១៩

*នាថ្ងៃពុធ ៩រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រីមាសទី៣ ដំណាក់កាលទី៣ ឆ្នាំ២០១៩ ក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ។*

កិច្ចប្រជុំត្រួតពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រីមាសទី៣ ដំណាក់កាលទី៣ ឆ្នាំ២០១៩ មានវឌ្ឍនភាពដូចខាងក្រោម៖

### ១. សមិទ្ធផលគន្លឹះៗនៃលិខិតបទដ្ឋានគតិយុត្ត ដែលបាននិងកំពុងកសាងក្នុងដំណាក់កាលទី៣

ចាប់តាំងពីដំណាក់កាលទី១ រហូតមកដល់ដំណាក់កាលទី៣ នេះ, ផែនការសកម្មភាពរួម ដែលតម្រូវឱ្យគ្រប់ក្រសួង-ស្ថាប័ន រៀបចំ និងអនុវត្តការងារកែទម្រង់ ត្រូវបានចែកចេញជា ៥ ផ្នែក, ២១ គោលបំណង, និង ៧០ ចង្កោមសកម្មភាព រួមមាន៖

- ផ្នែកទី១៖ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា “៤ គោលបំណង និង ១៦ ចង្កោមសកម្មភាព”
- ផ្នែកទី២៖ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ “៥ គោលបំណង និង ១៦ ចង្កោមសកម្មភាព”
- ផ្នែកទី៣៖ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ “៥ គោលបំណង និង ១៨ ចង្កោមសកម្មភាព”
- ផ្នែកទី៤៖ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ “៤ គោលបំណង និង ១៤ ចង្កោមសកម្មភាព”
- ផ្នែកទី៥៖ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព “៣ គោលបំណង និង ៦ ចង្កោមសកម្មភាព”

ជាលទ្ធផល, លិខិតបទដ្ឋានគតិយុត្តជាច្រើន ត្រូវបានកសាងឡើងសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំនិងដាក់ឱ្យអនុវត្ត



ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ កាន់តែមានប្រសិទ្ធភាព និងឈានទៅសម្រេចគោលដៅ និងចក្ខុវិស័យរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា។ សមិទ្ធផល នៃលិខិតបទដ្ឋានគតិយុត្តទាំងនោះត្រូវបានកសាងឡើងស្របទៅតាមផ្នែកនីមួយៗ នៃការអនុវត្តការងារកែទម្រង់ដែលសមិទ្ធផលគន្លឹះៗ រួមមានជាអាទិ៍÷

-ដើម្បីជំរុញប្រសិទ្ធភាពលើភាពជឿទុកចិត្តនៃថវិកា យុទ្ធសាស្ត្រនិងច្បាប់មួយចំនួនត្រូវបានបញ្ចប់និងកំពុងបន្តរៀបចំ ដូចជាយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៥, យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ២០១៩-២០២៥, យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ឆ្នាំ២០១៩-២០២៥, ច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន, ច្បាប់ស្តីពីការ គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ជាដើម។

-ដើម្បីជំរុញប្រសិទ្ធភាពលើគណនេយ្យភាពហិរញ្ញវត្ថុ ឯកសារ និងយុទ្ធសាស្ត្រមួយចំនួន ត្រូវបានបញ្ចប់ និងកំពុងបន្តរៀបចំ ដូចជាយុទ្ធសាស្ត្រនៃការកែទម្រង់គណនេយ្យសាធារណៈកម្ពុជា ឆ្នាំ២០១៩-២០៣១, ផែនការសកម្មភាពស្តីពី ការកាត់បន្ថយនីតិវិធី និងការគ្រប់គ្រងការផ្លាស់ប្តូរ, និង FMIS Blueprint Phase 2 ជាដើម។

-ដើម្បីជំរុញប្រសិទ្ធភាពលើការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ឯកសារ និងយុទ្ធសាស្ត្រមួយចំនួនត្រូវបានបញ្ចប់ និងកំពុងបន្តរៀបចំ ដូចជា គោលការណ៍ណែនាំស្តីពីផែនការលទ្ធកម្មភ្ជាប់ជាមួយសំណើថវិកា, អនុក្រឹត្យពីការ ផ្ទេរធនធានថវិកាថ្នាក់ជាតិជូនរដ្ឋបាលក្រុងស្រុក និង ឃុំសង្កាត់, គោលការណ៍ណែនាំស្តីពីផែនការរជ្ជទេយ្យភ្ជាប់ជាមួយសំណើថវិកា ជាដើម។

-ដើម្បីត្រៀមសម្រាប់ជំហានបន្ទាប់សម្រាប់ដំណាក់កាលទី៤ ឯកសារនិងយុទ្ធសាស្ត្រមួយចំនួន ត្រូវបានបញ្ចប់ និងកំពុងបន្តរៀបចំ ដូចជា យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥, ទស្សនាទានថវិកាព័ត៌មានសមិទ្ធកម្មនៅ កម្ពុជា, និងគោលការណ៍ណែនាំស្តីពីសវនកម្មផ្ទៃក្នុងផ្អែកលើសមិទ្ធកម្ម ជាដើម។

-ដើម្បីការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ឯកសារ និងយុទ្ធសាស្ត្រ មួយចំនួន ត្រូវបានបញ្ចប់ និង កំពុងបន្តរៀបចំ ដូចជា ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ៣, និងប្រកាសស្តីពីវិធាន និងនីតិវិធី នៃការផ្តល់ការលើកទឹកចិត្តជូនក្រុមការងារ PFM នៃក្រសួង-ស្ថាប័នជាដើម។

## ២. វឌ្ឍនភាពលើការប្រមូលចំណូល និងការអនុវត្តចំណាយ

### ក.ទិដ្ឋភាពរួម

ក្នុងរយៈពេល ៩ ខែនេះ, រាជរដ្ឋាភិបាលកម្ពុជា បានប្រមូលចំណូលថវិការដ្ឋសរុប ប្រមាណ ១៩ ១២៥ ប៊ីលានរៀល ស្មើនឹង ៩០% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០១៩ ដែលទិន្នផលចំណូលនេះ បានពីការប្រមូលដោយពន្ធគយនិងរដ្ឋាករ មានប្រមាណ






៤៩%, ពន្ធដារ មានប្រមាណ ៣២%, ចំណូលមិនមែនសារពើពន្ធ មានប្រមាណ ១២% និងចំណូលផ្សេងៗប្រមាណ ៦%។

សម្រាប់ការអនុវត្តចំណាយ នៅទាបជាងគោលដៅដែលបានកំណត់ គឺ ៥៩% ធៀបនឹង ៦៧% ដែលអាចបង្កឱ្យមានការ ចំណាយច្រើននៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០១៩ នេះ។

បើធៀបនឹងច្បាប់ថវិកា,ការអនុវត្តចំណាយតាមប្រភេទនីមួយៗ,មានតែចំណាយបន្ទុកបុគ្គលិក ដែលសម្រេចបាន ៧៤% ខណៈដែលការចំណាយលើទំនិញ និងសេវា និងមូលធន មានវឌ្ឍនភាពទាបនៅឡើយ ដោយសារតែការអនុវត្តកិច្ចលទ្ធកម្ម នៅមានភាពយឺតយ៉ាវ និងការទូទាត់ចំណាយមូលធនធ្វើនៅត្រីមាសទី៤។

ដោយឡែកក្របខណ្ឌគណនីដែលបានបើកនៅ កសហវ សម្រាប់ធ្វើការកត់ត្រាចំណូល-ចំណាយ មានការកើនឡើងរហូតដល់ ៩៧ គិតមកត្រឹមចុងត្រីមាសទី៣នេះ ដោយសារមានកើនឡើងគម្រោងការខ្ចី ដែលតម្រូវឱ្យបើកគណនីថ្មីសម្រាប់គម្រោងនីមួយៗ។

## ខ.និន្នាការនៃការប្រមូលចំណូល

ការប្រមូលចំណូលសារពើពន្ធ នៅបន្តមានភាពរឹងមាំ ដោយសារ ការកើនឡើង

រូបភាពទី៣÷និន្នាការនៃការប្រមូលចំណូល




នូវការនាំចូលយានយន្ត និងការកែសម្រួលគោលនយោបាយពន្ធអាករគយ លើមុខទំនិញមួយចំនួន ដែលមានវេទយិតភាពលើចំណូល, ការធ្វើកំណែទម្រង់គោល-នយោបាយ និងរដ្ឋបាលសារពើពន្ធ, ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងការដាក់ឱ្យអនុវត្ត ប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូល អនឡាញ, ប៉ុន្តែ ចំណូលពីផលិតផលថ្នាំជក់មានការធ្លាក់ចុះ ដោយសារការការបិទរោងចក្រផលិតបារីធំៗក្នុងស្រុក។ (រូបភាពទី៣)។

រីឯ ការប្រមូលចំណូលមិនមែនសារពើ-ពន្ធ ក៏មានវឌ្ឍនភាពប្រសើរ ដោយសារការកើនឡើងនៃចំណូលទទួលបានពីការបង់ភាគលាភរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនដែលចំរុះរដ្ឋមានភាគកម្ម ពីការជួលផ្នែកនៃអាគារ ឬសំណង់ផ្សេងៗ និងចំណូលពីការជួលដី និងអាគារទាំងមូលរបស់រដ្ឋ, ផលទុនរបស់អាកាសចរណ៍ស៊ីវិល, ផលទុនរបស់ប្រៃសណីយ៍ និងទូរគមនាគមន៍,ចំណូលពីអាករ នៃស្ថានទូតរួមមានការផ្តល់ទិដ្ឋាការស្ទិកការផ្តល់ទិដ្ឋាការអេឡិចត្រូនិច ការផ្តល់លិខិតឆ្លងដែន, ចំណូលកាតព្វកិច្ចពីកាស៊ីណូ, ចំណូលកាតព្វកិច្ចពីឆ្នោត និងចំណូលពីអាជ្ញាបណ្ណកាស៊ីណូ ប៉ុន្តែ មិនទាន់មានចំណូលពីសម្បទាន ពីប្រេងកាត, រីឯពីរ៉ែមានការថយចុះ ដោយក្រសួងរ៉ែនិងថាមពលកំពុងរៀបចំកំណែទម្រង់ ។ ការកត់សម្គាល់, សមត្ថភាពនៃការព្យាករណ៍របស់អង្គភាពប្រមូលចំណូល កាន់តែប្រសើរឡើង គឺក្នុងរង្វង់ +/-៥% ធៀបនឹងផែនការត្រីមាស។ (រូបភាពទី៤ និង រូបភាពទី៥)

រូបភាពទី៤




រូបភាពទី៥




*ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ (គិតត្រឹមថ្ងៃទី៣០ តុលា ២០១៩)*

រូបភាពទី៦÷ និន្នាការនៃការអនុវត្តថវិកាធៀបនឹងច្បាប់ (រយៈពេល៩ខែ)




រូបភាពទី៧




*ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ (គិតត្រឹមថ្ងៃទី៣០ តុលា ២០១៩)*

**គ.ការអនុវត្តថវិការដ្ឋ**

ក្នុងរយៈពេល ៩ ខែ នៃឆ្នាំ២០១៩, ស្ថានភាពនៃការអនុវត្តចំណាយថវិការដ្ឋ សម្រេចបានតែ ៥៩.១២% ធៀបនឹងច្បាប់ថវិកា ដែលនៅទាបជាងគោលដៅដែល ក្នុងនោះ ចំណាយចរន្តមានប្រមាណ ៨៤% ហើយភាគច្រើនគឺចំណាយសម្រាប់បន្ទុកបុគ្គលិក ដែលមានប្រមាណ ៤៩%។ (រូបភាពទី៦ និងរូបភាពទី៧)។

បើធៀបនឹងច្បាប់, ក្នុងរយៈពេល៩នេះ ចំណាយបន្ទុកបុគ្គលិកសម្រេចបាន ៧៤%, ចំណាយក្រៅបន្ទុកបុគ្គលិក (ទំនិញ និងសេវា) សម្រេចបាន ៥១,១% រីឯចំណាយមូលធន សម្រេចបាន ៤៧,៨%។សម្រាប់រយៈពេលដដែល ធៀបនឹងឆ្នាំ កន្លងទៅ, វឌ្ឍនភាពលើការអនុវត្តចំណាយ មានការថមថយ ជាពិសេសសម្រាប់ចំណាយលើទំនិញនិងសេវា ដោយសារមានការយឺត-យ៉ាវលើការអនុវត្តកិច្ចលទ្ធកម្ម រីឯចំណាយមូលធន គឺធ្វើការទូទាត់នៅត្រីមាសទី៤។

*ក្នុងរយៈពេល ៩ ខែនេះ, រាជរដ្ឋាភិបាលកម្ពុជា បានប្រមូលចំណូលថវិការដ្ឋសរុប ប្រមាណ ១៩ ១២៥ ប៊ីលានរៀល ស្មើនឹង ៩០% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៩ ដែលទិន្នផលចំណូលនេះបានពីការប្រមូលដោយពន្ធគយនិងរដ្ឋាករ មានប្រមាណ ៤៩%, ពន្ធដារ មានប្រមាណ ៣២%, ចំណូលមិនមែនសារពើពន្ធ មានប្រមាណ ១២% និងចំណូលផ្សេងៗ ប្រមាណ ៦% ។*

រូបភាពទី៨÷ និន្នាការនៃការអនុវត្តចំណាយតាមប្រភេទ ធៀបនឹងច្បាប់នៃប្រភេទនីមួយៗ (ក្នុងរយៈពេល ៩ ខែ)




*ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ (គិតត្រឹមថ្ងៃទី៣០ តុលា ២០១៩)*

រូបភាពទី៩÷ វឌ្ឍនភាពតាមអង្គភាព នៃ កសហវ. *ប្រភព÷ អ.គ.ហ.*




## ៣. វឌ្ឍនភាពលើការងារកែទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្នុងត្រីមាសទី៣នេះ, ផ្នែកទី១ “ភាពជឿទុកចិត្តនៃថវិកា” សម្រេចបាន ៩១%, ផ្នែកទី២ “គណនេយ្យភាពហិរញ្ញវត្ថុ” សម្រេចបាន ៩៧%, ផ្នែកទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” សម្រេចបាន ៩៥%, ផ្នែកទី៤ “ការត្រៀមសម្រាប់ជំហានបន្ទាប់” សម្រេចបាន ៩០%, និងផ្នែកទី៥ “ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយចីរភាព” សម្រេចបាន ៩៩%។ បើធៀបនឹងត្រីមាសទី២, សកម្មភាព នៃការអនុវត្តការងារកែទម្រង់ នៅតែបន្តមានវឌ្ឍនភាពល្អ ទាំងក្របខណ្ឌនៃការរៀបចំលិខិតបទដ្ឋានគិតយុត្ត, ការកសាងប្រព័ន្ធ, និងការពង្រឹងការកសាងសមត្ថភាពមន្ត្រី។ ប៉ុន្តែ ចំណុចសូចនាករគន្លឹះៗចំនួន នៅបន្តតាមដាន ដែលជំរុញក្នុង ការពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល, ការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ការពង្រឹងការអនុវត្តថវិកាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, និង ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS ជាដើម។

ភាគច្រើននៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានវឌ្ឍនភាព នៃការអនុវត្តកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុច្រើនជាង ៨៦% និងមានតែ២ អង្គភាពប៉ុណ្ណោះដែលសម្រេចបានក្រោម ៨៦%។

## ៤. វឌ្ឍនភាពលើការងារកែទម្រង់របស់ក្រសួង-ស្ថាប័ន (ការអនុវត្តចំណាយចរន្ត)

| វិស័យ | ក្រសួង-ស្ថាប័ន | ការអនុវត្តថវិកាចរន្ត (គិតជាប៊ីលានរៀល) | | ត្រីមាសទី៣ | |
|---|---|---|---|---|---|
| | | រយៈពេល ៩ ខែ | % ធៀបច្បាប់ | សមិទ្ធកម្ម | សកម្មភាពសម្រេច ១០០% |
| វិស័យសេដ្ឋកិច្ច | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 20.80 | 37% | 94% | 16/19 |
| | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 32.81 | 57% | 96% | 11/12 |
| | ក្រសួង រ៉ែ និងថាមពល | 24.08 | 42% | 100% | 9/9 |
| | ក្រសួងពាណិជ្ជកម្ម | 70.35 | 47% | 99% | 8/9 |
| | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 156.90 | 59% | 94% | 15/18 |
| | ក្រសួងអភិវឌ្ឍន៍ជនបទ | 63.35 | 35% | 99% | 18/20 |
| | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 55.44 | 75% | 97% | 4/9 |
| | ក្រសួងសាធារណការ និងដឹកជញ្ជូន | 127.72 | 31% | 62% | 22/28 |
| | ក្រសួងទេសចរណ៍ | 62.35 | 64% | 99% | 12/14 |
| | ក្រសួងធនធានទឹក និង ឧតុនិយម | 62.00 | 39% | 89% | 5/10 |
| | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 140.41 | 60% | 99% | 20/21 |

| វិស័យ | ក្រសួង-ស្ថាប័ន | ការអនុវត្តថវិកាចរន្ត (គិតជាប៊ីលានរៀល) | | ត្រីមាសទី៣ | |
|---|---|---|---|---|---|
| | | រយៈពេល ៩ ខែ | % ធៀបច្បាប់ | សមិទ្ធកម្ម | សកម្មភាពសម្រេច ១០០% |
| ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេស និងសេវាសាធារណៈទូទៅ | ទីស្តីការគណៈរដ្ឋមន្ត្រី | 230.93 | 56% | 91% | 6/9 |
| | ក្រសួងមុខងារសាធារណៈ | 35.01 | 65% | 92% | 12/13 |
| | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 7.87 | 51% | 96% | 22/23 |
| | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 27.00 | 65% | 100% | 9/9 |
| | ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | 98.57 | 66% | 100% | 13/13 |
| | ក្រសួងពតិមាន | 82.95 | 55% | 97% | 5/6 |
| | ក្រសួងផែនការ | 56.00 | 61% | 99% | 15/16 |
| | គណៈកម្មការមូលបត្រកម្ពុជា | #N/A | #N/A | 100% | 9/9 |
| ស្ថាប័នសេវាការពារជាតិ | ក្រសួងការពារជាតិ | 1,709.13 | 71% | 100% | 2/2 |
| | ក្រសួងមហាផ្ទៃ -ផ្នែកសន្តិសុខសាធារណៈ | 972.22 | 65% | 97% | 9/12 |
| | ក្រសួងមហាផ្ទៃ -ផ្នែករដ្ឋបាលទូទៅ | 161.62 | 78% | 86% | 10/12 |
| | ក្រសួងបរិស្ថាន | 49.64 | 55% | 84% | 18/21 |
| | ក្រសួងរៀបចំដែនដី នគរូបនីកម្ម និង សំណង់ | 90.02 | 55% | 100% | 16/16 |
| ស្ថាប័នសេវាសង្គមកិច្ច | ក្រសួងសុខាភិបាល | 1,014.65 | 66% | 92% | 10/11 |
| | ក្រសួងអប់រំ យុវជន និងកីឡា | 1,981.36 | 67% | 83% | 11/18 |
| | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 137.89 | 77% | 76% | 15/18 |
| | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | 743.38 | 75% | 99% | 11/12 |
| | ក្រសួងធម្មការ និង សាសនា | 45.76 | 67% | 93% | 5/10 |
| | ក្រសួងកិច្ចការនារី | 66.41 | 67% | 99% | 7/8 |
| ស្ថាប័នកំពូល និងឯករាជ្យ | ក្រសួងព្រះបរមរាជវាំង | 66.41 | 67% | 100% | 8/8 |
| | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ | 9.91 | 86% | 100% | 4/4 |
| | អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | 78.78 | 90% | 68% | 2/5 |
| | អគ្គលេខាធិការដ្ឋានរដ្ឋសភា | 163.11 | 89% | 14% | 3/9 |
| | ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | #N/A | #N/A | 100% | 1/1 |
| | តុលាការកំពូល | #N/A | #N/A | 85% | 6/6 |
| | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | #N/A | #N/A | 85% | 3/4 |
| | អាជ្ញាធរសវនកម្មជាតិ | 8.73 | 59% | 96% | 10/18 |
| | អង្គភាពប្រឆាំងអំពើពុករលួយ | 30.78 | 67% | 100% | 4/4 |
| | ក្រសួងយុត្តិធម៌ | #N/A | #N/A | 100% | 2/2 |
| | សាលាឧទ្ធរណ៍ | #N/A | #N/A | 86% | 9/11 |

*ប្រភព៖ អគ្គនាយកដ្ឋានថវិកា និង អ.គ.ហ.*



កិច្ចប្រជុំ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារបច្ចេកទេស
(PFMSC + TWG)

# របាយការណ៍វឌ្ឍនភាព ប្រចាំត្រីមាសទី៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣

ថ្ងៃពុធ ៩រោច ខែកត្ដិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ស្ថានភាពនៃការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានភាពរឹងមាំ ប៉ុន្តែ ស្ថានភាពនៃការអនុវត្តចំណាយ នៅមានការយឺតយ៉ាវបន្តិច ដោយការអនុវត្តកិច្ចលទ្ធកម្មមួយចំនួន នៅមានភាពយឺតយ៉ាវ ។*

ក្រសួងស្ថាប័ន ដែលអនុវត្តចំណាយទាបជាង ៥០% ធៀបនឹងច្បាប់ រួមមាន រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល (៣៧%), ក្រសួងរ៉ែ និងថាមពល (៤២%), ក្រសួងពាណិជ្ជកម្ម (៤៧%), ក្រសួងអភិវឌ្ឍន៍ជនបទ (៣៥%), ក្រសួងសាធារណៈការនិងដឹកជញ្ជូន (៣១%), និងក្រសួងធនធានទឹក និងឧតុនិយម (៣៩%)។

### គ. វឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់

ក្រសួង-ស្ថាប័ន ភាគច្រើននៅតែបន្តការចូលរួមលើការងារកែទម្រង់ និងបន្តមានវឌ្ឍនភាពប្រសើរ ក្នុងនោះការបន្តរៀបចំយន្តការក្នុងការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ, ការរៀបចំនិងអនុវត្តថវិកា និងការចូលរួមតាមដានលើការអនុវត្តការងារកែទម្រង់តាមរបបប្រជុំជាទៀងទាត់។ ទោះជាយ៉ាងណា បញ្ហាប្រឈមមួយចំនួន នៅតែត្រូវបន្តយកចិត្តទុកដាក់ ដូចជា ពង្រឹងកិច្ចសហការក្នុងការងារកែទម្រង់ផ្ទៃក្នុងក្រសួង, ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចូលរួមពិនិត្យកែលម្អនីតិវិធីនៃការអនុវត្តការងារជាដើម។

## ៥.សន្និដ្ឋាន

ស្ថានភាពនៃការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានភាពរឹងមាំ ប៉ុន្តែស្ថានភាពនៃការអនុវត្តចំណាយនៅមានការយឺតយ៉ាវបន្តិច ដោយការអនុវត្តកិច្ចលទ្ធកម្មមួយចំនួន នៅមានភាពយឺតយ៉ាវ។ ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP3/ MAP3/ GDAP3) ប្រចាំត្រីមាសទី៣នេះ មានវឌ្ឍនភាពល្អប្រសើរ ដោយភាគច្រើននៃអង្គភាពអនុវត្តសម្រេចបានគោលដៅល្អប្រសើរ ទៅតាមសូចនាករដែលបានកំណត់ ទាំងក្របខណ្ឌនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត, យុទ្ធសាស្ត្រ, ផែនការសកម្មភាព, និងការចូលរួមអនុវត្តសកម្មភាពនានា។

ជារួម, ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គិតមកត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩ គឺស្ថិតក្នុងស្ថានភាពល្អប្រសើរ និងត្រូវបានរំពឹងថាអាចសម្រេចបាននូវគោលដៅប្រចាំឆ្នាំ៕■

*រៀបចំដោយ÷ ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព នៃ អ.គ.ហ.*

# សញ្ញាណទូទៅនៃការគ្រប់គ្រងការផ្លាស់ប្តូរ

*ការគ្រប់គ្រងការផ្លាស់ប្តូរ គឺជាក្របខណ្ឌសម្រាប់គ្រប់គ្រងមនុស្សលើការផ្លាស់ប្តូរ ដើម្បីឱ្យស្រប ទៅនឹងជំនាញ និងឥរិយាបថថ្មី, បញ្ជ្រាបនូវចក្ខុវិស័យ និងបេសកកម្មរួម និងលទ្ធផលរំពឹងទុក។*

ការគ្រប់គ្រងការផ្លាស់ប្តូរមិនមែនជាក្របខណ្ឌផ្អែកលើឧបករណ៍ ឬ One-size-fits-all នោះឡើយ ប៉ុន្តែគឺជាការផ្តល់នូវភាពទន់ភ្លន់ និងបន្តការសម្របបន្តិចម្តងៗ, " ដឹកនាំការផ្លាស់ប្តូរតាមរយៈមនុស្ស កុំដឹកនាំមនុស្សតាមរយៈការផ្លាស់ប្តូរ Drive change through people not people through change" ការផ្លាស់ប្តូរ រួមមានដូចជា÷

- ការអនុវត្តនូវប្រព័ន្ធថ្មី, កម្មវិធីកុំព្យូទ័រថ្មី, សម្ភារៈ/ ឧបករណ៍ថ្មី
- កែប្រែរចនាសម្ព័ន្ធអង្គភាព ឬ បន្ទាត់គណនេយ្យភាព
- ការកាត់បន្ថយបុគ្គលិក
- ការផ្លាស់ប្តូរទៅរកម៉ូឌែលការងារថ្មីទាំងស្រុង
- ការរួមបញ្ចូលគ្នារវាងអង្គភាព
- ការផ្លាស់ប្តូរដោយសារបរិយាកាសសកល
- នីតិវិធីអនុវត្តការងារថ្មី។

ដូចនេះ ការគ្រប់គ្រងការផ្លាស់ប្តូរ គឺមិនមែនជាព្រឹត្តិការណ៍ទេ ប៉ុន្តែជាកិច្ចដំណើរការដែលភាពជោគជ័យ អាស្រ័យលើបុគ្គល ឬមនុស្សជាក្រុម ដែលបានផ្លាស់ប្តូររបៀបធ្វើការរបស់ពួកគេ ដូចជា ការទទួលយកឥរិយាបទការងារថ្មី, ការប្រើប្រាស់ឧបករណ៍ថ្មី, ការសម្របខ្លួនទៅនឹងនីតិវិធីថ្មី ។

### ❖ ការសិក្សាស្រាវជ្រាវអំពីការគ្រប់-គ្រងការផ្លាស់ប្តូរ

**សញ្ញាណទូទៅ÷** យោងតាមប្រភពរបស់ McKinsey & Co (២០០៩) បានបង្ហាញថា ៥០%-៦០% នៃកម្លាំងខិតខំលើការផ្លាស់ប្តូរ មិនទទួលបានជោគជ័យនោះទេ ហើយតិចជាង ១ភាគ៣ នៃគំនិតផ្តួចផ្តើមលើការគ្រប់គ្រងការផ្លាស់ប្តូរ ត្រូវបានទទួលស្គាល់។

**បញ្ហាប្រឈមចម្បងៗ** នៃការផ្លាស់ប្តូរ គឺកើតពីការបដិសេធមិនទទួលយក ចាប់ពីកម្រិតថ្នាក់ដឹកនាំរហូតដល់មន្ត្រី ប្រមាណ ៦៥%, ភាពកំសោយនៃការបញ្ជ្រាបព័ត៌មាន




*ប្រភព៖Change Management for HR Certification, SGP*




៥១%, និងកង្វះការបណ្តុះបណ្តាល និងការគាំទ្រ ៤៩%។ ឧបសគ្គដែលរាំងស្ទះដល់ការផ្លាស់ប្តូរភាគច្រើន គឺរចនាសម្ព័ន្ធ/នីតិវិធីការងារចាស់, ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស, ឥរិយាបទថ្នាក់ដឹកនាំដែលមិនព្រមទទួលការផ្លាស់ប្តូរ ។

### ❖ មុខងារក្នុងការគ្រប់គ្រងការផ្លាស់ប្តូរ

ក្នុងកិច្ចដំណើរការនៃការគ្រប់គ្រងការផ្លាស់ប្តូរ មានមុខងារសំខាន់ៗ ចំនួន ៣ រួមមាន មុខងារស្ថាបត្យករ (Architect-Design Change), មុខងារផ្សព្វផ្សាយ ( Broadcaster é Communication Change), និងមុខងារគ្រូបង្វឹក (Coach-Encourage change)។

➢ មុខងារស្ថាបត្យករ (Architect-Design Change)÷ ជាចំណុចដែលចាប់ផ្តើមនៃការផ្លាស់ប្តូរ ដែលត្រូវគិតគូរការផ្លាស់ប្តូរដោយផ្អែកលើអភិក្រមមូលដ្ឋានមនុស្ស (Human-centered design approach)។ ក្នុងដំណាក់កាលនេះ ត្រូវធានាមានធនធានមនុស្សដែលនឹងចូលរួម ហើយត្រូវជាមួយនឹងលក្ខខណ្ឌ នៃការផ្លាស់ប្តូរ ដោយគិតបញ្ចូលទាំងការត្រៀមលក្ខណៈ, ការជម្រុះចេញនូវឧបសគ្គនានា និងការរក្សានិរន្តរភាព។

- ការវាយតម្លៃលើភាពរួចរាល់នៃការផ្លាស់ប្តូរ, វិសាលភាពនៃការផ្លាស់ប្តូរ, និងកំណត់ឧបករណ៍សម្រាប់ការវាយតម្លៃនេះ ដូចជា វិភាគលើអ្នកចូលរួម,វិភាគលើផលប៉ះពាល់ និងលទ្ធផល ។
- កំណត់ហានិភ័យទៅតាមប្រភេទនៃការផ្លាស់ប្តូរ ដែលរួមមាន÷
  - ■ ហានិភ័យខ្ពស់÷ សម្រាប់ការផ្លាស់ប្តូរខ្លាំង និងលឿន
  - ■ ហានិភ័យមធ្យម÷សម្រាប់ការផ្លាស់ប្តូរតិចតួច ប៉ុន្តែលឿន, ឬ ការផ្លាស់ប្តូរខ្លាំង ប៉ុន្តែបន្តិចម្តងៗ ។
  - ■ ហានិភ័យទាប÷សម្រាប់ការផ្លាស់ប្តូរតិចតួច និងបន្តិចម្តងៗ។

➢ មុខងារផ្សព្វផ្សាយ (Broadcaster - Communication Change)÷ គឺកំណត់នូវព័ត៌មានត្រឹមត្រូវ និងមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត សម្រាប់ធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបទៅអ្នកពាក់ព័ន្ធ,ព្រមទាំងកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រសម្រាប់ការទំនាក់ទំនងនិងផ្សព្វផ្សាយ។ ការផ្សព្វផ្សាយ/ការទំនាក់ទំនង គឺមានសារៈសំខាន់ណាស់ សម្រាប់ផ្តល់ព័ត៌មានទៅបុគ្គលិកអំពីការផ្លាស់ប្តូរ និងបញ្ជ្រាបឱ្យយល់ដឹងអំពីអត្ថប្រយោជន៍ ដែលពួកគេទទួលបានពីលទ្ធផលនៃការផ្លាស់ប្តូរនេះ។ វិធីសាស្ត្រនៃការផ្សព្វផ្សាយត្រូវចាប់ផ្តើមពី ចក្ខុវិស័យ, ហេតុផលនៃការផ្លាស់ប្តូរ, វិធីសាស្ត្រលម្អិតអំពីការផ្លាស់ប្តូរ, ផលប៉ះពាល់និងលទ្ធផល,

*បញ្ហាប្រឈមចម្បងៗ នៃការផ្លាស់ប្តូរ គឺកើតពីការបដិសេធមិនទទួលយកចាប់ពីកម្រិតថ្នាក់ដឹកនាំរហូតដល់មន្ត្រី ប្រមាណ ៦៥%, ភាពកំសោយ នៃការបញ្ជ្រាបព័ត៌មាន ៥១%, និងកង្វះការបណ្តុះបណ្តាល និងការគាំទ្រ ៤៩% ។*

និងវឌ្ឍនភាព។ លើសពីនេះ, ការរៀបចំ និងអនុវត្តនូវ ផែនការផ្សព្វផ្សាយ ក៏មានសារៈសំខាន់ក្នុងការជំរុញប្រសិទ្ធភាព ដែលអាចឆ្លុះបញ្ចាំងអំពី WHY និងHOW ដែលចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរផងដែរ ក្នុងនោះត្រូវកំណត់អំពីក្រុមមនុស្សដែលត្រូវទទួលនូវការផ្លាស់ប្តូរនេះ ព្រមទាំងអ្នកដែលនឹងមានឥទ្ធិពលក្នុងការបញ្ជ្រាបអំពីការផ្លាស់-ប្តូរនេះ ប្រកបដោយប្រសិទ្ធភាព ទៅតាមចំណុចនីមួយៗដូចខាងក្រោម÷

- ថ្នាក់ដឹកនាំជាន់ខ្ពស់/ប្រធាននៃការផ្លាស់ប្តូរ÷ ជាអ្នកបញ្ជ្រាបការយល់ដឹងអំពីចក្ខុវិស័យ និងហេតុផលនៃការផ្លាស់ប្តូរ
- ថ្នាក់ដឹកនាំ ឬក្រុមការងារ÷ ជាអ្នកផ្តល់ព័ត៌មានលម្អិតបន្ថែមអំពីវិធីសាស្ត្រនៃការផ្លាស់ប្តូរ
- ប្រធានផ្នែក/អ្នកគ្រប់គ្រងផ្ទាល់÷ ជាអ្នកពន្យល់អំពីផលប៉ះពាល់ និងលទ្ធផលដែលទទួលបាន
- ថ្នាក់ដឹកនាំ ឬក្រុមការងារ ឬអ្នកគ្រប់គ្រងផ្ទាល់÷បង្ហាញអំពីវឌ្ឍនភាពអំពីការផ្លាស់ប្តូរនេះ។




*ប្រភព៖Change Management for HR Certification, SGP*

➢ មុខងារគ្រូបង្វឹក (Coach-Encourage change)

- កំណត់ និងប៉ាន់ស្មានទុកមុនអំពីប្រតិកម្មរបស់មនុស្សចំពោះការផ្លាស់ប្តូរ។
- ប្រើប្រាស់សក្តានុពលរបស់មន្ត្រីឱ្យអស់លទ្ធភាពដើម្បីប្រឈមនឹងការផ្លាស់ប្តូរ÷ វិភាគតម្រូវការបណ្តុះបណ្តាល, បង្កើតផែនការបណ្តុះបណ្តាល, កំណត់វិធីសាស្ត្រនៃការបណ្តុះបណ្តាល, កំណត់ពេលវេលាដែលត្រូវបណ្តុះបណ្តាល
- ផ្តល់ឱកាសឱ្យមន្ត្រីចូលរួមគ្រប់ដំណាក់កាលនៃការផ្លាស់ប្តូរ÷ លើកទឹកចិត្ត និងរង្វាន់ និងការទទួលស្គាល់ស្នាដៃ, ជ្រើសរើសមន្ត្រីគំរូជាអ្នកតំណាង/នាំសារបន្ត, និងបង្កើតបណ្តាញអប់រំបន្ត។

### ❖ អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងការផ្លាស់ប្តូរ

ប្រធាន នៃការផ្លាស់ប្តូរ (Change Sponsor) ÷ជាបុគ្គល ឬក្រុមមនុស្ស ដែលមានឥទ្ធិពលបំផុត ដែលអាចដឹកនាំការផ្លាស់ប្តូររបស់អង្គភាព តាមរយៈការបង្កើតក្រុមការងារចំរុះ ដើម្បីគាំទ្រការផ្លាស់ប្តូរនេះព្រមទាំងផ្តល់ព័ត៌មានជាមួយនឹងមន្ត្រីដើម្បីចូលរួមការផ្លាស់ប្តូរនេះឱ្យមានប្រសិទ្ធភាព។

ដើម្បីឱ្យការគាំទ្រលើការផ្លាស់ប្តូរជោគជ័យ ត្រូវផ្តល់ភាពទុកចិត្ត, កំណត់អាទិភាពច្បាស់លាស់ដែលអាចបង្កើតបានលទ្ធផលជាក់លាក់។

ការចូលរួមរបស់អ្នកពាក់ព័ន្ធ (Stake-holders) ÷តាមការសិក្សាស្រាវជ្រាវរបស់ McKinsey & Co បង្ហាញថា អត្រាជោគជ័យលើការផ្លាស់ប្តូរ អាចមាន៧០% បើអ្នកពាក់ព័ន្ធបានចូលរួមចាប់តាំងពីដំណាក់កាលដំបូងនៃការផ្លាស់ប្តូរ។■

*រៀបចំដោយ÷ ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព នៃ អ.ត.ហ.*

# យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥

*យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ត្រូវបានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៩ ។*

ការណ៍នេះ បានបង្ហាញឱ្យឃើញពីការបោះជំហានថ្មី មួយទៀត និងជាសក្ខីកម្ម នៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាពនិងគណនេយ្យភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងជាឆ្លើយតបទៅនឹងការចង្អុលបង្ហាញដែលមាននៅក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ ២០១៨-២០២៥ ដើម្បីប្រែក្លាយជាប្រព័ន្ធថវិកាជាតិពេញលេញ និងតែមួយ។ ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិមិនគ្រាន់តែជាការផ្លាស់ប្តូររបៀបរបបនៃការគ្រប់គ្រងថវិកាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនឆន្ទានុសិទ្ធិ និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផងដែរ។

ក្នុងន័យនេះ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ មានទិសដៅពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាបណ្តើរៗ ដើម្បីឈានដល់ការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាដោយធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណង/គោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាល ដែលកំណត់តួនាទី, សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើសមាហរណកម្មផែនការនីយកម្មកម្រិតផែនការយុទ្ធសាស្ត្រ ផ្តល់ការលើកកម្ពស់ប្រសិទ្ធភាពនៃទំនាក់ទំនង, ភាពប្រទាក់ក្រឡា និងបំពេញឱ្យគ្នា ដោយការតម្រឹមកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅនឹងកម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ។ ការធ្វើសមាហរណកម្ម នៃផែនការនីយកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងធ្វើឱ្យការរៀបចំផែនការសកម្មភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំង ០៣ប្រភេទ (រដ្ឋបាលរាជធានី-ខេត្ត, ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់) មានលក្ខណៈប្រមូលផ្តុំដើម្បីតម្រង់ទិសបែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ជាងមុន សម្រាប់ជា

*ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសង្គតិភាពជាមួយនឹងប្រព័ន្ធថវិកាជាតិតាមអភិក្រម* ***សាមញ្ញ ទន់ភ្លន់ តម្លាភាព និងគណនេយ្យភាព*** *ស្របទៅតាមសមត្ថភាព និងបរិការណ៍ជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនោះទេ ប៉ុន្តែការវិភាជ និងការអនុវត្តថវិកាក៏ត្រូវបានផ្តល់សិទ្ធស្វ័យសម្រេច និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផងដែរ ។*



មូលដ្ឋានក្នុងការតម្រឹមជាមួយផែនការរបស់មន្ទីរជំនាញរាជធានី-ខេត្ត។ ថែមលើនេះ, ការធ្វើការកែលម្អ និងផ្លាស់ប្តូរជាជំហានៗវដ្តថវិកានៃរដ្ឋបាលរាជធានី-ខេត្ត, ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់ ដោយត្រូវតម្រឹមជាមួយនឹងវដ្តថវិកាជាតិ ជាពិសេសកំណត់ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្តថវិកា។

ទន្ទឹមនឹងនេះ, យុទ្ធសាស្ត្រនេះ ក៏បានកំណត់គោលបំណង និងគូសវាសផ្លូវ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្ម សាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដោយធ្វើការពន្លឿន និងកែសម្រួលនីតិវិធីលទ្ធកម្មសាធារណៈ តាមអភិក្រមជាជំហានៗ ដើម្បីឱ្យមានសង្គតិភាពជាមួយទិសដៅ នៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ។ ប្រព័ន្ធលទ្ធកម្មសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវធ្វើការកែលម្អដោយប្រគល់សិទ្ធិសម្រេច និងការទទួលខុសត្រូវលើកិច្ចលទ្ធកម្មជាបណ្តើរៗបន្ថែមទៀតជូនរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពេលមានក្របខណ្ឌគណនេយ្យភាពច្បាស់លាស់នៅឆ្នាំ២០២៥។ ប្រការនេះ, ការត្រួតពិនិត្យការអនុវត្តកិច្ចលទ្ធកម្មរបស់រដ្ឋបាលរាជធានី-ខេត្ត និងក្រុង ស្រុក ខណ្ឌ នឹងត្រូវពង្រឹងជាបណ្តើរៗតាមរយៈការធ្វើសវនកម្មកិច្ចលទ្ធកម្ម។

ជារួម, យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ មានទិសដៅ÷

- ពង្រឹង និងពង្រីកការអនុវត្ត «ថវិកាកម្មវិធី» ជាបណ្តើរៗ ដើម្បីធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេស គោលបំណង/ ត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាពគោលនយោបាយជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិទាំង ០៣កម្រិត នឹងត្រូវធ្វើឱ្យការគ្រោងផែនការសកម្មភាពមានលក្ខណៈប្រមូលផ្តុំ ដើម្បីតម្រង់ទិស, បែងចែកមុខងារ និងកំណត់ការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ជាងមុនសម្រាប់ជាមូលដ្ឋានក្នុងការតម្រឹមជាមួយ ផែនការរបស់មន្ទីរជំនាញរាជធានី ខេត្ត។
- ធ្វើការកែលម្អ និងផ្លាស់ប្តូរជាជំហានៗ វដ្តថវិកានៃរដ្ឋបាលរាជធានី-ខេត្ត,ក្រុង ស្រុក ខណ្ឌ និងឃុំ-សង្កាត់ ដោយត្រូវតម្រឹមជាមួយនឹងវដ្តថវិកាជាតិ ជាពិសេសកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវនៅក្នុងដំណាក់កាលនៃវដ្តថវិកា។
- បង្កើត តួនាទីត្រួតពិនិត្យថវិកាដោយផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវរួម និងផ្ទាល់ដល់មន្ទីរ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រមូលផ្តុំមុខងារត្រួតពិនិត្យហិរញ្ញវត្ថុ និងកិច្ចលទ្ធកម្ម ក្នុងការត្រួតពិនិត្យថវិកាមន្ទីរជំនាញ និងថវិការដ្ឋបាលរាជធានី-ខេត្ត ។
- ផ្តល់សិទ្ធិស្វ័យសម្រេច និងទទួលខុសត្រូវ ចំពោះការអនុវត្តថវិការដ្ឋបាល ក្រុង ស្រុក និងថវិការដ្ឋបាល ឃុំ សង្កាត់ ប៉ុន្តែជាកម្មវត្ថុនៃការត្រួតពិនិត្យក្រោយចំណាយដោយរតនាគាររាជធានី-ខេត្ត ក្នុងមុខងារជាគណនេយ្យករសាធារណៈ ព្រមជាមួយនឹងការពង្រឹងមុខងារអធិការកិច្ចជាយថាហេតុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាយន្តការប្រតិតុល្យការ (check and balance)។
- ធ្វើស្វ័យនីយកម្មជាបណ្តើរៗនៃរបបរបាយការណ៍ហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ និងបង្កើនសមត្ថភាព រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យធ្វើរបាយការណ៍លទ្ធផលនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ។



ដូចនេះ, ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ មិនត្រឹមតែបានកំណត់ទិសដៅ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសង្គតិភាពជាមួយនឹងប្រព័ន្ធថវិកាជាតិតាមអភិក្រម ***សាមញ្ញ ទន់ភ្លន់ តម្លាភាពនិងគណនេយ្យភាព*** ស្របទៅតាមសមត្ថភាព និងបរិការណ៍ជាក់ស្តែងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនោះទេ ប៉ុន្តែការវិភាជ និងការអនុវត្តថវិកា ក៏ត្រូវបានផ្តល់សិទ្ធិស្វ័យសម្រេច និងគណនេយ្យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផងដែរ។■

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ*

# សញ្ញាណទូទៅ នៃចំណូលមិនមែនសារពើពន្ធនៅកម្ពុជា

*យោងតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ របស់កម្ពុជាឆ្នាំ២០០៨ ធនធានអចិន្ត្រៃយ៍របស់រដ្ឋមាន ចំណូលចរន្ត (ចំណូលសារពើពន្ធ, ចំណូលមិនមែនសារពើពន្ធ, និងចំណូលតាមដីការ) និងចំណូលមូលធន (ចំណូលពីប្រភពផ្ទាល់, ចំណូលពីប្រភពខាងក្រៅ, និងចំណូលតាមដីការ)។*

ចំណូលសារពើពន្ធ សំដៅដល់ចំណូលបានពីពន្ធ និងអាករក្នុងប្រទេស និងពន្ធនិងអាករលើពាណិជ្ជកម្មក្រៅប្រទេស និងចំណូលសារពើពន្ធដទៃទៀត, ឯចំណូលមិនមែនសារពើពន្ធរួមមានចំណូលបានពីការចាត់ចែង ការធ្វើអាជីវកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋ ផលបានមកពីសម្បទាន កម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម ការឧបត្ថម្ភ និងតាមដានចំណូលសារពើពន្ធ (ក្រៅពីអាករពាណិជ្ជកម្ម), អគ្គនាយកដ្ឋានគយនិងរដ្ឋាករទទួលខុសត្រូវលើការប្រមូល និងតាមដានចំណូលសារពើពន្ធ (សម្រាប់តែអាការពាណិជ្ជកម្ម), អគ្គនាយកដ្ឋានទ្រព្យ-សម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធទទួលខុសត្រូវពិនិត្យ និងតាមដានការប្រមូលចំណូលមិនមែនសារពើពន្ធ, អគ្គ-នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទទួល រៀល នៅឆ្នាំ២០១៨ ដែលមានកំណើនប្រមាណជិត ២ដង ក៏ប៉ុន្តែបើមើលពីតម្រូវការ នៃចំណាយថវិកាជាតិសរុបប្រចាំឆ្នាំ ភាគរយនៃចំណូលមិនមែនសារពើពន្ធ និងចំណាយថវិកាជាតិសរុបមានការធ្លាក់ចុះពីប្រមាណ ១៦% ដល់ ១៣,៤២% ពីឆ្នាំ ២០១១ ដល់ឆ្នាំ២០១៨ ដោយសារយន្តការពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលសារពើពន្ធ។




*ក្រាប ១. និន្នាការនៃចំណូលមិនមែនសារពើពន្ធ នឹងច្បាប់ថវិកា និងចំណាយថវិកាជាតិសរុប*[២]

អំណោយ ផលហិរញ្ញវត្ថុផលផ្សេងៗ និងផលពិសេស និងចំណូលមិនមែនសារពើពន្ធដទៃទៀត[១] ។

ក្នុងទិដ្ឋភាពនៃយន្តការស្ថាប័នវិញ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការឱ្យរាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យលើថវិកា និងគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអគ្គនាយក-ដ្ឋានពន្ធដារទទួលខុសត្រូវលើការប្រមូល ខុសត្រូវលើការប្រមូល និងតាមដានចំណូលពីឧស្សាហកម្មល្បែង, ការបញ្ចាំ, សញ្ញាបណ្ណ និងធានារ៉ាប់រង។

តាមរយៈក្រាបទី១. និន្នាការចំណូលមិនមែនសារពើពន្ធ ធៀបនឹងច្បាប់ថវិកា និងចំណាយថវិកាជាតិសរុប ចំណូលមិន-មែនសារពើពន្ធរបស់រាជរដ្ឋាភិបាល បានបន្តកើនឡើងពី ១.១៩៣.៦៥២ លានរៀល ពីឆ្នាំ២០១១ ទៅដល់ ២.៣៨៤.៤៤៤ លាន

## និយមន័យ និងប្រភេទ នៃចំណូលមិន-មែនសារពើពន្ធ

*"ចំណូលមិនមែនសារពើពន្ធសំដៅដល់ចំណូលបានមកពីការចាត់ចែងការធ្វើអាជី-វកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋផលបានពីសម្បទាន កម្រៃបានពីសេវាសាធារណៈ ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយ ផលហិរញ្ញវត្ថុផលផ្សេងៗ និងផលពិសេស និងចំណូលផ្សេងទៀត*

*១. ប្រភព÷ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨*

*២. ប្រភព÷អគ្គនាយកដ្ឋានរតនាគារជាតិ កសហវ*

*ដែលត្រូវបានកំណត់ថាជាចំណូលមិនមែនសារពើពន្ធដទៃទៀត" ។*

យោងតាមអនុក្រឹត្យ លេខ ៧២ អនក្រ.បក ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ចំណូលមិនមែនសារពើពន្ធនៅកម្ពុជា ត្រូវបានបែងចែកជាប្រាំប្រភេទ÷

**១. ចំណូលពីទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់ចំណូលដែលទទួលបានពីការចាត់ចែងការធ្វើអាជីវកម្ម និងផលបានពីសម្បទានលើទ្រព្យសម្បត្តិរដ្ឋ។ បច្ចុប្បន្ន ប្រភពចំណូលនេះ រួមមានមកពី÷ផលនេសាទ, ផលព្រៃឈើ, សម្បទានរ៉ែ និងប្រេងកាត, ការជួលអចលនទ្រព្យ ។ល។

**២. ចំណូលពីសហគ្រាសសាធារណៈ** និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត សំដៅដល់ចំណូលពីការបង់ភាគលាភ (ផ្នែកបានពីការបែងចែកប្រាក់ចំណេញ) និងអតិរេកថវិកា (ចំនួនទឹកប្រាក់ដែលត្រូវបង់ចូលថវិការដ្ឋ តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការទទួលស្គាល់ពីអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ) របស់សហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត។ ជាទូទៅចំណូល នៃសហគ្រាសសាធារណៈ និងអង្គភាពស្វ័យភាពនីមួយៗ ត្រូវបានគ្រប់គ្រងដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

**៣. ចំណូលពីសេវាសាធារណៈ** សំដៅដល់ចំណូល ដែលប្រមូលបានពីកម្រៃនៃការប្រើប្រាស់សេវាសាធារណៈ ចំពោះសេវាបង់ថ្លៃរបស់រដ្ឋ ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច ក្នុងគោលដៅបម្រើសេវាសាធារណៈ។ ចំណូលប្រភេទនេះ ត្រូវបានបែងចែកទៅតាមវិស័យដែលមាន÷ វិស័យរដ្ឋបាលទូទៅ, វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ, វិស័យសង្គមកិច្ច, វិស័យសេដ្ឋកិច្ច, និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ រាល់ប្រភេទសេវាសាធារណៈកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួង-ស្ថាប័ន ឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃករណីចំណូលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៤. ចំណូលពីការផាកពិន័យ និងការដាក់**ទណ្ឌកម្ម សំដៅដល់ចំណូល ដែលបានពីការពិន័យជាប្រាក់ដែលធ្វើឡើងដោយស្ថាប័នរដ្ឋបាល ឬស្ថាប័នតុលាការ ចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តធរមាន និងផលពីការរឹបអូសជាសម្បត្តិរដ្ឋ ដោយសេចក្តីសម្រេចស្ថាពររបស់តុលាការសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ជាតិ ឬថវិកាថ្នាក់ក្រោមជាតិ។

**៥. ចំណូលមិនមែនសារពើពន្ធផ្សេងទៀត** មានដូចជា÷ ចំណូលពីទ្រព្យនិទាឃាទភាព, ប្រទានកម្ម, អច្ច័យទាន, ចំណូលពីផលហិរញ្ញវត្ថុ, ចំណូលពីឧស្សាហកម្មហិរញ្ញវត្ថុ, ផលផ្សេងៗ, និងផលពិសេសផ្សេងៗទៀត។

## យន្តការគ្រប់គ្រងចំណូលមិនមែនសារ-ពើពន្ធ

ការប្រមូលចំណូលមិនមែនសារពើពន្ធនៅថ្នាក់ក្រោមជាតិ តម្រូវឱ្យក្រសួង-ស្ថាប័នមានចំណូល ដែលមានប្រមាណជាង ២៣, ទទួលខុសត្រូវក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ, ដឹកនាំ អនុវត្ត និងគ្រប់គ្រងការប្រមូលចំណូល, កត់ត្រា, រាយការណ៍ស្ថិតិចំណូល, តឹងទារបំណុល និងដោះស្រាយវិវាទផ្សេងៗ រួមទាំងការស្នើសុំវិធានការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជារៀងរាល់ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ របាយ-ការណ៍នៃការអនុវត្តចំណូលមិនមែនសារពើពន្ធនៃក្រសួង-សាប័ន ត្រូវរាយការណ៍ជូន អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃ កសហវ។

រីឯការនៅថ្នាក់ក្រោមជាតិវិញ មន្ទីរសេដ្ឋ-កិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនា-ធិការ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវ ដូចក្នុងយន្តការថ្នាក់ជាតិដែរ តែត្រូវបញ្ជូនរបាយការណ៍មកកាន់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



**គោលការណ៍បង់ថវិកានៃចំណូលមិនមែនសារពើពន្ធ អាចប្រព្រឹត្តតាមរយៈ÷**

(១). គណនីទោលរបស់រតនាគារ ឬធនាគារដៃគូ,

(២). រដ្ឋទេយ្យករចំណូល ឬភ្នាក់ងារប្រមូលចំណូល ដោយធ្វើជាសលាកបត្រចំណូលថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ។

ចំពោះការបង់ ចំណូលមិនមែនសារពើពន្ធនៅថ្នាក់ជាតិ, ភាគីបង់ចំណូល អាចអនុវត្តត្រង់ទៅកាន់គណនីទោល ឬ ធនាគារពាណិជ្ជដៃគូ ឬក្រសួង-ស្ថាប័ន ឬអង្គភាពប្រមូលចំណូល ហើយចំណូលដែលបានបង់ នឹងត្រូវបញ្ចូនបន្តទៅគណនេយ្យទោលរតនាគារជាតិ។ រីឯនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ភាគីបង់ចំណូល អាចធ្វើការទូទាត់តាមរយៈមន្ទីរ ឬអង្គភាពប្រមូល ឬផ្ទាល់ទៅអនុគណនីទោល ដែលនឹងបន្តទៅកាន់គណនីទោលនៃរតនាគារជាតិ

ស្របនឹងចលនាការប្រកបដោយជវភាពនៃបច្ចេកវិទ្យាព័ត៌មាន, អភិបាលកិច្ចអេឡិចត្រូនិច និងសេដ្ឋកិច្ចឌីជីថលស្ទើរបានក្លាយទៅជា របៀបវារៈនយោបាយរបស់រដ្ឋាភិបាលជាសាកល។ ទំនើបកម្មយន្តការ នៃការគ្រប់គ្រងចំណូល មិនមែនសារពើពន្ធ

*ចំណូលមិនមែនសារពើពន្ធ សំដៅដល់ចំណូលបានមកពីការចាត់ចែង ការធ្វើអាជីវកម្ម និងការលក់ទ្រព្យសម្បត្តិរដ្ឋ ផលបានពីសម្បទាន កម្រៃបានពីសេវាសាធារណៈ ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយ ផលហិរញ្ញវត្ថុ ផលផ្សេងៗ និងផលពិសេស និងចំណូលផ្សេងទៀត ដែលត្រូវបានកំណត់ថាជាចំណូលមិនមែនសារពើពន្ធដទៃទៀត*

របស់រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ជាទិសដៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៥របស់រាជរដ្ឋាភិបាលកម្ពុជា ដោយការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព លើយន្តការ គ្រប់គ្រង តាមដាន និងវាយតម្លៃ ។ ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ NRMIS÷ Non-Tax revenue Management Information System ត្រូវបានបង្កើត និងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ ២០១៨។ ជាវឌ្ឍនភាពគិតត្រឹមចុងឆ្នាំ២០១៩, ប្រព័ន្ធ NRMIS ត្រូវបានអនុវត្តនៅគ្រប់ក្រសួង- ស្ថាប័ន ដែលប្រមូលចំណូលទាំង ២៣ហើយនឹងបន្តពង្រីកវិសាលភាពការអនុវត្តទៅតាមមន្ទីរជំនាញ និងសាលារាជធានី- ខេត្តទាំងអស់។ ជាទិសដៅបន្តប្រព័ន្ធ NRMIS មានគោលដៅក្នុងការកសាងបន្ថែមទូវ÷ ការទូទាត់ស្វ័យប្រវត្តិកម្ម តាមរយៈទូរស័ព្ទដៃ ឬកុំព្យូទ័រ ចូលទៅក្នុងធនាគារជាតិ ឬធនាគារដៃគូ តាមរយៈមុខងារទូទាត់ស្វ័យប្រវត្តិកម្ម (Online Payment), ការអភិវឌ្ឍកម្មវិធីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធលើឧបករណ៍ឆ្លាតវៃ, និងការដាក់ឱ្យដំណើរការមុខងារថ្មីនៅទូទាំងប្រទេសទាំងស្ថាប័នរដ្ឋ និងភាគីឯកជន៕■

*រៀបចំដោយ÷ ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ អ.គ.ហ.*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....៦៤.....អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស. ៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១១/០១៧ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

១

# ការកែទម្រង់នៃការបើកផ្តល់បៀវត្សរ៍តាមនីតិវិធីថ្មី

*សមិទ្ធផលដែលបានសម្រេចជាបណ្តើរៗ កន្លងមកនេះ បាននិងកំពុងធ្វើឱ្យវិស័យហិរញ្ញវត្ថុសាធារណៈ ដើរតួនាទីកាន់តែសំខាន់ នៅក្នុងការចូលរួមធានាឱ្យប្រទេសជាតិមានស្ថិរភាព និងឯករាជ្យភាព ព្រមទាំងកាន់តែមានការអភិវឌ្ឍឈានឡើង ។*



ស្ថិតក្នុងទិសដៅនេះ, រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងអាណត្តិទី៦បានផ្តោតលើការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់ជីវភាព និងសេចក្តីត្រូវការប្រចាំថ្ងៃ របស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀតក៏ដូចជាអតីត មន្ត្រីរាជការស៊ីវិល អតីតយុទ្ធជន ដោយបានចាប់ផ្តើមកែទម្រង់លើការបើកផ្តល់ប្រាក់បៀវត្សរ៍នៅរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ។

ដើម្បីឱ្យដំណើរការ នៃការផ្តល់បៀវត្សរ៍នៅរៀងរាល់ពីរសប្តាហ៍ម្តង ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត អតីតមន្ត្រី រាជការស៊ីវិល និងអតីតយុទ្ធជនទៅបានរលូនទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវសារាចរលេខ ០១ សរ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់នីតិវិធី សម្រាប់បើកផ្តល់ប្រាក់របបសន្តិសុខសង្គមរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជននិងអ្នកនៅក្នុងបន្ទុក និងសារាចរលេខ ០៧ សរ ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរ៍រៀងរាល់ ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀត។ ដោយមើលឃើញអំពីគុណប្រយោជន៍ នៃការបើកផ្តល់បៀវត្សរ៍នៅ ពីរសប្តាហ៍ម្តងក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ ក៏បានស្ម័គ្រចិត្តចូលរួមអនុវត្តខ្លឹមសារសារាចរលេខ ០៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ។

*មកដល់បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាបានកំពុងដំណើរការយ៉ាងរលូនក្នុងការអនុវត្តនីតិវិធីការបើកផ្តល់បៀវត្សរ៍រៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀតសម្រេចបានជោគជ័យគួរជាទីមោទនៈ ហើយបន្តប្តេជ្ញាចិត្តពង្រឹងការបើកផ្តល់ប្រាក់បៀវត្សរ៍នេះ ឱ្យបានទាន់ពេលវេលាចិតថេរជានិរន្តរ ។*

ដើម្បីឱ្យកិច្ចការនេះដំណើរការបើកផ្តល់បៀវត្សរ៍នៅរៀងរាល់ពីរសប្តាហ៍ម្តង ដែលចាប់អនុវត្តពី ខែមករា ឆ្នាំ២០១៩ ប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសារាចរណែនាំលំអិតលេខ ០១១ សហវ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ ដើម្បីសម្រួលនីតិវិធីអនុវត្តបន្ថែម ទៀតដល់ក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋ-

បាលថ្នាក់ក្រោមជាតិ។ ដោយមានការគិតគូយ៉ាង ហ្មត់ចត់ ពីសំណាក់ថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសអគ្គនាយកដ្ឋានរតនាគារជាតិ បានសិក្សា និង ដាក់ឱ្យដំណើរការទូទាត់ប្រាក់បៀវត្សតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារជាតិនៃកម្ពុជា (Electronic Fund Transfer) ដើម្បីពន្លឿនការបើកផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងៗ អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ឱ្យបានឆាប់រហ័ស និងទាន់ពេល វេលាតាមកាលកំណត់ពោលគឺ នៅសប្តាហ៍ទី២ និងនៅសប្តាហ៍ទី៤ ក្នុងខែនីមួយៗ ចាប់ពីខែមករា ឆ្នាំ២០១៩។ ដោយមានកិច្ចសហការយ៉ាងសកម្មពីក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ធនាគារជាតិ នៃកម្ពុជា និងធនាគារពាណិជ្ជដៃគូ នៅថ្នាក់កណ្តាលការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនៅរៀងរាល់ ពីរសប្តាហ៍ម្តង នៃខែនីមួយៗទទួលបានជោគជ័យយ៉ាងត្រចះត្រចង់។ ដើម្បីពន្លឿន និងពង្រឹងការងារនេះ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត អគ្គនាយកដ្ឋានរតនាគារជាតិបាននិងកំពុងសិក្សាប្រព័ន្ធទូទាត់តាមរយៈអេឡិចត្រូនិចជាមួយធនាគារពាណិជ្ជដៃគូផងដែរ ដើម្បីពង្រីកវិសាលភាព នៃការដាក់ឱ្យ ប្រើប្រាស់ប្រព័ន្ធទូទាត់តាមរយៈអេឡិចត្រូនិចនេះ ដល់រតនាគាររាជធានី ខេត្ត។ តាមរយៈប្រព័ន្ធទំនាក់ទំនងសង្គម អគ្គនាយកដ្ឋានរតនាគារជាតិបានធ្វើការយ៉ាងសកម្មជាមួយក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ ក្រោមជាតិ ធនាគារជាតិ នៃកម្ពុជាធនាគារពាណិជ្ជដៃគូ នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋានក្នុងការតាមដានដោះស្រាយបញ្ហាប្រឈម និងចាត់វិធានការទាន់ពេលវេលា ដើម្បីធានាបានការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភ ជូនដល់មន្ត្រីរាជការទាំងអស់តាមការកំណត់។អគ្គនាយកដ្ឋាន រតនាគារជាតិក៏បានធ្វើការជូនដំណឹងជាសាធារណៈ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ Facebook របស់ខ្លួន ដើម្បីជ្រាបជាព័ត៌មាននៅរៀងរាល់លើក ដែលខ្លួនបានបញ្ចប់ការងារបើកផ្តល់ បៀវត្ស និងប្រាក់ឧបត្ថម្ភជូនក្រសួង-ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

មកដល់បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានកំពុងដំណើរការយ៉ាងរលូនក្នុងការអនុវត្តនីតិវិធីការបើក ផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តង ក្នុងខែនីមួយៗ ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងទៀតសម្រេចបានជោគជ័យគួរជាទីមោទនៈ ហើយបន្តប្តេជ្ញាចិត្តពង្រឹង ការបើកផ្តល់ប្រាក់បៀវត្សនេះ ឱ្យបានទាន់ពេលវេលាឋិតថេរជានិរន្តរ ៕■

*រៀបចំដោយ៖ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានរតនាគារជាតិ*

## គំនូសបំព្រួញការប្រែប្រួលនីតិវិធីអនុវត្តការចារទូទាត់បៀវត្ស



# វឌ្ឍនភាពនៃការអនុវត្តគម្រោង FMIS ឆ្នាំ២០១៩

*ការអនុវត្តគម្រោង FMIS សម្រេចបាននូវវឌ្ឍនភាពក្នុងរង្វង់ ៩០% សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩ ។*

ផ្អែកលើលទ្ធផលនេះប្រព័ន្ធ FMIS ត្រូវបានជឿជាក់យ៉ាងច្បាស់ថានឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅតាមក្រសួង-ស្ថាប័នចំនួន ១៧ បន្ថែមទៀត នៅដើមឆ្នាំ២០២០ ដែលសម្រេចបាននូវគោលដៅពង្រីកការអនុវត្តគម្រោង FMIS ជំហានទី២ (២០១៧-២០២០) ទៅគ្រប់ក្រសួង-ស្ថាប័នទាំងអស់ដើម្បីគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុ និងការអនុវត្តថវិកាតាមប្រព័ន្ធ FMIS ។

បើទោះបីជាជួបប្រទះបញ្ហាប្រឈមមួយចំនួននៅក្នុងដំណើរការ នៃការអនុវត្តគម្រោង FMIS ក្នុងត្រីមាសទី ៣ ឆ្នាំ២០១៩ យ៉ាងណាក្តីការអនុវត្តគម្រោង FMIS នៅតែសម្រេចបានវឌ្ឍនភាពការងារគន្លឹះជាច្រើន ដូចជា÷

***(១). ការត្រៀមលក្ខណៈក្នុងការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS ទៅក្រសួង-ស្ថាប័ន ១៧ ថ្មី ÷***

- បានរៀបចំការបណ្តុះបណ្តាលអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ចំនួន ៣៧២ រូប ដែលនឹងប្រើប្រាស់ប្រព័ន្ធ FMIS នៅដើមឆ្នាំ ២០២០ ខាងមុខ ។
- ដំឡើងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា-ព័ត៌មានរួចរាល់ ពាក់ព័ន្ធនឹងការតភ្ជាប់បណ្តាញ Network (LAN), ការតភ្ជាប់បណ្តាញអគ្គិសនី, ដំឡើងទូរ Rack និងការតភ្ជាប់ Leased Line ទៅមជ្ឈមណ្ឌលទិន្នន័យ។
- បានកែសម្រួលធ្វើបច្ចុប្បន្នភាពកម្មវិធីប្រព័ន្ធ FMIS Software រួចរាល់ ឆ្លើយតបនឹងបញ្ជីឈ្មោះអ្នកប្រើប្រាស់ និងលំហូរការងារ ដែលបានផ្តល់ជូនពី ក្រសួង-ស្ថាប័ន។


រូបភាពក្នុងវគ្គបណ្តុះបណ្តាលអំពីមុខងាររបស់ប្រព័ន្ធ FMIS នៅសាកលវិទ្យាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

***(២). រៀបចំរួចរាល់នូវឯកសារតម្រូវការប្រើប្រាស់សម្រាប់មុខងារថ្មីចំនួន ២ គឺ មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្ម និងបានរៀបចំសេចក្តីព្រាងឯក-សារដេញថ្លៃរួចរាល់សម្រាប់មុខងារទាំងពីរនេះ។***

***(៣). ការសិក្សានិងរៀបចំប្រព័ន្ធសន្ទាន-កម្មជាមួយប្រព័ន្ធខាងក្រៅបន្ថែមទៀត÷***

- បានបញ្ចប់នូវការរៀបចំផ្នែកបច្ចេក-ទេសលើប្រព័ន្ធសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និងកំពុងដំណើរការធ្វើតេស្តសាកល្បង
- ការងាររៀបចំប្រព័ន្ធសន្ទានកម្មទិន្នន័យជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ សម្រេចបាន ៥០% លើផ្នែកបច្ចេកទេស
- សម្រេចបាននូវលទ្ធផល នៃការសិក្សាលទ្ធភាពបច្ចេកទេស ក្នុងការសន្ទានកម្មជាមួយប្រព័ន្ធបៀវត្ស មន្ត្រីរាជការ Payroll នៃក្រសួងមុខងារសាធារណៈដោយក្រសួងមុខងារសាធារណៈត្រូវកែសម្រួល ប្រព័ន្ធ Payroll មួយចំនួន មុននឹងធ្វើសន្ទានកម្មបាន និងបានរៀបចំរបាយការណ៍សង្ខេបជាមួយនឹងការស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិ-រញ្ញវត្ថុ ក្នុងការរៀបចំប្រកាសអន្តរក្រសួងបង្កើតក្រុមការងារបច្ចេកទេសរៀបចំការងារនេះ រវាងក្រុមការងារគ្រប់គ្រងគម្រោង FMIS និងក្រុមការងារប្រព័ន្ធ Payroll ។

***(៤). ការងារកែសម្រួល និងតម្រង់ទិសនីតិវិធីអនុវត្តការងារ (Business Process Streamline)÷***

- បានរៀបចំសេចក្តីព្រាង ផែនការយុទ្ធ-សាស្ត្រតម្រង់ទិស និងកែសម្រួលនីតិវិធីអនុវត្តការងារក្នុងក្របខណ្ឌនៃការគ្រប់គ្រង

*ផែនការយុទ្ធសាស្ត្រតម្រង់ទិស និងកែសម្រួលនីតិវិធីអនុវត្តការងារក្នុងក្របខណ្ឌ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្សារភ្ជាប់នឹងការប្រើប្រាស់ប្រព័ន្ធ FMIS ដោយចាប់ផ្តើមសិក្សាជាជំហានៗលើនីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងការអនុវត្តចំណាយថវិកាផ្អែកតាមអភិក្រមពីហានិភ័យទាប ទៅខ្ពស់ ។*

ហិរញ្ញវត្ថុសាធារណៈផ្សារភ្ជាប់នឹងការប្រើប្រាស់ប្រព័ន្ធ FMIS ដោយចាប់ផ្តើមសិក្សាជាជំហានៗលើនីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងការអនុវត្តចំណាយថវិកា ផ្អែកតាមអភិក្រមពីហានិភ័យទាបទៅខ្ពស់ (ទី១. ទូទាត់ចំណាយពាក់ព័ន្ធបៀវត្ស, ទី២. ទូទាត់ចំណាយព្រមលើមុខសញ្ញាចំណាយដែលប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង- ស្ថាប័ន អនុម័តក្នុងនាមជាអភិបាលហិរញ្ញវត្ថុ, ទី៣. ទូទាត់ចំណាយរជ្ជទេយ្យបុរេប្រទាន និងចំណាយព្រមផ្សេងៗ និងទី៤. ទូទាត់លើចំណាយដែលមានធានាចំណាយ) ។

- បានសិក្សាលម្អិតអំពីលទ្ធភាពក្នុងការកែសម្រួល និងតម្រង់ទិសនីតិវិធីអនុវត្តការងារទាត់បៀវត្ស ក្នុងក្របខណ្ឌ កសហវ



*កម្មវិធី "ការចែករំលែកគន្លឹះសំខាន់ៗក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ក្រសួង-ស្ថាប័ន" នៅថ្ងៃទី៤ តុលា ឆ្នាំ២០១៩*

និងសម្រេចបានលទ្ធផល ក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសនូវការកាត់បន្ថយពី ២៧កន្លែង ចូលរួមនៅក្នុងនីតិវិធីមកត្រឹម ១៧ កន្លែង កន្លែង (កាត់បន្ថយ ១០ កន្លែង), និងបានទទួលការណែនាំពីថ្នាក់ដឹកនាំ កសហវ ក្នុងការសិក្សាបន្ថែមលើលទ្ធភាពក្នុងការប្រែក្លាយនីតិវិធីនេះ រួមទាំងនីតិវិធីទូទាត់ត្រង់ដែលមានហានិភ័យទាប ឱ្យក្លាយជានីតិវិធីអនុវត្តការងារស្វ័យប្រវត្តិកម្ម តាមប្រព័ន្ធ FMIS ទាំងស្រុងតែម្តង។

### *(៥). ការពង្រឹងការអនុវត្តប្រព័ន្ធ FMIS*

- បានធ្វើការផ្សព្វផ្សាយនូវគន្លឹះថ្មីៗពាក់ព័ន្ធនឹងប្រព័ន្ធ FMIS ជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រសួង- ស្ថាប័នចំនួន ១០ ដែលបានអនុវត្តក្នុងឆ្នាំ ២០១៨
- បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធជំនួយគាំទ្រថ្មីដែលមានឈ្មោះថា PK-The Helper ដើម្បីផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់បំពេញនូវសំណើពាក់ព័ន្ធនឹងការកែសម្រួល ឬស្នើរបាយការណ៍ថ្មីៗចេញពីប្រព័ន្ធ FMIS ។
- បានសម្រេចការអភិវឌ្ឍរបាយការណ៍សម្រាប់ភ្ជាប់ក្នុងច្បាប់ទូទាត់ប្រមាណ ៧០% និងកំពុងបន្តកិច្ចការនេះយ៉ាងសកម្មជាមួយអគ្គនាយកដ្ឋានគន្លឹះ បើទោះបីជាមានភាពស្មុគស្មាញច្រើន ក្រុមការងារនៅតែប្តេជ្ញាសម្រេចឱ្យបានលទ្ធផលជាអតិបរមានៅដំណាច់ឆ្នាំនេះ ។
- បានបន្តការងារផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈគេហទំព័របណ្តាញសង្គមជាដើម រួមមាន ព័ត៌មាន វីដេអូ និងព្រឹត្តិបត្រព័ត៌មាន អំពីគម្រោង និង ប្រព័ន្ធ FMIS ៕■

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*



*កិច្ចប្រជុំ ពិភាក្សាអំពីការងារកែសម្រួល និងតម្រង់ទិសនីតិវិធីអនុវត្តការងារ*

# ការត្រៀមខ្លួនសម្រាប់ដំហានបន្ទាប់ "គណនេយ្យភាពសមិទ្ធកម្ម"

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកែទម្រង់រយៈពេលវែង ដែលមានចក្ខុវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម គឺផ្លាស់ប្ដូរប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅឧត្តមានុវត្ត អន្តរជាតិ ដោយបាននិងកំពុងកសាង និងពង្រឹងសមាសធាតុស្នូលទាំង ៤ រួមមាន "ការកែលម្អប្រព័ន្ធ, ក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន និងធនធានមនុស្ស"។*




ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺត្រូវរៀបចំឡើងតាមលំដាប់លំដោយស្រប តាមបរិបទនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

ក្នុងន័យនេះ,កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី០៥ ខែធ្នូ២០០៤ ដោយប្រកាន់យកអភិក្រមជាខឿននិងអនុវត្តជាដំណាក់កាលរួមមាន ជាអាទិ៍÷

- **ដំណាក់កាលទី១** "ភាពជឿទុកចិត្តនៃថវិកា" ពីឆ្នាំ២០០៥-២០០៨
- **ដំណាក់កាលទី២** "ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ" ពីឆ្នាំ២០០៩-២០១៥
- **ដំណាក់កាលទី៣** "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ពីឆ្នាំ២០១៦-២០២០
- **ដំណាក់កាលទី៤** "គណនេយ្យភាពសមិទ្ធកម្ម" ពីឆ្នាំ២០២១-២០២៥។

រហូតមកដល់ពេលនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺស្ថិតក្នុងដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ដោយគោលដៅអាទិភាពចំនួន ០៣ រួមមាន (១). ការពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល, (២). ការពង្រឹង និងពង្រីកការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៣). ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី។

ទោះបីជារាជរដ្ឋាភិបាល សម្រេចបាននូវវឌ្ឍនភាពជាច្រើនក្នុងរយៈពេល១៥ឆ្នាំកន្លងមកនេះ ដើម្បីសម្រេចបាន ទិសដៅនៃការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ

*ការរៀបចំកម្មវិធីរបស់ក្រសួង-ស្ថាប័នមួយចំនួននៅចំណុះទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលធ្វើឱ្យមានការលំបាកខ្លះក្នុងការផ្សារភ្ជាប់កម្មវិធីទៅនឹងគោលបំណងគោលនយោបាយ ក៏ដូចជាការផ្សារភ្ជាប់កម្មវិធីទៅនឹងការអនុវត្តជាក់ស្តែង ។*

**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**ផែនការសកម្មភាពរួមដំណាក់កាលទី៣**
**សម្រាប់អនុវត្តឆ្នាំ ២០២០**

(CAP3 2020)

ផ្នែកទី ១÷ បន្តពង្រឹងភាពទុកចិត្តបាននៃថវិកា
ផ្នែកទី ២÷ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ
ផ្នែកទី ៣÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
ផ្នែកទី ៤÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់
ផ្នែកទី ៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព

សាធារណៈ ស្របតាមនិយាមនិងឧត្តមានុវត្តជាអន្តរជាតិ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានថ្លែងក្នុងកិច្ចប្រជុំត្រួតពិនិត្យឆ្នាំ២០១៨ កន្លងទៅថា ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈកំពុងបន្តជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចតទៅ÷

**ទី១.** ការកៀរគរចំណូល ទទួលបានលទ្ធ-ផលល្អ ប៉ុន្តែនៅមិនទាន់មានចីរភាពពេញលេញនៅឡើយ។ ម្យ៉ាង, ទោះបីជាការ

*ភាពចាំបាច់ក្នុងការបន្តការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ និងឆ្លើយតបទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសឆ្ពោះទៅ* ***ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម*** *។*

ប្រមូលចំណូលពន្ធបានកៀកនឹងសក្តា-នុពល, ប៉ុន្តែរចនាសម្ព័ន្ធចំណូលមិនទាន់មានភាពរឹងមាំអាចធានាបាននូវចីរភាពក្នុងរយៈពេលវែងនៅឡើយ។ ម្យ៉ាងទៀត ការប្រមូលចំណូលមិនមែនសារពើពន្ធក៏នៅមានសក្តានុពលគួរកត់សម្គាល់ ។ លើសពីនេះ, ការធ្វើស្ថាបនីយកម្មយន្តការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធនៅមានលទ្ធភាពកែលម្អបន្ថែមទៀត។

**ទី២.** ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ទោះបីជាសម្រេចបានជាសារវ័ន្តជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ, ប៉ុន្តែ នៅមិនទាន់អាចផលិត បាននូវរបាយការណ៍ឲ្យបានគ្រប់ជ្រុងជ្រោយ និងមិនទាន់បានធ្វើស្វ័យប្រវត្តិកម្មការអនុវត្តថវិកានៅឡើយ មានន័យថា ការអនុវត្តថវិកានៅត្រូវប្រើក្រដាសស្នាមផង និង ប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផង ដែលការងារមួយចំនួនមានលក្ខណៈត្រួតជាន់គ្នា ។

**ទី៣.** ការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកាពិតមែនតែត្រូវបានដាក់ឲ្យអនុវត្តនៅគ្រប់ក្រសួង/ ស្ថាប័ន ថ្នាក់ជាតិ ប៉ុន្តែគុណភាពនៃកម្មវិធីនៅមិនទាន់បានល្អពេញលេញ តាមការចង់បាននៅឡើយ, ទាំងខ្លឹមសារ, ទាំងរចនាសម្ព័ន្ធ និងទាំងសមិទ្ធកម្ម ។ លើសពីនេះ, ការរៀបចំកម្មវិធីរបស់ក្រសួង- ស្ថាប័នមួយចំនួននៅចំណុះទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលដែលធ្វើឲ្យមានការលំបាកខ្លះក្នុងការផ្សារភ្ជាប់កម្មវិធីទៅនឹងគោលបំណងគោលនយោបាយក៏ដូចជាការផ្សារភ្ជាប់កម្មវិធី ទៅនឹងការអនុវត្តជាក់ស្តែង ។ ម៉្យាងទៀត, ក្រសួង- ស្ថាប័នមួយចំនួន

ក៏នៅរក្សាការគ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថាថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ក៏មានតិចតួចដែរ ។

**ទី៤.** នីតិវិធី នៃការអនុវត្តថវិកាត្រូវបានពន្លឿនច្រើន, ប៉ុន្តែនៅមិនទាន់អាចធានាបាននូវភាពឆាប់រហ័ស, ភាពត្រឹមត្រូវ និងភាពអាចប៉ាន់ប្រមាណបាន តាមការរំពឹងទុកនៅឡើយ ។ ការងារនេះមិនមែនជាការងារដាច់ដោយឡែករបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនោះទេ ប៉ុន្តែក៏ជាការងារផ្ទាល់របស់ក្រសួងស្ថាប័នផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលមួយចំនួនហើយលើបញ្ហានេះ, ក៏ប៉ុន្តែក្រសួង-ស្ថាប័នសាមី ក៏ត្រូវខិតខំកាត់បន្ថយនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាព និង តម្លាភាពផ្ទៃក្នុងរបស់ខ្លួនផងដែរ ។

**ទី៥.** ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅតែជាបញ្ហាប្រឈមសំខាន់ ដែលជាចំណែកមួយនៃការគ្រប់គ្រងធនធានសាធារណៈ។ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ, ទាំងជាទ្រព្យហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិមិនមែនហិរញ្ញវត្ថុ, ត្រូវការនូវការយកចិត្តទុកដាក់ច្រើនថែមទៀត, ខណៈដែលផ្នែកផ្សេងៗនៃការកែទម្រង់កំពុងមានវឌ្ឍនភាពល្អទៅមុខ។

**ទី៦.** ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម ទើបត្រូវបានចាប់ផ្តើមអនុវត្តសាកល្បងនៅឆ្នាំ ២០១៩ សម្រាប់ថវិកាឆ្នាំ ២០២០-២០២២ ដើម្បីតម្រង់ទិសផែនការយុទ្ធសាស្ត្រថវិកា ឱ្យមានគុណភាពប្រសើរឡើង។ ជាមួយគ្នានេះ, ក្របខណ្ឌ នៃការគ្រប់គ្រងការវិនិយោគសាធារណៈក៏កំពុងតែស្ថិតនៅក្នុងដំណាក់កាល រៀបចំនៅឡើយ ។

**ទី៧.** ខណៈដែលការរៀបចំថវិកាត្រូវបានធ្វើឡើងតាមកម្មវិធី, ការគ្រប់គ្រងស្ថាប័នត្រូវធ្វើទំនើបកម្មថែមទៀត តាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនដល់អ្នកអនុវត្ត ដែលក្នុងនោះថ្នាក់ដឹកនាំ ឬគ្រប់គ្រងទទួលខុសត្រូវជាសំខាន់លើសមិទ្ធកម្ម ឬការត្រួតពិនិត្យលើលទ្ធផល នៃការអនុវត្ត, ចំណែកការទទួលខុសផ្នែកហិរញ្ញវត្ថុត្រូវធ្វើឡើងតាមរយៈការពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៃក្រសួង-ស្ថាប័ន។

**ទី៨.** ភាពចាំបាច់ក្នុងការបន្តការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ដើម្បីគាំទ្រ និងឆ្លើយតបទៅនឹងការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសឆ្ពោះទៅ "ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម"។

ការដោះស្រាយចំណុចទាំង ៨ ខាងលើ គឺជាមូលដ្ឋានគន្លឹះ សម្រាប់កសាងថ្នាលសម្រាប់ជំហានបន្ទាប់។ ជាមួយគ្នានេះ ដើម្បីត្រៀមខ្លួនជំហានបន្ទាប់ "គណនេយ្យភាពសមិទ្ធកម្ម" នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានកំពុងសិក្សាភាពគ្រប់ជ្រុងជ្រោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដោយផ្តោតសំណួរសំខាន់ចំនួន ៣ រួមមាន (១). តើសម្រេចអ្វីខ្លះ? (២). តើកំពុងនៅកន្លែងណា? និង (៣). តើត្រូវធ្វើអ្វីទៀត?




ក្នុងន័យនេះ **អ.គ.ហ.** បាននិងកំពុងត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់ ឧបករណ៍ចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ ដែលត្រូវប្រើប្រាស់យ៉ាងទូលំទូលាយប្រមាណជា ១៥០ ប្រទេសលើពិភពលោក។ លទ្ធផល នៃការសិក្សាខាងលើនឹងក្លាយជាមូលដ្ឋានសំខាន់សម្រាប់រៀបចំក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤ ដែលគ្រោងនឹងបញ្ចប់ក្នុងឆមាសទី១ ឆ្នាំ២០២០ ៕■

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*

# ទស្សនាទាននៃការរៀបចំសៀវភៅស្តីពី “ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-បទពិសោធន៍កម្ពុជា”

*ក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយនេះ កម្ពុជាមានកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ និងសម្រេចបានជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីពេលថ្មីៗកន្លងទៅ ។*

មុនសេដ្ឋកិច្ចមានការរីកចម្រើន កម្ពុជាបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះ បញ្ហាកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ បានបង្កើតឱ្យមានជាបំណុលកកស្ទះ ដែលមានបច្ច័យដល់ប្រសិទ្ធភាពនៃការវិភាជ និងប្រតិបត្តិការជាពិសេសការបើកបៀវត្សរ៍ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធមានភាពយឺតយ៉ាវ និងមិនទៀងទាត់; បញ្ហាប្រឈម នៃការផ្សារភ្ជាប់រវាងថវិកា និងគោលនយោបាយ ដែលមិនអាចធានាបាននូវប្រសិទ្ធភាព នៃការចំណាយ តាមវិស័យ។លើសពីនេះប្រព័ន្ធថវិកាកម្ពុជាផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការជាជាងការផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ។ ដោយប្រមើលមើលឃើញអំពីភាពចាំបាច់បន្ទាន់, រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានរយៈពេលវែង និងប្រកបដោយមហិច្ឆិតា។

ជាសារវតារ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាព ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០០៤ ក្នុងគោលបំណងកែប្រែជាជំហានៗ នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ឧត្តមានុវត្តន៍អន្តរជាតិដោយប្រកាន់យកអភិក្រមជាខឿន




និងបែងចែកជា ៤ ដំណាក់កាល។ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេល ជាង ១៥ ឆ្នាំមកនេះ ត្បិតកម្ពុជាសម្រេចបានសមិទ្ធផលជាច្រើន ប៉ុន្តែទ្រឹស្តីនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមិនទាន់មានការយល់ដឹងទូលំទូលាយ ជាពិសេសភាពចាំបាច់ និងសមាសធាតុនីមួយៗនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ រីឯបទពិសោធន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់កម្ពុជានៅមិនទាន់មានការចងក្រងជាសៀវភៅនៅឡើយ ចាប់តាំងពីមុនចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ការរៀបចំសៀវភៅស្តីពី “ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ–បទពិសោធន៍កម្ពុជា” គឺដើម្បីបង្ហាញអំពីសញ្ញាណទូទៅ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការផ្សារភ្ជាប់គ្នារវាងទ្រឹស្តីនិងការអនុវត្តជាក់ស្តែងព្រមទាំងបទពិសោធន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់បណ្តាប្រទេស OECD និងប្រទេសមួយចំនួន ដែលជាសមាជិកជាពិសេសបទពិសោធន៍ក្នុងការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទិសដៅនៃប្រព័ន្ធថវិកាកម្ពុជា ដោយផ្អែកលើឯកសារ ឬគតិយុត្តដែលមានស្រាប់ និងយុទ្ធសាស្ត្រថ្មីៗ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កិច្ចការនេះទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍន៍រួមមានសហភាពអ៊ឺរ៉ុប និងធនាគារពិភពលោកក្នុងការផ្តល់ជាជំនួយបច្ចេកទេសទាំងក្នុងការចូលរួមសរសេរ ការផ្តល់យោបល់ និងការកែសម្រួល។

## ❖ គោលបំណងនៃការរៀបចំសៀវភៅ

ដូចបានរៀបរាប់ខាងលើ, ទ្រឹស្តី និងសមាសធាតុ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅមិនទាន់មានការយល់ដឹង

*ការលើកកម្ពស់ការយល់ដឹងអំពីសមាសធាតុនីមួយៗ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការសិក្សាអំពីបទពិសោធន៍អន្តរជាតិ កាន់តែមានភាពចាំបាច់ ។*

ទូលំទូលាយ។ បទពិសោធន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការវិវឌ្ឍនៃប្រព័ន្ធថវិកាកម្ពុជា នៅមិនទាន់បានចងក្រង ជាសៀវភៅ នៅឡើយ ។ សៀវភៅស្តីពី "ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - បទពិសោធន៍កម្ពុជា" នឹងត្រូវរៀបចំឡើងក្នុងគោលបំណងទុកជាឯកសារគន្ធៈនិទ្ទេស និងជាជំនួយស្មារតីបន្ថែមសម្រាប់មន្ត្រីរាជការ និងសិស្ស-និស្សិត សិក្សាឈ្វេងយល់ឱ្យកាន់តែ ស៊ីជម្រៅអំពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា និងបណ្តាប្រទេសមួយចំនួនលើសកលលោក។

សៀវភៅស្តីពី "**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ – បទពិសោធន៍កម្ពុជា**" ផ្តោតលើទិដ្ឋភាពចំនួន ៤ ដូចខាងក្រោម៖

**១.** ទ្រឹស្តីសកល៖ សញ្ញាណទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**២.** បទពិសោធន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេស OECD ៖ អូស្ត្រាលី, បារាំង និង ស៊ុយអែត ។

៣. បទពិសោធន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់បណ្តាប្រទេសនៅតំបន់អាស៊ី៖ ហ្វីលីពីន, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី, ថៃឡង់ដ៍, និង វៀតណាម។

៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា៖ ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល, លំដាប់លំដោយ នៃការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, និងការប្រើប្រាស់ឧបករណ៍វាយតម្លៃហិរញ្ញវត្ថុសាធារណៈ (PEFA, OBS, TADAT, PIMA)។

ការសិក្សាអំពីបទពិសោធន៍កែទម្រង់របស់ប្រទេសដទៃ ដែលបូករួមទាំងកត្តាបច្ចេកទេស និងមិនមែនបច្ចេកទេស នឹងផ្តល់អត្ថប្រយោជន៍ដល់កម្ពុជា ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ❖ ការប្រើប្រាស់ឯកសារគន្ធៈនិទ្ទេស

ឯកសារដែលនឹងត្រូវយកមកពិនិត្យ និងពិភាក្សាសម្រាប់ជាគន្ធៈនិទ្ទេស រួមមាន៖ (១). យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល, (២). យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨, (៣). យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ (៤). យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, (៥). យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, (៦). យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, (៧). ចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣ ដំណាក់កាល (៧). របាយការណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុឆ្នាំ ២០១០ និង២០១៥, (៨). របាយការណ៍ត្រួតពិនិត្យវឌ្ឍនភាព នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ និងឯកសារពាក់ព័ន្ធផ្សេងទៀត រួមទាំងឯកសារពាក់ព័ន្ធនឹងបទពិសោធន៍អន្តរជាតិ។

ខណៈកម្មវិធីកែទម្រង់កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ អាចនឹងត្រូវបិទបញ្ចប់នៅឆ្នាំ ២០២០ និងឈានទៅអនុវត្តនូវដំណាក់កាលទី ៤ "គណនេយ្យភាពសមិទ្ធកម្ម" នៅឆ្នាំ២០២១ ខាងមុខ, ការអនុវត្តកម្មវិធីកែទម្រង់កាន់តែមានលក្ខណៈស្មុគស្មាញ។ ការលើកកម្ពស់ការយល់ដឹងអំពីសមាសធាតុនីមួយៗ នៃការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ និងការសិក្សាអំពីបទពិសោធន៍អន្តរជាតិ កាន់តែមានភាពចាំបាច់ ។ សៀវភៅស្តីពី "ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - បទពិសោធន៍កម្ពុជា" នឹងក្លាយជាឯកសារចែករំលែកចំណេះដឹងដ៏មានសារៈសំខាន់សម្រាប់មន្ត្រីរាជការ និងសិស្ស-និស្សិត សិក្សាឈ្វេងយល់អំពីបទពិសោធន៍ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់បណ្តា ប្រទេសមួយចំនួនលើសកលលោក និងបទពិសោធន៍ផ្ទាល់របស់កម្ពុជា ៕■

*រៀបចំដោយ៖ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*



# ការរៀបចំក្របខណ្ឌលទ្ធផលគន្លឹះក្នុងឆ្នាំ របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន

*ក្នុងរយៈពេលជិត ១៥ឆ្នាំ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានឆ្លងកាត់ដំណាក់កាលចំនួនបី ។*

ដំណាក់កាលទាំង ៣ នោះរួមមាន÷ ទី១) **ការបង្កើនភាពជឿទុកចិត្ត នៃថវិកា**មានរយៈពេលជាង ៤ឆ្នាំ (២០០៤-២០០៨) ដោយសម្រេចបានជោគជ័យនូវមូលដ្ឋានគ្រឹះនៃ ការពង្រឹងការគ្រប់គ្រងនិងប្រមូលចំណូល ព្រមទាំងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អយន្តការចំណាយ, ទី២) **ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** មានរយៈពេល ៦ឆ្នាំ (២០០៩-២០១៥) ដោយសម្រេចបានមូលដ្ឋានជាសារវន្ត នៃគណនេយ្យភាពហិរញ្ញវត្ថុ, ទី៣) **ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** ដែលរំពឹងថានឹងមានរយៈពេល ៥ ឆ្នាំ (២០១៦-២០២០) គឺផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្មនិងវិមជ្ឈការ និងដំណាក់កាលចុងក្រោយគឺដំណាក់កាលទី៤ “**គណនេយ្យភាពសមិទ្ធកម្ម**”, ដែលជាពេលវេលានៃការផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រង ដែលផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅជាប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើសមិទ្ធកម្ម ឬលទ្ធផល និងវិមជ្ឈការ។ នៅក្នុងន័យនេះដើម្បីសម្រេចបានតាមការរំពឹងទុករបស់រាជរដ្ឋាភិបាលក្នុងការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឆ្ពោះទៅកាន់ស្តង់ដារអន្តរជាតិ, កាលពីឆ្នាំ២០១៩ និងឆ្នាំ២០២០ **អ.គ.ហ.** បានធ្វើការសាកល្បងកំណត់និងបូកសរុបលទ្ធផលក្នុងឆ្នាំដោយផ្សារភ្ជាប់នឹងការចរចារកញ្ចប់ថវិការបស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) របស់ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន។ ជាលទ្ធផល **អ.គ.ហ.** ទទួលបាននូវលទ្ធផលគន្លឹះ ដែលជាសង្វាក់លទ្ធផលឆ្លើយតបនឹងក្របខ័ណ្ឌឡូជីខល (Logical Framework) និងក្របខណ្ឌសមិទ្ធកម្ម (Performance Framework) ក្នុងន័យវិភាជន៍ធាតុចូល (ថវិកា, និងធនធាន)ដែលមានសង្គតិភាពនិងសមានគតិភាពនឹងលទ្ធផលតាមរយៈការរៀបចំផែនការសកម្មភាពលម្អិត GDAP3 សម្រាប់អង្គភាពក្រោមឱវាទ **កសហវ** និងផែនការសកម្មភាពលម្អិត MAP3 សម្រាប់ក្រសួង-ស្ថាប័ន។ បន្ថែមពីនេះ **អ.គ.ហ.** ទទួលបាននូវកម្រងលទ្ធផលក្នុងឆ្នាំ ដែលជាឯកសារយោងមួយបង្ហាញពីសមិទ្ធផលក្នុងឆ្នាំ ដែល **ក.ហ.ស.** បានចូលរួមសហការយ៉ាងស្អិតរមួតក្នុងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដោយមានការចូលរួមផ្តល់ថវិកាពីកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមរយៈថវិកាប្រចាំឆ្នាំ, ថវិកាកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា, ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងប្រាក់ឧបត្ថម្ភការងារកែទម្រង់ហិរញ្ញវត្ថុក្រោមមូលនិធិកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈជាដើម។

*សូចនាករគន្លឹះ គឺជាកត្តាកំណត់ជោគជ័យ ឬភស្តុតាង ឬមធ្យោបាយដែលអង្គភាពសាមីដឹងថាលទ្ធផលក្នុងឆ្នាំ នឹងសម្រេចបានដោយការកំណត់តាមរយៈសូចនាករល្អ ឬ "CREAM" ដែលអាចកំណត់ចេញជាគុណភាព ឬបរិមាណបាន ។*

ក្នុងក្របខ័ណ្ឌនៃការរៀបចំលទ្ធផលគន្លឹះ




[9] Doran, G. T. (1981). "There's a S.M.A.R.T. way to write management's goals and objectives". Management Review. 70 (11): p. 35é36

ក្នុងឆ្នាំដែលមានលក្ខណៈស្តង់ដាររួមមួយ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ ដើម្បីជាទិសដៅដោះស្រាយនូវបញ្ហាធំៗ និងអាទិភាពរបស់អង្គភាពក្រោមឱវាទ **កសហវ.** និងក្រសួង- ស្ថាប័នក្នុងន័យសម្រេចបានតាមគោលដៅសូចនាករគន្លឹះ, លទ្ធផលរបស់ផែនការសកម្មភាពរួម (CAP), សូចនាករគន្លឹះរបស់ដៃគូអភិវឌ្ឍន៍ ក្នុងអភិក្រមធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ភាពសន្សំសំចៃ និងភាពប្រទាក់ក្រឡាឆ្ពោះទៅកាន់ជំហានបន្ទាប់នៃដំណាក់ កាលទី៤ ប្រកបដោយចីរភាព, **អ.គ.ហ.** បានរៀបចំជាជំហានៗ ដោយគោរពតាមគោលការណ៍ SMART[១] ដែលត្រូវបានអនុវត្ត យ៉ាងទូលំទូលាយក្នុងការកំណត់សូចនាករ និងស្របតាមខ្សែសង្វាក់លទ្ធផលដូចខាងក្រោម÷

➢ **ច្បាស់លាស់** (Specific)÷ ធានាថាលទ្ធផលចុងក្រោយសម្រាប់ដោះស្រាយបញ្ហាប្រឈមណាមួយ មានការទទួលខុសត្រូវ អ្នកទទួលផលប្រយោជន៍ និងនិរន្តរភាពបន្ទាប់ពីបញ្ចប់កម្មវិធីកែទម្រង់។

➢ **វាស់វែងបាន** (Measurable)÷ អាចរៀបចំសូចនាករដែលមានលក្ខណៈ "CREAM"[២] ។

➢ **អាចសម្រេចបាន** (Attainable)÷ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចលទ្ធផលចុងក្រោយទៅតាមធនធាន, ពេលវេលា និងគុណភាពណាមួយ ។

➢ **ប្រាកដនិយម** (Realistic)÷អាចរៀបចំផែនការប្រតិបត្តិ ផែនការថវិកា និងសកម្មភាពលម្អិត។

➢ **ពេលវេលាកំណត់** (Timeframe)÷ មានពេលវេលាចាប់ផ្តើមនិងបញ្ចប់ច្បាស់លាស់ ។

ក្នុងដ្យាក្រាមទី១, ក្នុងកិច្ចដំណើរការរៀបចំផែនការលទ្ធផលត្រូវរៀបចំពីក្របខណ្ឌលទ្ធផលពីកម្រិតលទ្ធផលចុងក្រោយដែលចេញពីគោលបំណង និងចង្កោមសកម្មភាពរបស់ផែនការសកម្មភាព (CAP) ជាមុនសិន បន្ទាប់មកអង្គភាពអនុវត្តក្រោមកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ត្រូវកំណត់ធាតុចេញ ឬលទ្ធផលក្នុងឆ្នាំយ៉ាងច្រើន ៥ របស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស**)[៣] នៅក្នុងក្រសួង- ស្ថាប័ន និងអង្គភាពរបស់ខ្លួន និងរៀបចំផែនការសកម្មភាពលម្អិត (GDAP/MAP) និងធាតុចូល (ហិរញ្ញវត្ថុលើសិក្ខាសាលា/ បណ្តុះបណ្តាល ទីប្រឹក្សាក្នុងឬក្រៅប្រទេស ទំនិញ និងប្រាក់លើកទឹកចិត្តការងារកែទម្រង់-PFM) សម្រាប់គាំទ្រផែនការអនុវត្តសកម្មភាពកែទម្រង់ជាអាទិភាព។ លើសពីនេះ ចំពោះការគ្រប់គ្រងលទ្ធផល **គ.ហ.ស.** ត្រូវជ្រើសរើសអនុវត្តទៅតាមផែនការសកម្មភាព និងថវិកាដែលបានអនុម័ត និងរៀបចំរបាយការណ៍វឌ្ឍនភាព ជាប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំមក **គ.ហ.ស.** តាមរយៈ **អ.គ.ហ.** ដែលជាសេនាធិការ ដើម្បីបូកសរុប ត្រួតពិនិត្យនិងវាយតម្លៃ។

**-ចំណុចទី១÷ លទ្ធផលក្នុងឆ្នាំ**

លទ្ធផលក្នុងឆ្នាំ គឺធាតុចេញ (Output) រយៈពេលខ្លី ឬក្នុងឆ្នាំនីមួយៗដែលអង្គភាពត្រូវសម្រេចឱ្យបានតាមគោលដៅដែលបានដាក់ចេញដើម្បីដោះស្រាយកិច្ចប្រឈម ឬធ្វើឱ្យប្រសើរឡើងអ្វីមួយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រសិទ្ធភាព សេវាសាធារណៈជាដើម ដែលអង្គភាពសាមីបានជ្រើសរើសចេញពីគោលបំណងជាអាទិភាពសម្រាប់ឆ្នាំ ឬសេចក្តីសម្រេចរបស់ **គ.ហ.ស.** ឬសូចនាករគន្លឹះរបស់ដៃគូអភិវឌ្ឍន៍ ឬសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលណាមួយ។




*ដ្យាក្រាម ១÷ ខ្សែសង្វាក់លទ្ធផល (Results Chain)*

[២] *CREAM : ច្បាស់លាស់ (Clear), ពាក់ព័ន្ធ (Relevant) , សន្សំសំចៃ (Economic) , គ្រប់គ្រាន់ (Adequate) , ត្រួតពិនិត្យបាន (Monitorable), Schiavo-Campo (1999). "The CREAM principles are used to select good performance indicators" p. 85*

[៣] *សារាចរលេខ ០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី វិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសធារណៈ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥, ទំព័រទី ៣*

| លទ្ធផលក្នុងឆ្នាំ 1 | សូចនាករគន្លឹះ 2 | ខ្នាត 3 | គោលដៅ 4 | សន្ទស្សន៍អទិភាព 5 | គោលដៅ/លក្ខខណ្ឌកំណត់លទ្ធផល 6 | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | ល្អប្រសើរ | ល្អណាស់ | ល្អ | មធ្យម | ខ្សោយ |
| | | | | | ១០០% | ៩០% | ៨០% | ៧០% | ៦០% |
| | | | | | | | | | |

**-ចំណុចទី២÷ សូចនាករគន្លឹះ**

សូចនាករគន្លឹះ គឺជាកត្តាកំណត់ជោគជ័យ ឬភស្តុតាង ឬមធ្យោបាយដែលអង្គភាពសាមីដឹងថាលទ្ធផលក្នុងឆ្នាំនឹងសម្រេចបានដោយការកំណត់តាមរយៈសូចនាករសមិទ្ធិកម្មល្អ ឬ “CREAM” ដែលអាចកំណត់ចេញជាគុណភាព ឬបរិមាណបាន។

**-ចំណុចទី៣÷ គោលដៅ**

រូបមន្តនៃការវាយតម្លៃគឺ÷ **គោលដៅសមិទ្ធកម្ម** (កម្រិតនៃប្រាថ្នានៃសមិទ្ធកម្មដែលយើងកំណត់) = **កម្រិតសូចនាកររបស់បន្ទាត់គោល ឬទិន្នន័យមូលដ្ឋាន+កម្រិតនៃប្រាថ្នាចង់កែលម្អ** (សន្មតលើភាពច្បាស់លាស់ ដោយកម្រិតរំពឹងទុកធាតុចូល, សកម្មភាព/កិច្ចដំណើរការ, និងធាតុចេញ)

**-ចំណុចទី៤÷ ខ្នាត**

ខ្នាត គឺការកំណត់នូវវិធីសាស្រ្តដើម្បីវាស់វែង និងជាក្របខ័ណ្ឌសមិទ្ធកម្ម ដូចជា÷ ១. **ពេលវេលា** (កាលបរិច្ឆេទ, សប្តាហ៍, ខែ, ត្រីមាស, ឆមាស និងឆ្នាំ), ២. **ចំនួន/លេខ** (រូបិយវត្ថុ, %, សន្ទស្សន៍,...) និង ៣. **សមិទ្ធកម្ម/ បាទ-ទេ** (លទ្ធផលដែលតម្រូវផលិត ឬបង្កើតក្នុងឆ្នាំ)។

**-ចំណុចទី៥÷ សន្ទស្សន៍អាទិភាព**

កម្រិតអាទិភាពខ្ពស់បំផុត ១០០%, អាទិភាពបង្គួរ ៧៥%, អាទិភាពមធ្យម ៥០% និងអាទិភាពទាប ២៥% និងតាមការគណនាសន្ទស្សន៍និទ្ទេសធៀបនឹងអង្គភាពដែលកំពុងអនុវត្តគម្រោង PFM។

**-ចំណុចទី៦÷ គោលដៅ/ លក្ខខណ្ឌកំណត់លទ្ធផល**

រូបមន្តនៃការវាយតម្លៃគឺ÷ **សមិទ្ធកម្មធៀបនឹងគោលដៅក្នុងលក្ខខណ្ឌ X គុណភាពឬទម្ងន់ នៃ RFD = សមិទ្ធកម្មជាក់ស្តែង**

**ឧទាហរណ៍÷** ១០០% (ពិន្ទុក្នុង RFD នៃលក្ខខណ្ឌ) X ៦០% (ទម្ងន់នៃ RFD) = ៦០%

ផ្អែកតាមបទពិសោធន៍ នៃការរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផ្សារភ្ជាប់នឹងផែនការថវិកា រយៈពេល ២ឆ្នាំកន្លង, **អ.គ.ហ.** បានមើលឃើញពីប្រសិទ្ធភាពនៃចំណាយថវិកា ចំគោលដៅ និងតម្លាភាព ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គុណភាព និងគោលដៅ នៃការអនុវត្តជាយុទ្ធសាស្រ្ត នៅតែជួបបញ្ហាចម្បងៗ ដែលតម្រូវឱ្យមានការដោះស្រាយជាស្ថាពរមួយ។ ដូច្នេះ ក្នុងឆ្នាំ២០២០នេះផងដែរ ពោលគឺជាឆ្នាំចុងក្រោយ នៃដំណាក់កាលទី៣ និងជាពេលវេលា នៃការបោះជំហានទៅកាន់ដំណាក់កាលទី៤“**គណនេយ្យភាពសមិទ្ធកម្ម**” នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, **អ.គ.ហ.** បាននិងកំពុងរៀបចំផែនការសកម្មភាពជាអាទិភាពមួយចំនួន រួមមាន÷

ទី១. ជម្រុញការរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ២០២០ ផ្សារភ្ជាប់នឹងផែនការសកម្មភាពរួម MAP3/GDAP3 និងផែនការថវិកា របស់អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័នឱ្យមានសង្គតិភាព និងសមានគតិ-ភាព និងគ្រោងដាក់ឱ្យអនុវត្តលទ្ធផលគន្លឹះនេះ នៅត្រីមាសទី១ នៃឆ្នាំ២០២០, ទី២. រៀបចំសេចក្តីព្រាងក្របខ័ណ្ឌសម្រាប់ត្រួត-ពិនិត្យ និងវាយតម្លៃលើលទ្ធផលរបស់ **គ.ហ.ស.** ដែលទទួលជំនួយបច្ចេកទេសពីសហភាពអ៊ឺរ៉ុប និងទី៣. គ្រោងដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធ Online Web-based Application សម្រាប់ផ្ទៃក្នុង **អ.គ.ហ.** ដើម្បីធានាលទ្ធផលចុងក្រោយ ក៏ដូចជាត្រួតពិនិត្យលើការអនុវត្តផែនការសកម្មភាពរួមរបស់អង្គភាព ដូចដែលមានចែងនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ **អ.គ.ហ.** ៕■

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*

# យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥

*កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩, រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត «យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥» និងបានប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនេះនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ កន្លងទៅ។*

ឯកសារយុទ្ធសាស្ត្រនេះបានបង្ហាញពីទិដ្ឋភាពរួមនៃការគ្រប់គ្រងការវិនិយោគសាធារណៈ និងត្រូវបានចាត់ទុកជាសមាសភាគដ៏សំខាន់មួយនៃ « **យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥**» ក្រោមក្របខ័ណ្ឌ « **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ។

ជានិយមន័យទូទៅ, ការវិនិយោគ-សាធារណៈ សំដៅដល់ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលមាន ២ ប្រភេទគឺ÷ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធសង្គម។

ការវិនិយោគសាធារណៈអាចត្រូវបានហិរញ្ញប្បទានដោយ (១)-ថវិការបស់រដ្ឋាភិបាល ដែលបានមកពីថវិការដ្ឋ និងការខ្ចីពីក្នុងនិងក្រៅប្រទេស, និង (២)-ទុនវិនិយោគពីវិស័យឯកជន។ ការវិនិយោគសាធារណៈ ត្រូវបានហិរញ្ញប្បទានដោយថវិកាមូលធន ក្នុងដំណាក់កាលសាងសង់ និងហិរញ្ញប្បទានដោយថវិកាចរន្ត ក្នុងដំណាក់កាលប្រតិបត្តិការ និងថែទាំ។

ជាការពិត, ការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គឺជាគ្រឹះនៃការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ទន្ទឹមនេះ, ការវិនិយោគសាធារណៈចំទិសដៅអាទិភាព ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក៏កាន់តែមានសារៈសំខាន់ និងចាំបាច់សម្រាប់ដំណាក់កាលអភិវឌ្ឍន៍



*កិច្ចប្រជុំពិនិត្យ និងសម្រេចលើសេចក្តីព្រាង "ឯកសារក្របខ័ណ្ឌទស្សនាទានស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២០" ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩*

របស់កម្ពុជាផងដែរ។ ក្នុងន័យនេះ, រាជរដ្ឋា-ភិបាល ចាំបាច់ត្រូវតែរៀបចំ និងដាក់ចេញនូវយុទ្ធសាស្ត្រមុតស្រួច និងម៉ឺងម៉ាត់ ក្នុងការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការ វិនិយោគសាធារណៈ ជាពិសេស សម្រាប់បរិការណ៍បច្ចុប្បន្នរបស់កម្ពុជា ដែលម្យ៉ាង (១) កំពុងមានតម្រូវការទុនវិនិយោគកាន់តែធំសម្រាប់ឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍កម្ពុជានៅដំណាក់កាលថ្មី, ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការពង្រឹងសមត្ថភាពប្រកួតប្រជែង ប៉ុន្តែ (២) កម្ពុជាក៏កំពុងប្រឈមនឹងភាពកម្រ និងភាពរឹងស្ងួតនៃធនធានវិនិយោគសាធារណៈ ទាំងពីប្រភពខាងក្រៅ និងផ្ទៃក្នុងផងដែរ។ ភាពកម្រ និងភាពរឹងស្ងួតពីប្រភពខាងក្រៅ គឺបណ្តាលមកពីការធ្លាក់ចុះ នៃប្រភពហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ ពីដៃគូ-អភិវឌ្ឍន៍ដោយសារកម្ពុជាបានចាកផុតពីឋានៈជាប្រទេសដែលមានចំណូលទាបមកជាប្រទេស ដែលមានចំណូលមធ្យមកម្រិតទាប។ ភាពកម្រពីប្រភពផ្ទៃក្នុង គឺបណ្តាលមកពីកំណើន នៃបន្ទុកចំណាយ-ចរន្ត ជាពិសេសការកើនឡើង នៃបន្ទុកបៀវត្ស, ការអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ, ការអនុវត្តកម្មវិធីគាំពារសង្គម, និងការអនុវត្តវិធានការជាកញ្ចប់ត្រៀមទប់ទល់នឹងការគំរាមកំហែងពីខាងក្រៅដែលធ្វើឱ្យអតិរេកថវិកាសម្រាប់ទ្រទ្រង់ការវិនិយោគសាធារណៈ អាចនឹងថមថយជាយថាហេតុ។ លើសពីនេះ,(៣) ការវិនិយោគសាធារណៈ

*ការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គឺជាគ្រឹះនៃការជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ។*

កាន់តែមានចរិតស្មុគស្មាញ, តម្លៃកាន់តែថ្លៃ និងទំហំវិនិយោគកាន់តែធំ ដែលតម្រូវឱ្យមានប្រព័ន្ធគ្រប់គ្រងរួមមួយកាន់តែរឹងមាំ, ច្បាស់លាស់ និងហ្មត់ចត់ជាងមុន ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពសេដ្ឋកិច្ច, សមធម៌សង្គម និងឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព។


រូបភាពក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៩

យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ បានដាក់ចេញនូវចក្ខុវិស័យចម្បងពោលគឺនៅមុនដំណាច់ឆ្នាំ២០២៥ រាជរដ្ឋាភិបាលត្រូវបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ រួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព នៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន ឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។ យុទ្ធសាស្ត្រនេះមានគោលបំណងកំណត់ក្របខ័ណ្ឌរួមមួយ សម្រាប់បង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ, ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន), និងនៅគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ។


រូបភាពក្នុងកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាង "យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធ គ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥"

ដើម្បីសម្រេចនូវចក្ខុវិស័យ និងគោលបំណងខាងលើ, យុទ្ធសាស្ត្រនេះ មានគោលដៅសំខាន់ៗដូចខាងក្រោម÷

**(១).** ពិនិត្យមើលឡើងវិញ និងរៀបចំក្របខ័ណ្ឌគតិយុត្ត សម្រាប់ធ្វើឱ្យមានសង្គតិភាពកម្រិតគោលការណ៍ និងអភិក្រមនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង, ពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងថវិការដ្ឋ ថវិកាដៃគូ និងទុនវិនិយោគឯកជន) និងក្នុងគ្រប់កម្រិតរដ្ឋបាល (ទាំងថ្នាក់ជាតិទាំងរដ្ឋបាលថ្នាក់ក្រោមជាតិសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពសាធារណៈប្រហាក់ប្រហែល) ។

**(២).** ពង្រឹងការធ្វើអាទិភាវូបនីយកម្មការវិនិយោគសាធារណៈបីឆ្នាំរំកិល, ការធ្វើផែនការនីយកម្ម នៃការវិនិយោគសាធារណៈ និងការធ្វើសមាហរណកម្មថវិកាវិនិយោគសាធារណៈពីប្រភពថវិកា




ជាតិ និងថវិកាដៃគូអភិវឌ្ឍន៍តាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ។

**(៣).** ពង្រឹងការធ្វើសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី-ខេត្តដែលមានលក្ខណៈសមាហរណកម្មស្របតាមទិសដៅ នៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, និងលើកកម្ពស់ប្រសិទ្ធភាព នៃទំនាក់ទំនងប្រទាក់ក្រឡា និងបំពេញឱ្យគ្នា ដោយការតម្រឹមកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅនឹងកម្មវិធីរបស់រដ្ឋបាលថ្នាក់ជាតិ (មន្ទីរជំនាញរាជ-ធានី-ខេត្ត)។

**(៤).** ពង្រឹងគុណភាព ប្រសិទ្ធភាពអនុវត្ត និងភាពផ្សារភ្ជាប់រវាងកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ,

**(៥).** បង្កើត និង/ ឬ ពង្រឹងយន្តការស្ថាប័នសម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈជាពិសេស ដំណាក់កាលអាទិភាវូបនីយកម្ម និងផែនការនីយកម្ម, សិក្សាវាយតម្លៃ និងរៀបចំសំណើគម្រោង, ពិនិត្យវាយ តម្លៃលើសំណើគម្រោង, ជ្រើសរើសគម្រោង និងថវិកានីយកម្មគម្រោងវិនិយោគសាធារណៈ, និងការវាយតម្លៃក្រោយបញ្ចប់ការអនុវត្តគម្រោង, និង

**(៦).** រៀបចំ និងបង្កើតឯកសារណែនាំស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ។

ការឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ នឹងធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមួយចំនួន, ផ្លាស់ប្តូររបៀបរបបបំពេញការងារ, ព្រមទាំងត្រូវការបំពេញលក្ខខណ្ឌជាច្រើនថែមទៀត ដើម្បីឱ្យសំណើគម្រោងវិនិយោគសាធារណៈមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលចាំបាច់

*នៅមុនដំណាច់ឆ្នាំ២០២៥ រាជរដ្ឋាភិបាលត្រូវបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ រួមមួយរបស់ជាតិដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, ចីរភាព នៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ។*

តម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធជាពិសេស ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវតែបុរេសកម្ម, សកម្ម, អន្តរសកម្ម និងម៉ឺងម៉ាត់ជាងមុន ដើម្បីមិនត្រឹមតែធានាថា គ្មានការរាំងស្ទះដល់ចលនាការអភិវឌ្ឍប្រទេស ដោយសារការជាប់គាំងនៃគម្រោងវិនិយោគសាធារណៈនៅដំណាក់កាលណាមួយនោះទេ, តែថែមទាំងជួយលើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព នៃការវិនិយោគសាធារណៈឱ្យកាន់តែប្រសើរជាងមុនទៀតផង។ ក្នុងស្មារតីនេះ, ការអនុវត្តយុទ្ធសាស្ត្រនេះត្រូវប្រកាន់យកនូវអភិក្រម «**ប្រយ័ត្នប្រយែង, សន្សឹមៗ, ឈរលើគោលការណ៍ប្រាកដនិយម, ទន់ភ្លន់, និង រៀនផង-ធ្វើផង**» តែម៉ឺងម៉ាត់ និងម៉ត់ចត់ជាងមុន ដើម្បីប្រសិទ្ធភាពខ្ពស់នៃការវិនិយោគសាធារណៈ។

ដើម្បីគាំទ្រការអនុវត្តវិធានការជាយុទ្ធសាស្ត្រខាងលើប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និងគណនេយ្យភាព, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាលត្រូវទទួលបន្ទុកជាស្ថាប័ននាំមុខ ក្នុងការសម្របសម្រួលលើការអនុវត្តផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ នៃឯកសារយុទ្ធសាស្ត្រនេះ៕■

*រៀបចំដោយ÷ ផ្នែកអនុវត្តថវិកា នៃ អ.គ.ហ.*

# ស្វែងយល់អំពីក្របខណ្ឌនៃប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ÷ សវនកម្ម និង អធិការកិច្ច

*ជាទូទៅ ការគ្រប់គ្រងនៅក្នុងវិស័យសាធារណៈ តែងតែប្រព្រឹត្តទៅនៅក្នុងវដ្តដែលមាន ៣ ដំណាក់កាល គឺ ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យតាមដាន ជាក់ស្តែង នៅក្នុងការគ្រប់គ្រងថវិកាជាតិជាដើម។*

ការត្រួតពិនិត្យតាមដាន គឺជាដំណាក់កាល ដ៏សំខាន់ និងមិនអាចខ្វះបានព្រោះវាជាយន្តការដើម្បីត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អអំពីសុខភាព នៃការគ្រប់គ្រង អំពីចំណុចខ្លាំង និងចំណុចខ្សោយ។ នៅកម្ពុជា ប្រព័ន្ធត្រួតពិនិត្យលើការគ្រប់គ្រងវិស័យសាធារណៈនិយាយជារួម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិយាយដោយឡែក ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ នៃមុខងារចំនួន ២ គឺមុខងារអធិការកិច្ច និងមុខងារសវនកម្ម។ មុខងារទាំង ២នេះមានសារៈសំខាន់ណាស់ ព្រោះវាជាឧបករណ៍ដ៏ចាំបាច់ដែលត្រូវបានប្រើប្រាស់សម្រាប់កែលម្អនូវចំណុចខ្វះខាត និងស្វែងរកនូវចំណុចគន្លឹះ សំដៅបង្កើនសមិទ្ធកម្មរបស់ក្រសួង- ស្ថាប័ននីមួយៗ ឱ្យកាន់តែប្រសើរឡើង ជាពិសេសនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតែម្តង។

## ក. ឧត្តមានុវត្តន៍អន្តរជាតិ

### ក.១. ករណីចក្រភពអង់គ្លេស ÷ ប្រព័ន្ធនៃបណ្តាប្រទេសអង់គ្លូសាកសុង (Anglo saxon)

ជាទូទៅ ប្រព័ន្ធត្រួតពិនិត្យ នៃបណ្តាប្រទេសអង់គ្លូសាកសុង យកលំនាំតាមប្រព័ន្ធដើមដែលមានកំណើតនៅចក្រភពអង់គ្លេស។ ក្នុងរដ្ឋបាលសាធារណៈអង់គ្លេស អង្គភាពសវនកម្មផ្ទៃក្នុង មាននៅតាមគ្រប់

> *ភាពចម្រុះនៃស្ថាប័នពាក់ព័ន្ធសវនកម្ម និងអធិការកិច្ចនៅកម្ពុជា ទាំងក្នុងក្របខណ្ឌក្រសួង- ស្ថាប័ននីមួយៗ និងក្នុងក្របខណ្ឌនៃរាជរដ្ឋាភិបាលទាំងមូល ជាចំណុចដ៏មានសារៈសំខាន់មួយដែលបង្ហាញអំពីភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យនៅកម្ពុជា ។*

ក្រសួង- ស្ថាប័នរបស់រដ្ឋាភិបាល ដែលត្រូវត្រួតពិនិត្យទៅលើប្រព័ន្ធនិងបញ្ហាពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃបណ្តាស្ថាប័ននីមួយៗ។ ស្តង់ដាររួមនិងសេចក្តីណែនាំផ្សេងៗពាក់ព័ន្ធវិធាន នីតិវិធី និងបែបបទ នៃការធ្វើសវនកម្មផ្ទៃក្នុងត្រូវរៀបចំឡើងដោយក្រសួងរតនាគារ (Treasury) ដែលមានអង្គភាពសវនកម្មផ្ទៃក្នុង របស់រដ្ឋាភិបាល ( the government internal audit agency -GIAA) ជាសេនាធិការ។

ដោយឡែក សវនកម្មផ្ទៃក្រៅទៅលើក្រសួង- ស្ថាប័នរដ្ឋាភិបាល គឺជាសមត្ថកិច្ចរបស់ស្ថាប័នសវនកម្មជាតិ (The National Audit Office -NAO)។ ទន្ទឹមនេះ ការធ្វើសវនកម្មទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពនគបាល និងអង្គភាពជាតិផ្តល់សេវាសុខាភិបាល គឺជាសមត្ថកិច្ចរបស់គណៈកម្មការសវនកម្ម (Audit Commission) ដែលត្រូវបានបង្កើតក្នុងពេលទន្ទឹមនឹងការបង្កើតស្ថាប័នសវនកម្មជាតិខាងលើដែរ។

ដោយសារតែលក្ខណៈវិមជ្ឍការ នៃប្រព័ន្ធសវនកម្មផ្ទៃក្នុងរបស់រដ្ឋាភិបាលអង់គ្លេសនេះហើយទើបប្រព័ន្ធសវនកម្មនេះត្រូវបានចាត់ទុកជាប្រព័ន្ធគំរូមួយដែលបណ្តាប្រទេសជាច្រើន ជាពិសេសបណ្តាប្រទេសអង់គ្លូសាកសុងភាគច្រើន បានយកលំនាំតាម។

### ក.២. ករណីប្រទេសបារាំង ÷ ម៉ូដែលនៃបណ្តាប្រទេសហ្វ្រង់កូហ្វូនី (Francophony)

នៅក្នុង រដ្ឋបាលសាធារណៈបារាំង ប្រព័ន្ធសវនកម្ម ជ្រកនៅក្រោមឈ្មោះ “**អធិការកិច្ច**” ព្រោះសវនកម្ម គឺជាសញ្ញាណនៃបណ្តាប្រទេសអង់គ្លូសាកសុង។ ក្នុងន័យនេះ អគ្គាធិការដ្ឋានហិរញ្ញវត្ថុ (Inspection Général des Finances) ដែល ជាអង្គភាពមួយស្ថិតក្រោមក្រសួងហិរញ្ញវត្ថុ មានបេសកម្មដ៏ចម្បងមួយ គឺធ្វើសវនកម្មលើគ្រប់ក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល និងកិច្ចប្រតិបត្តិការ របស់ស្ថាប័នទាំងឡាយណាដែលទទួលបានហិរញ្ញវត្ថុសាធារណៈយកទៅចាត់ចែង។ ក្រៅពីធ្វើសវនកម្ម អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ក៏មានមុខងារត្រួតពិនិត្យ, សិក្សា, ផ្តល់យោបល់ និងធ្វើការវាយតម្លៃផងដែរនៅលើវិស័យពាក់ព័ន្ធនឹងការងាររដ្ឋបាល ការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។ ក្រៅពីអគ្គាធិការដ្ឋានហិរញ្ញវត្ថុ របស់ក្រសួងហិរញ្ញវត្ថុ, ក្រសួង- ស្ថាប័ននីមួយៗក៏មាននូវអង្គភាព




សវនកម្មផ្ទៃក្នុងរបស់ខ្លួនផងដែរ ដើម្បីត្រួតពិនិត្យទៅលើកិច្ចប្រតិបត្តិការ និងការអនុវត្តហិរញ្ញវត្ថុរបស់គ្រប់អង្គភាព ចំណុះឱ្យក្រសួង ស្ថាប័ននីមួយៗ។

ដោយឡែកនៅក្នុងក្របខ័ណ្ឌនៃសវនកម្មកំពូលបារាំងមានស្ថាប័នសវនកម្មកំពូលមួយទៀត ដែលហៅថា "តុលាការគណនី" (Cour des Comptes) ដែលមានបេសកកម្មជាស្ថាប័នធ្វើសវនកម្មកំពូល និងឯករាជ្យដូចក្នុងករណីនៃអាជ្ញាធរសវនកម្មជាតិនៅប្រទេសកម្ពុជាដែរ។

## ២. ក្របខ័ណ្ឌស្ថាប័ននៅកម្ពុជា

### ២.១. ក្របខ័ណ្ឌស្ថាប័នសវនកម្ម

#### ២.១.១. សវនកម្មផ្ទៃក្នុងតាមក្រសួង-ស្ថាប័ន

សវនកម្មផ្ទៃក្នុង (Internal Audit) ជាអង្គភាពមួយស្ថិតនៅក្រោមរចនាសម្ព័ន្ធរបស់ក្រសួង- ស្ថាប័ន និងសហគ្រាសសាធារណៈនីមួយៗដែលអាចមានកម្រិតជាអង្គភាពជានាយកដ្ឋាន ឬជាអគ្គនាយកដ្ឋាន។ អង្គភាពនេះត្រូវបានតម្រូវឱ្យបង្កើតឡើងដោយអនុក្រឹត្យលេខ ៤០ អនក្រ. បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ដើម្បីបំពេញមុខងារ និងភារកិច្ចវាយតម្លៃដោយឯករាជ្យនូវអនុលោមភាព និងភាពសមស្របនៃកិច្ចប្រតិបត្តិការផ្ទៃក្នុងស្ថាប័ន។ អង្គភាពសវនកម្មផ្ទៃក្នុង ធ្វើរបាយការណ៍ផ្ទាល់ និងត្រង់ទៅរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីតែម្តង។

#### ២.១.២. អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ស្ថាប័ន ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ និងកំណត់គោលនយោបាយ ស្តង់ដារ បែបបទ និងនីតិវិធី នៃការធ្វើសវនកម្មផ្ទៃក្នុងនៅក្នុងវិស័យសាធារណៈ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ខ្លួន ជាសេនាធិការ។

#### ២.១.៣. អាជ្ញាធរសវនកម្មជាតិ

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នឯករាជ្យដែលមិនស្ថិតក្រោមចំណុះរាជរដ្ឋាភិបាលឡើយ។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ២០០០។ អាជ្ញាធរសវនកម្មជាតិ ទទួលខុសត្រូវក្នុងការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅ (External Audit) រួមមានសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សវនកម្មលើកិច្ចប្រតិបត្តិការ និងសវនកម្មលើការអនុលោមតាមច្បាប់។ លទ្ធផលនៃរបាយការណ៍សវនកម្មនេះ ត្រូវផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងចម្លងជូនទៅរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដើម្បីជ្រាប ក្នុងគោលដៅជំរុញនិងកែលម្អប្រព័ន្ធគ្រប់គ្រងទាំងឡាយ ដែលនៅមានចំណុចខ្វះខាត ឬមានភាពមិនប្រក្រតីក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

### ២.២. ក្របខ័ណ្ឌស្ថាប័នអធិការកិច្ច

#### ២.២.១. អធិការកិច្ចតាមក្រសួង-ស្ថាប័ន

អធិការកិច្ចនៅតាមក្រសួង- ស្ថាប័នត្រូវបានបង្កើតឡើង ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួង-ស្ថាប័ននីមួយៗ ទៅតាមវិសេសភាពរបស់ស្ថាប័នរៀងៗខ្លួន ដោយមិនទាន់មានលិខិតបទដ្ឋានគតិយុត្តតម្រូវឱ្យបង្កើតជាកាតព្វកិច្ចនោះឡើយ។

ជាទូទៅនិងតាមឧត្តមានុវត្តន៍អន្តរជាតិ អធិការកិច្ចនៅតាមក្រសួង- ស្ថាប័នបំពេញមុខងារត្រួតពិនិត្យទៅលើវិស័យជំនាញនីមួយៗ ដូចជាវិស័យអប់រំវិស័យសុខាភិបាល និងវិស័យការងារជាដើម (លើកលែងតែអធិការកិច្ចហិរញ្ញវត្ថុ ដែលជាសមត្ថកិច្ចរបស់ក្រសួងហិរញ្ញវត្ថុ) ដោយប្រើប្រាស់អភិក្រមផ្អែកលើហានិភ័យ ឬផ្អែកលើករណីសង្ស័យ ឬផ្អែកលើបណ្តឹងតវ៉ា ឬមានបទបញ្ជាពីរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន។

### ខ.២.២. អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អង្គភាពអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានឈ្មោះថា "**អគ្គាធិការដ្ឋាន**" ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ និងក្រោយមកទៀតត្រូវបានបញ្ជាក់នៅក្នុងក្របខ័ណ្ឌច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុថា អធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានបេសកកម្មធ្វើអធិការកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើអភិក្រមអធិការកិច្ចផ្អែកលើហានិភ័យនិងអធិការកិច្ចផ្អែកលើករណីសង្ស័យ ឬបណ្តឹងតវ៉ាជាក់ស្តែង ក្នុងគោលដៅធានាការប្រមូលព័ត៌មាន និងទិន្នន័យច្បាស់លាស់ក្នុងការរៀបចំការទូទាត់ថវិកា និងកំណត់អំពើបំពានហិរញ្ញវត្ថុសាធារណៈ តាមរយៈការចាត់វិធានការឱ្យទទួលខុសត្រូវផ្សេងៗ។

### ខ.២.៣. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវបានបង្កើតឡើងនៅឆ្នាំនៅឆ្នាំ១៩៩៩។ ក្រសួងអធិការកិច្ចជាស្ថាប័នមានសមត្ថកិច្ចធ្វើអធិការកិច្ចទូទៅ លើគ្រប់វិស័យរបស់រដ្ឋាភិបាល សំដៅបង្ការទប់ស្កាត់ កែលម្អ និងមានវិធានការដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភអំណាច និងបាតុភាពអសកម្មផ្សេងៗ។

## គ. ការអនុវត្តជាធរមាននៅកម្ពុជា

ភាពចម្រុះនៃស្ថាប័នពាក់ព័ន្ធសវនកម្ម និងអធិការកិច្ចនៅកម្ពុជា ទាំងនៅក្នុងក្របខ័ណ្ឌក្រសួង- ស្ថាប័ននីមួយៗ និងក្នុងក្របខ័ណ្ឌនៃរាជរដ្ឋាភិបាលទាំងមូល ជាចំណុចដ៏មានសារៈសំខាន់មួយដែលបង្ហាញអំពីភាពរឹងមាំនៃប្រព័ន្ធត្រួតពិនិត្យនៅកម្ពុជា។

ក៏ប៉ុន្តែ ទន្ទឹមនេះ ប្រការនេះក៏បានបង្កើតនូវបញ្ហាប្រឈមមួយចំនួន លើការជាន់សមត្ថកិច្ចគ្នាផងដែរ។ ក្នុងករណីខ្លះអង្គភាពសវនកម្មផ្ទៃក្នុង និងអង្គភាពអធិការកិច្ចនៅតាមក្រសួង- ស្ថាប័ន បានបំពេញមុខងារត្រួតពិនិត្យស្ទួនគ្នា ដោយត្រួតពិនិត្យលើកិច្ចប្រតិបត្តិការរបស់ក្រសួង, ការអនុវត្តថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងបុគ្គលិក ជាដើម។ ក្រសួង- ស្ថាប័នមួយចំនួនធំនៅពុំទាន់បានបែងចែកភារកិច្ចរវាងសវនកម្មផ្ទៃក្នុង និងអគ្គាធិការ- ដ្ឋាន/ អធិការដ្ឋានរបស់ខ្លួនឱ្យបានត្រឹមត្រូវឱ្យស្របតាមការកំណត់នៅក្នុងអនុក្រឹត្យលេខ ៤០ អនក្រ. បក[9] នៅឡើយ។ ដោយឡែក ក៏មានការស្ទួនគ្នាផងដែរ រវាងការអនុវត្តមុខងារ នៃអគ្គាធិការដ្ឋាន នៃ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង
នៅតាមបណ្តា ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃ ទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ។

[9] http://gdia.mef.gov.kh/wp-content/uploads/2012/04/៤០-១៥កុម្ភៈ២០០៥.pdf

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសវនកម្មផ្ទៃក្នុង/អគ្គាធិការដ្ឋាន នៅតាមបណ្ដាក្រសួង-ស្ថាប័ន ខណៈដែលជាទូទៅស្ថាប័នទាំង២នេះ មានគោលដៅ ផ្សេងពីគ្នាព្រោះសវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតឡើងសម្រាប់ជំរុញប្រសិទ្ធភាព នៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន រីឯអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានគោលដៅកំណត់អំពើ ដែលបំពានលើបទប្បញ្ញត្តិ នៃការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និងការចាត់វិធានការឱ្យទទួលខុសត្រូវ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល។

ក្រៅពីនេះ ក្នុងក្របខ័ណ្ឌអន្តរក្រសួង អធិការកិច្ចហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអធិការកិច្ចទូទៅ របស់ក្រសួង អធិការកិច្ច សុទ្ធសឹងជាស្ថាប័នធ្វើការត្រួតពិនិត្យលើហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលដូចគ្នាខណៈដែលច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងហិរញ្ញវត្ថុ-សាធារណៈ បានកំណត់យ៉ាងច្បាស់លាស់អំពីមុខងារ នៃអធិការកិច្ចហិរញ្ញវត្ថុ៕■

*រៀបចំដោយ៖ ផ្នែកកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ អ.គ.ហ.*



ជំពូក ទី៥

អវសានប្បញ្ញត្តិ

មាត្រា ៩.-

ប្រធានស្ថាប័ន ក្រសួងនីមួយៗ ត្រូវសម្របសម្រួលបែងចែកភារកិច្ច រវាងអគ្គាធិការដ្ឋាន ឬអធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងនេះ ឱ្យបានសមស្រប ។

81

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងប្រធានអគ្គនាយក ឬអគ្គនាយកនៃសហគ្រាសសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ[illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត- ក្រុង និងរាជធានីភ្នំពេញ
- ដូចមាត្រា ១០
- ឯកសារ- កាលប្បវត្តិ

## ផ្នែកទី៣

# សុន្ទរកថា




រាជរដ្ឋាភិបាលកម្ពុជា
ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
រាជរដ្ឋាភិបាលកម្ពុជា
យុទ្ធសាស្ត្រ
ស្តីពី
ទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ
២០១៩ - ២០២៥

# សុន្ទរកថាបើករបស់ ឯកឧត្តម រស់ សីលវ៉ា អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈ-កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ថ្លែងនៅក្នុងពិធីបើក វគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ នៅថ្ងៃចន្ទ ៥រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។*

*-ឯកឧត្តម លោកជំទាវ និង លោក លោកស្រី ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការជាន់ខ្ពស់ មកពីគ្រប់ក្រសួង-ស្ថាប័ន, រដ្ឋបាលរាជ-ធានី-ខេត្ត និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*

*-លោក Phil Sinnett ទីប្រឹក្សាបច្ចេកទេស និងតំណាងប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា*

*-លោក លោកស្រី សមាជិក អង្គពិធីជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានមកចូលរួមជាមួយនឹងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី «ក្របខណ្ឌចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ» ដ៏មានសារៈ-សំខាន់សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃរាជរដ្ឋាភិបាលកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ ចាប់ពីថ្ងៃទី ១៦ ដល់ ១៧ ខែធ្នូ ឆ្នាំ២០១៩ ដែលទទួលបានការគាំទ្រ និងកិច្ចសហប្រតិបត្តិការរវាង គណៈ-កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ និងសហភាពអឺរ៉ុបក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងអំពីឧត្តមានុវត្តន៍អន្តរជាតិលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាពង្រឹងសមត្ថភាពដើម្បីត្រៀមលក្ខណៈវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិឆ្នាំ២០២០ ដែលគ្រោងនឹងបញ្ចប់ក្នុងមិថុនា ឆ្នាំ២០២០។ ខ្ញុំសូមគូសបញ្ជាក់ថាការវាយតម្លៃ PEFA ថ្នាក់ជាតិឆ្នាំ ២០២០ គឺទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**



*រូបភាពក្នុងកម្មវិធី បើកវគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩*

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ក្របខណ្ឌ PEFA គឺជាឧបករណ៍វាស់ស្ទង់លើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយប្រមាណជា ១៥០ ប្រទេស ។ ឧបករណ៍ PEFA នេះ ចង្អុលបង្ហាញប្រាប់យើង អំពីចំណុចខ្លាំង និងចំណុចខ្សោយ នៃប្រព័ន្ធថវិការបស់យើង ក្នុងវដ្តថវិកាទាំងមូល គឺ


ឯកឧត្តម **រស់ សីលា** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.)

តាំងពីដំណាក់កាល នៃការរៀបចំថវិកា, ការអនុវត្តថវិកា និងការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តថវិកានិងសមិទ្ធកម្ម។ ការវាយតម្លៃ PEFA នេះ គឺជាមូលដ្ឋានដ៏សំខាន់ សម្រាប់រៀបចំផែនការសកម្មភាពរួម និងការកំណត់អាទិភាពរូបនីយកម្ម នៃគោលដៅកែទម្រង់ជាជំហានៗ ឱ្យបានត្រឹមត្រូវ និងប្រាកដនិយមផ្សារភ្ជាប់នឹងស្ថានការណ៍ជាក់ស្តែង ។ មិនតែប៉ុណ្ណោះ, ការវាយតម្លៃ PEFA នឹងអនុញ្ញាតឱ្យយើងអាចធ្វើការប្រៀបធៀបប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាយើង ទៅនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃបណ្តាប្រទេសផ្សេងទៀត លើពិភពលោក នៅលើមូលដ្ឋានគ្រឹះបីយ៉ាងគឺ **បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាព នៃការវិភាជន៍ថវិកា និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ** តាមរយៈ ការវាយ-តម្លៃនិងវិភាគលទ្ធផលសសរស្តម្ភទាំង ៧ រួមមាន សសរស្តម្ភទី១÷ ភាពជឿទុកចិត្តនៃថវិកា, សសរស្តម្ភទី២ ÷ តម្លាភាពហិរញ្ញវត្ថុ, សសរស្តម្ភទី៣÷ ការគ្រប់គ្រងទ្រព្យសកម្មនិងបំណុល, សសរស្តម្ភទី៤÷ យុទ្ធសាស្រ្តថវិកាផ្អែកលើគោលនយោបាយ, សសរស្តម្ភទី៥÷ ការប៉ាន់ប្រមាណនិងការត្រួតពិនិត្យការអនុវត្តថវិកា, សសរស្តម្ភទី៦÷ គណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងសសរស្តម្ភទី៧÷ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ។




*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!*

យើងបានរៀបចំសម្រេចបាននូវរបាយ-ការណ៍វាយតម្លៃ PEFA ចំនួន ២ ដងរួចមកហើយ គឺរបាយការណ៍ PEFA លើកទី១ ត្រូវបានរៀបចំរួចរាល់នៅក្នុងឆ្នាំ ២០១០ សម្រាប់ការវាយតម្លៃ ការអនុវត្តក្នុង ឆ្នាំ ២០០៦, ២០០៧ និង ២០០៨ និងត្រូវបានយកមកប្រើប្រាស់សម្រាប់រៀបចំក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី២។ រីឯរបាយការណ៍ PEFA លើកទី២ ត្រូវបានរៀបចំរួចរាល់ និងផ្សព្វផ្សាយ នៅក្នុងឆ្នាំ ២០១៥ សម្រាប់ការវាយតម្លៃការអនុវត្តចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ ត្រូវបានយកមកប្រើប្រាស់សម្រាប់រៀបចំក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៣។ នៅលើកទី១ ឆ្នាំ២០១០ ការវាយតម្លៃត្រូវបានរៀបចំដោយក្រុម ទីប្រឹក្សាអន្តរជាតិ រីឯក្រសួង- ស្ថាប័នកម្ពុជា គឺជាអ្នកចូលរួម ចំណែកឯការវាយតម្លៃលើកទី២ គឺដឹកនាំអនុវត្តផ្ទាល់ដោយអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានការរួមចំណែកវាយតម្លៃទាំងអស់គ្នាពីគ្រប់អង្គភាព និងក្រសួង-ស្ថាប័នកម្ពុជា រឹងទីប្រឹក្សាអន្តរជាតិជាអ្នកចូលរួមក្នុងការត្រួតពិនិត្យ និងធានាគុណភាពនៃរបាយការណ៍ធៀបទៅនឹងស្តង់ដារ PEFA វិញម្តង។ ជាមួយគ្នានេះ ខ្ញុំសូមជម្រាបអំពីវឌ្ឍនភាពការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រដ្ឋបាលភ្នំពេញ ផងដែរថា ក្រុមការងារ បានរៀបចំសេចក្តីព្រាងរបាយការណ៍ព្រមទាំងបាន ឱ្យប្រជុំពិភាក្សាពិគ្រោះយោបល់នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ នៅខេត្តសៀមរាប កន្លងទៅនេះ។ តាមផែនការការងារយើងនឹងបញ្ចប់របាយការណ៍នេះ ហើយផ្ញើជូនលេខាធិការដ្ឋាន PEFA នៅរដ្ឋវ៉ាស៊ីនតោន នៃសហរដ្ឋអាមេរិក ក្រោមការគាំទ្រជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីពិនិត្យលើគុណភាព និងសិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយនៅដើមខែមករា ឆ្នាំ២០២០។

សម្រាប់ការវាយតម្លៃ PEFA ថ្នាក់ជាតិ ក៏នៅតែប្រកាន់យកអភិក្រម "ក្រុមការងារវាយតម្លៃរបស់រដ្ឋាភិបាល ជាអ្នករៀបចំរបាយការណ៍ រឹងទីប្រឹក្សាអន្តរជាតិ ជាអ្នកត្រួតពិនិត្យគុណភាពនិងផ្តល់យោបល់ ដើម្បីកែសម្រួលរបាយការណ៍ឱ្យមានភាពគ្រប់ជ្រុងជ្រោយស្របតាមស្តង់ដារ PEFA" ក្នុងគោលបំណងបង្កើនសមត្ថភាពមន្ត្រីរាជការទាំងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស ដើម្បីជាធាតុចូលបន្ថែមធ្វើការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤ ដែលនឹងគ្រោងចាប់ផ្តើមប្រកាសដាក់ឱ្យអនុវត្តនៅឆ្នាំ២០២១ ខាងមុខនេះ។



សកម្មភាពសិក្សាក្នុងវគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!*

លទ្ធផលនៃការវាយតម្លៃ PEFA លើកទី១ និងលើកទី២ បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ថាការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា បាននិងកំពុងស្ថិតនៅលើវិថីវឌ្ឍនាការ រីកចម្រើនដ៏គួរជាទីសង្ឃឹមមុតមាំណាស់ ដែលឆ្លុះបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នាក្នុងការប្តូរផ្តាច់មោះមុតខិតខំអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលជាង ១០ ឆ្នាំ កន្លងមក។ ទន្ទឹមនេះ, យើងសង្ឃឹមថា ការវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងបង្ហាញនូវការជះឥទ្ធិពលវិជ្ជមាននៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា មានលក្ខណៈ


រូបភាពក្នុងកម្មវិធី បើកវគ្គបណ្តុះបណ្តាលស្តីពីក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩



សកម្មភាពបង្រៀនក្នុងវគ្គបណ្ដុះបណ្ដាលស្ដីពីក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

កាន់តែប្រសើរឡើងស្របតាមឧត្ដមានុវត្តន៍អន្តរជាតិ។

តាងនាមឱ្យអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់, ខ្ញុំសូមលើកទឹកចិត្តនិងសំណូមពរដល់ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី មេត្តាយកចិត្តទុកដាក់, ពិភាក្សា និងចោទសួរក្នុងវគ្គបណ្ដុះបណ្ដាលរយៈពេលពីរថ្ងៃនេះ អំពីចំណុចគន្លឹះៗដោយក្នុងនោះរួមមាន÷

**(ទី១).** ទស្សនាទាន និងសារៈសំខាន់នៃការប្រើប្រាស់ក្របខណ្ឌ PEFA ក្នុងការវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

**(ទី២).** កិច្ចដំណើរការនិងវិធីសាស្ត្រវាយតម្លៃ PEFA ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**(ទី៣).** ភាពខុសប្លែកគ្នារវាងក្របខ័ណ្ឌ PEFA ឆ្នាំ២០១១ និងក្របខ័ណ្ឌ PEFA ឆ្នាំ២០១៦ ។

**(ទី៤).** កំណត់ភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាតាមរយៈរបាយការណ៍ PEFA ឆ្នាំ២០១៥។

**(ទី៥).** អត្ថប្រយោជន៍ក្នុងការប្រើប្រាស់ឧបករណ៍ PEFA ដើម្បីរៀបចំក្របខ័ណ្ឌផែនការសកម្មភាពរួមសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រង់ហិរញ្ញវត្ថុសាធារណៈ។

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីជាថ្នាក់ដឹកនាំនិងមន្ត្រីរាជការមកពីគ្រប់ក្រសួង- ស្ថាប័ន, រដ្ឋបាលរាជធានី- ខេត្ត និងតំណាងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែផ្ដល់កិច្ចសម្របសម្រួល, កិច្ចសហការ និងការសាសងប្រាស្រ័យទាក់ទងជាមួយគ្នាជារៀងដរាប ដល់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់គ្រប់តំណាងដៃគូ-អភិវឌ្ឍន៍ ដែលតែងបានផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ដ៏មានសារៈសំខាន់ចាំបាច់ ជាពិសេសសហភាពអឺរ៉ុប ដើម្បីរួមចំណែកក្នុងកិច្ចការវាយតម្លៃ PEFA ថ្នាក់ ជាតិឆ្នាំ២០២០។

ជាទីបញ្ចប់, ខ្ញុំសូមគោរពជូនពរ ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រី សូមបានប្រកបដោយសុខភាពល្អបរិបូរ, កម្លាំងពលំមាំមួន និងសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុង គ្រប់ភារកិច្ច។ ខ្ញុំសូមប្រកាសបើក «វគ្គបណ្ដុះបណ្ដាលស្ដីពីក្របខណ្ឌចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ» ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ !**



រូបភាពក្នុងកម្មវិធី បញ្ចប់វគ្គបណ្ដុះបណ្ដាលស្ដីពីក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

# ផ្នែកទី៤

# ទស្សនៈ និងមតិ







ប្រសាសន៍របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងកិច្ចប្រជុំជាមួយនឹងគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា ស្ដីពីសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០, នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩

*“ ថវិកាយុទ្ធសាស្ត្រនៃការផ្គួបកម្លាំងសរុបដើម្បីទប់ទល់នឹងបញ្ហាប្រឈម និងហានិភ័យ, ទាំងក្នុង និងក្រៅប្រទេស, តាមរយៈការពង្រឹងសមត្ថភាពផ្ទៃក្នុងដោយជំរុញឱ្យបានខ្លាំក្លានូវការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចដើម្បីធានាសុខសន្តិភាព ស្ថិរភាពនិងចីរភាពនៃកំណើនសេដ្ឋកិច្ច សំដៅលើកកម្ពស់សុខុមាលភាពជូនប្រជាជនលើមាគ៌ាឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។”*



ប្រសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ថ្លែងក្នុងកម្មវិធី ការចែករំលែកគន្លឹះសំខាន់ៗក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS សម្រាប់ ក្រសួង-ស្ថាប័ន

*“ ក្រៅពីជាស្ថាប័នគ្រប់គ្រងការអនុវត្តគម្រោងអេហ្វអឹមអាយអេស (FMIS) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើជាគំរូក្នុងការកាត់បន្ថយនីតិវិធីអនុវត្តការងារក្រៅប្រព័ន្ធជាជំហានៗដើម្បីសម្រេចបាននូវការធ្វើប្រតិបត្តិការថវិកាក្នុងប្រព័ន្ធអេហ្វអឹមអាយអែសទាំងស្រុង ។”*

*“ ការងារកែទម្រង់ចៀសមិនផុតពីបញ្ហាប្រឈមឡើយ ទាំងនៅកម្រិតដឹកនាំ កម្រិតគ្រប់គ្រង និងកម្រិតប្រតិបត្តិការបច្ចេកទេស។ នេះពុំមែនជាបញ្ហាដោយឡែកសម្រាប់កម្ពុជាឡើយ នេះគឺជាបញ្ហាសកលដែលប្រទេសនានាលើសកលលោក ធ្លាប់បានឆ្លងកាត់រួចមកហើយនៅលើវិថីកែទម្រង់របស់ខ្លួន។”*



ប្រសាសន៍របស់ឯកឧត្តមកិត្តិបរិរក្សបណ្ឌិត **គាត ឈន់** ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ថ្លែងក្នុងសិក្ខាសាលាស្តីពីការបង្កើនភាពជាម្ចាស់លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។

*“ រាល់យុទ្ធសាស្ត្រដែលទើបទទួលបានការអនុម័តថ្មីៗនេះ គឺជាឆ្អឹងខ្នងក្នុងការកសាងរដ្ឋបាលទំនើបមួយដោយផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយកាន់តែខ្លាំងឡើង”*



**EUROPEAN UNION**

មតិរបស់ដៃគូអភិវឌ្ឍន៍នាកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងក្រុមបច្ចេកទេសដៃគូអភិវឌ្ឍន៍ ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩, នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ÷

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ **អ.គ.ហ.** |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង **អ.គ.ហ.** |
| មាស សុខសេនសាន | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង **អ.គ.ហ.** |
| អ៊ុង លុយណា | អគ្គលេខាធិការរង **អ.គ.ហ.** |
| យ៉េត វីណែល | អគ្គលេខាធិការរង **អ.គ.ហ.** |

## រៀបចំអត្ថបទដោយ ÷

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| វុទ្ធី សត្រា | មន្ត្រីជំនាញ |

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | ជំនួយការ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | មន្ត្រីជំនាញ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញជាន់ខ្ពស់ |
| រស់ ដាលីន | មន្ត្រីជំនាញ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ន | មន្ត្រីជំនាញ |
| ផៃង សុខម៉ៃ | មន្ត្រីជំនាញ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីជំនាញជាន់ខ្ពស់ត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យន ម៉ាលីមឆេង | មន្ត្រីជំនាញជាន់ខ្ពស់ថវិកា |
| ឈុន ម៉ារឌី | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| អ៊ុង វលក្ខទេវី | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ឡេង ចាន់ភួង | ជំនួយការមន្ត្រីថវិកា |

ការចូលរួមផ្សេងៗ÷

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានរតនាគារជាតិ

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## នវានុវត្ត និងកែសម្រួលដោយ ÷

ផ្នែកនវានុវត្តន៍ ផ្សព្វផ្សាយ និងកសាងសមត្ថភាព

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | ជំនួយការ |

អាសយដ្ឋានទំនាក់ទំនង÷
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ:(៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm